## បេឡាជាតិរបបសន្តិសុខសង្គម

# ផែនការយុទ្ធសាស្ត្រ
# អនុវត្តវិស័យសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ
# ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
# ២០១៣-២០១៥

ធានាសន្តិសុខប្រាក់ចំណូល រួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ស្ថិរភាពសង្គម

# បេឡាជាតិរបបសន្តិសុខសង្គម

# ផែនការយុទ្ធសាស្ត្រ
# អនុវត្តវិស័យសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ
# ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
# ២០១៣-២០១៥

ធានាសន្តិសុខប្រាក់ចំណូល រួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ស្ថិរភាពសង្គម

# អារម្ភកថា

ប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា បានចាប់ផ្តើមឡើងនៅឆ្នាំ១៩៥៥ ប៉ុន្តែត្រូវលុបបំបាត់ចោលទៅវិញក្រោមរបបកម្ពុជាប្រជាធិបតេយ្យនៅកំឡុងឆ្នាំ១៩៧៥-១៩៧៩។ ក្រោយរបបនេះបានបញ្ចប់ទៅ ជាបន្តបន្ទាប់រហូតមកនៅឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ប្រទេស និង ច្បាប់ស្តីពីការងារនៅឆ្នាំ១៩៩៧។ យោងទៅលើច្បាប់ទាំងពីរនេះនៅឆ្នាំ២០០២ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវបានបង្កើតឡើង និង ដោយអនុលោមតាមច្បាប់នេះ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ត្រូវបានបង្កើតដោយអនុក្រឹត្យនាឆ្នាំ២០០៧ និង រហូតមកដល់ខែវិច្ឆិកា ឆ្នាំ២០០៨ ប.ស.ស បានចាប់ផ្តើមដំណើរការជំហានទី១ របស់ខ្លួន គឺរបបធានារ៉ាប់រងហានិភ័យការងារដោយជោគជ័យ។

អនុលោមតាមច្បាប់ ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ស្ថានភាពរីកចំរើននៃសេដ្ឋកិច្ចជាតិ និងការធ្វើសមាហរណកម្មក្នុងតំបន់ បេឡាជាតិរបបសន្តិសុខសង្គម បាននឹងកំពុងត្រៀមខ្លួនតាមរយៈការរៀបចំពង្រីក ពង្រឹង និង អភិវឌ្ឍសមត្ថភាពរបស់ខ្លួនបន្ថែមទៀត ដោយបានរៀបចំនូវផែនការយុទ្ធសាស្ត្ររយៈពេលបីឆ្នាំនេះឡើង ដែលមានចក្ខុវិស័យ និង បេសកកម្មដ៏ច្បាស់លាស់ក្នុងការអនុវត្តផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឲ្យទទួលបាននូវសេវាសន្តិសុខសង្គម នៅពេលដែលពួកគាត់ជួបប្រទះនូវយថាភាពផ្សេងៗ មានជាអាទិ៍ ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ និង មាតុភាពជាដើម។

ក្នុងស្ថានភាពដែលប្រទេសកម្ពុជាមានការរីកចំរើនលើគ្រប់វិស័យ ការធានាផ្នែកសន្តិសុខសង្គមមានសារៈសំខាន់ខ្លាំងណាស់ ដោយបានផ្តល់នូវការគាំពារចំពោះប្រជាជនកម្ពុជានិយាយជារួម និងនិយាយដោយឡែកសម្រាប់កម្មករនិយោជិត ដែលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន ដោយផ្អែកលើទស្សនាទាននៃការចែករំលែក និង គោលការណ៍សាមគ្គីធម៌ក្នុងសង្គម ធានាបាននូវសន្តិសុខប្រាក់ចំណូល ពោលគឺមានន័យថា តាមរយៈការធានាផ្នែកសន្តិសុខសង្គម គ្មានសមាជិកសង្គមណាម្នាក់ធ្លាក់ទៅក្នុងហានិភ័យនៃភាពក្រីក្រ ដោយមិនអាចងើបរួចបានឡើយ។ ម្យ៉ាងទៀតគោលនយោបាយសន្តិសុខសង្គម ក៏រួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគោលការណ៍នៃការចែករំលែកប្រាក់ចំណូល តាមខ្សែទទឹង និង ខ្សែបណ្តោយ គឺមានន័យថា អ្នកមានប្រាក់ចំណូលខ្ពស់ជួយដល់អ្នកមានប្រាក់ចំណូលទាប អ្នកមានសុខភាពល្អជួយដល់អ្នកមានជំងឺ ជនពិការ ឬ អ្នកដែលទទួលរងនូវគ្រោះថ្នាក់ផ្សេងៗ ជនមានវ័យក្មេងជួយដល់ជនចាស់ជរា ដែលការនេះធ្វើឲ្យមនុស្សក្នុងសង្គមទាំងមូល ទទួលបាននូវភាពកក់ក្តៅក្នុងជីវភាពរស់នៅធានារក្សាបានស្ថិរភាព និងភាពសុខដុមរមនានៅក្នុងសង្គម។

តាងនាមក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក និង កម្មករនិយោជិត នៃបេឡាជាតិរបបសន្តិសុខសង្គម និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវការអរគុណ និង ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម ខង សួត** រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដែលឯកឧត្តមបានផ្តល់នូវការគាំទ្រទាំងផ្នែកនយោបាយ និង បច្ចេកទេស រហូតដល់បេឡាជាតិរបបសន្តិសុខសង្គម អាចដំណើរការបានប្រកបដោយជោគជ័យគួរជាទីមោទនៈ។ ខ្ញុំក៏សូមអរគុណផងដែរចំពោះឯកឧត្តម អស់លោក ជាសមាជិកក្រុមប្រឹក្សាភិបាល ដែលបានជួយជ្រោមជ្រែង និង គាំទ្រចំ ពោះការរៀបចំគោលការណ៍ លិខិតបទដ្ឋាននានា ដែលជាមូលដ្ឋានគ្រឹះធ្វើឲ្យ ប.ស.ស អាចចាប់ផ្តើមប្រតិបត្តិការប្រកបដោយភាពរលូន និង មានប្រសិទ្ធភាព។ ម្យ៉ាងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះការចូលរួមគាំទ្រសហការពីសំណាក់ក្រសួង និង ស្ថាប័នពាក់ព័ន្ធនានាទាំងអស់ដល់កិច្ចដំណើរការរបស់បេឡាជាតិរបបសន្តិសុខសង្គមរហូតមកដល់ថ្ងៃនេះ ជាពិសេសចំពោះនិយោជក និង កម្មករនិយោជិត ដែលបានចូលរួមសហការ និង អនុវត្តតាមច្បាប់បានល្អប្រសើរ ហើយខ្ញុំសូមឲ្យមានការបន្តនូវកិច្ចសហការនេះបន្ថែមទៀត ដល់កិច្ចដំណើរការរបស់បេឡាជាតិរបបសន្តិសុខសង្គម នៅក្នុងបេសកកម្មបម្រើសេវាសាធារណៈមានលក្ខណៈសង្គម ឲ្យបានកាន់តែប្រសើរថែមទៀត។ តាមរយៈការចូលរួមដ៏ស្មោះត្រង់ពីគ្រប់ផ្នែកដែលពាក់ព័ន្ធទាំងអស់នេះ បេឡាជាតិរបបសន្តិសុខសង្គម សង្ឃឹមយ៉ាងមុតមាំថា ផែនការយុទ្ធសាស្ត្រនេះនឹងត្រូវបានអនុវត្តដោយជោគជ័យ និង ប្រព្រឹត្តទៅតាមការគ្រោងទុក ហើយវានឹងក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាព និង ជាត្រីវិស័យសម្រាប់នាំផ្លូវដល់ការអនុវត្តគោលនយោបាយសន្តិសុខសង្គមឲ្យមានការអភិវឌ្ឍ និងគ្រប់ជ្រុងជ្រោយ ដើម្បីជាផលប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស**

**ប្រធាន**

# សេចក្តីសង្ខេប

ផែនការយុទ្ធសាស្ត្ររបស់បេឡាជាតិរបបសន្តិសុខសង្គមឆ្នាំ២០១៣-២០១៥ ត្រូវបានធ្វើឡើង ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២" និង "ផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ឆ្នាំ២០០៩-២០១៣" របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និង អនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និង អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម។

ផែនការយុទ្ធសាស្ត្រនេះរួមមាន ៥ ជំពូក ដែលបានលើកឡើងពីចក្ខុវិស័យ បេសកកម្ម គោលដៅ ទិសដៅ និង សកម្មភាពយ៉ាងច្បាស់លាស់ ដោយមានសូចនាករសម្រាប់វាស់វែង តាមដាន និង ត្រួតពិនិត្យវាយតម្លៃការអនុវត្ត ហើយក៏បានដាក់បញ្ចូលនូវគោលនយោបាយជាតិ អន្តរជាតិ និង ទិន្នន័យសំខាន់ៗមួយចំនួនសម្រាប់ឆ្លុះបញ្ចាំងពីការអនុវត្តវិស័យសន្តិសុខសង្គមផងដែរ។

***ជំពូកទី១.*** សេចក្តីផ្តើមបានលើកឡើងពីប្រវត្តិ និង និយមន័យសន្តិសុខសង្គម ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៅកម្ពុជា និង រចនាសម្ព័ន្ធគ្រប់គ្រង។ បរិបទស្តីពីសន្តិសុខសង្គម បានកើតឡើងក្នុងអំឡុងទសវត្ស៨០ នៃសតវត្សទី១៩ នៅប្រទេសអាល្លឺម៉ង់ ប៉ុន្តែពាក្យថា "សន្តិសុខសង្គម" ត្រូវបានគេជួបប្រទះដំបូងបំផុតនៅសហរដ្ឋអាមេរិក នៅក្នុងច្បាប់សន្តិសុខសង្គម (Social Security Act) ដែលបានអនុម័តនៅឆ្នាំ១៩៣៥ ក្រោយមកពាក្យនេះក៏ត្រូវបានសហប្រជាជាតិយកមកប្រើនៅក្នុងសេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្សនៅឆ្នាំ១៩៤៨។ រីឯនិយមន័យសន្តិសុខសង្គម មានលក្ខណៈទីទៃពីគ្នារវាងប្រទេសនានា ប៉ុន្តែក្នុងនោះមានបង្កប់នូវចំណុចរួមមួយ ដែលមិនអាចបំភ្លេចបាន គឺវិធានការជួយសម្រាលបន្ទុកក្នុងគ្រាដែលជនណាម្នាក់បាត់បង់ ឬថមថយនូវប្រាក់ចំណូល ពុំអាចទ្រទ្រង់ជីវភាពក្នុងគ្រួសារបាន។

ព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីទទួលបានឯករាជ្យពីអាណាព្យាបាលបារាំងនៅឆ្នាំ១៩៥៣ ព្រះរាជក្រមលេខ៣ នស ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៥៥ ត្រូវបានប្រកាសឲ្យប្រើ។ អនុលោមតាមព្រះរាជក្រមនេះ កម្មករនិយោជិត មានសិទ្ធិទទួលបាននូវប្រាក់ឧបត្ថម្ភសម្រាប់ប្រពន្ធ និងកូន ដែលនេះអាចចាត់ទុកជាការចាប់ផ្តើមឡើងនៃប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា។ ជាអកុសល ប្រព័ន្ធនេះត្រូវបានបំផ្លិចបំផ្លាញចោលទៅវិញក្រោមរបបកម្ពុជាប្រជាធិបតេយ្យនៅកំឡុងឆ្នាំ១៩៧៥-១៩៧៩។ នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា កម្មករនិយោជិតទាំងអស់ ទទួលបានការគាំពារផ្នែកសោធននិវត្តន៍ ទុព្វលភាព មរណភាព និងគ្រោះថ្នាក់ការងារ។ ចាប់ពីឆ្នាំ១៩៨៩ មកដោយសារមានកំណែទម្រង់ពីសេដ្ឋកិច្ចផែនការ មកសេដ្ឋកិច្ចទីផ្សារ ប្រព័ន្ធសន្តិសុខសង្គមសម្រាប់កម្មករនិយោជិតផ្នែកឯកជន ត្រូវបានកែសម្រួលស្របតាមស្ថានភាពសេដ្ឋកិច្ចជាក់ស្តែង។ ច្បាប់ការងារឆ្នាំ១៩៩២ ត្រូវបានប្រកាសឲ្យប្រើ ដែលបានតម្រូវឲ្យនិយោជក ជាអ្នកទទួលបន្ទុកលើគ្រោះថ្នាក់ការងារ ដែលកើតឡើងជាយថាហេតុចំពោះកម្មករនិយោជិតរបស់ខ្លួន។ ក្រោយការបោះឆ្នោតសាកលឆ្នាំ១៩៩៣ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីការងារនៅឆ្នាំ១៩៩៧ នៅ

ឆ្នាំ២០០២ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវបានប្រកាសឲ្យប្រើ។ ដោយអនុលោមតាមច្បាប់នេះ នៅឆ្នាំ២០០៧ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវបានបង្កើតឡើង ហើយរហូតមកដល់ចុងឆ្នាំ២០០៨ បានដាក់ឲ្យដំណើរការជំហានទី១ របបធានារ៉ាប់រងហានិភ័យការងារដោយជោគជ័យ។ ប.ស.ស ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និង អាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលចូលរួមដោយត្រីភាគី និងអង្គការប្រតិបត្តិដែលគ្រប់គ្រងដោយនាយក០១ រូប និង នាយករងមួយចំនួនជាជំនួយការ រួមទាំងការិយាល័យថ្នាក់កណ្តាល ការិយាល័យតាមបណ្តារាជធានី-ខេត្ត និង គណៈកម្មការជំនាញមួយចំនួន។

***ជំពូកទី២.*** លើកឡើងពីទិដ្ឋភាពផ្នែកច្បាប់ និង ឯកសារគតិយុត្តសំខាន់ៗមួយចំនួន ដែលរួមមានទាំងបទដ្ឋានជាតិ និង អន្តរជាតិទាក់ទងនឹងការអនុវត្តផ្នែកសន្តិសុខសង្គម។ នៅក្នុងបទដ្ឋានជាតិ មានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដែលនៅជំពូកទី៦ អំពីអប់រំ វប្បធម៌ និងសង្គមកិច្ច មាត្រា៧៥ បានចែងថា *“រដ្ឋចាត់ចែងឲ្យមានរបបសន្តិសុខសង្គមដល់កម្មករ និងនិយោជិត”*។ ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មានចែងនៅក្នុងជំពូកទី៩ អំពីគ្រោះថ្នាក់ការងារ មាត្រា(២៤៨-២៥៧)។ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារឆ្នាំ២០០២ អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមឆ្នាំ២០០៧ និង បទដ្ឋានគតិយុត្តមួយចំនួនទៀត។ រីឯបទដ្ឋានអន្តរជាតិវិញរួមមានសេចក្តីប្រកាសជាសាកលអំពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ បានចែងថា *"មនុស្សគ្រប់រូបក្នុងឋានៈខ្លួនជាសមាជិកសង្គមត្រូវមានសិទ្ធិខាងសន្តិសុខសង្គម"* អនុសញ្ញាលេខ១០២ របស់អង្គការអន្តរជាតិខាងការងារ ដែលជាមូលដ្ឋានគ្រឹះផ្នែកសន្តិសុខសង្គម និង ជាអនុសញ្ញាអន្តរជាតិតែមួយគត់ ដែលបានកំណត់ពីតាវកាលិកទាំងប្រាំបួននៃសន្តិសុខសង្គមដែលរួមមាន *១.ការថែទាំវេជ្ជសាស្ត្រ ២.ជំងឺ ៣.និកម្មភាព ៤.ជរាភាព ៥.គ្រោះថ្នាក់ការងារ ៦.គ្រួសារ ៧.មាតុភាព ៨.ទុព្វលភាព និង៩.ឧត្តរជីវី។* ក្រៅពីបទដ្ឋានខាងលើ ក៏នៅមានបទដ្ឋានសន្តិសុខសង្គមរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសមាគមសន្តិសុខសង្គមអាស៊ាន ដែលកម្ពុជាជាសមាជិក និងបទដ្ឋានអន្តរជាតិមួយចំនួនទៀត ដែលទាក់ទងទៅនឹងផ្នែកសន្តិសុខសង្គមដែលត្រូវបានអភិវឌ្ឍ និងរៀបចំឡើងតាមរយៈការពិភាក្សា និងទទួលស្គាល់ជាសកលផងដែរ។

នៅក្នុងផែនការយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍជាតិ កាត់បន្ថយភាពក្រីក្រ និងលើកកំពស់ស្ថិរភាពសង្គម រាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ចូលនូវផ្នែកសន្តិសុខសង្គមជាសកម្មភាពចម្បង ទៅក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួន ដូចមាននៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ *“មុំទី៣ ការអភិវឌ្ឍផ្នែកឯកជន និងការងារ ចំនុចទី៤ ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម”*។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ បានកំណត់នូវក្រសួង ស្ថាប័ន ដែលជាអ្នកទទួលខុសត្រូវអនុវត្តគោលនយោបាយជាអាទិភាពទាំងឡាយក្នុងមុំនីមួយៗ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (២០១១-២០១៥) *(ជំពូកទី២ ការគាំពារសង្គម គឺជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា)*។ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

ឆ្នាំ២០១១-២០២០ *នៅជំពូកទី៣* ស្តីពីវិស័យហិរញ្ញវត្ថុមិនមែនធនាគារ បានលើកឡើងពីវិស័យធានារ៉ាប់រងសោធន និងទីផ្សារទុន។ ចំពោះផ្នែកសោធន រដ្ឋាភិបាលបានបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) បេឡាជាតិអតីតយុទ្ធជន (ប.ជ.អ) មូលនិធិជនពិការ (ម.ជ.ព) រីឯរបបសោធនសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ នឹងត្រូវបានអនុវត្តដោយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។ មួយវិញទៀត នៅក្នុងផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ឆ្នាំ២០០៩-២០១៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់ជាអាទិភាពទី៣ សម្រាប់ជំរុញការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម។

***ជំពូកទី៣.*** បង្ហាញអំពីកត្តាកំណត់ និងស្ថានភាពពាក់ព័ន្ធមួយចំនួន ដែលជះឥទ្ធិពលដល់ការអនុវត្តគោលនយោបាយសន្តិសុខសង្គម រួមមានកត្តាប្រជាសាស្ត្រ កត្តាម៉ាក្រូសេដ្ឋកិច្ច ស្ថានភាពសហគ្រាស គ្រឹះស្ថាន និងអ្នកចូលរួមការងារ និង ស្ថានភាពវិស័យធានាសន្តិសុខសង្គមនៅកម្ពុជា ដែលជាព័ត៌មានសំខាន់សម្រាប់ប្រៀបធៀប វាយតម្លៃ និងរៀបចំផែនការអនុវត្តផ្នែកសន្តិសុខសង្គមឲ្យមានប្រសិទ្ធភាព និង ស្របតាមស្ថានភាពសង្គម។ យោងតាមលទ្ធផលចុងក្រោយជំរឿនទូទៅស្ថិតិប្រជាសាស្ត្រឆ្នាំ២០០៨ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ព្រះរាជាណាចក្រកម្ពុជាមានប្រជារាស្ត្រចំនួន ១៣.៣៩៥.៦៨២ នាក់ ប្រុសមានចំនួន ៦.៥១៦.០៥៤ នាក់ (៤៨,៦៤ ភាគរយ) ស្រីចំនួន ៦.៨៧៩.៦២៨ នាក់ (៥១,៣៦ ភាគរយ)។ អាយុមធ្យមរបស់បុរសមាន ៦០,៥ ឆ្នាំ និងស្ត្រីមាន ៦៤,៣ ឆ្នាំ។ ដង់ស៊ីតេប្រជារាស្ត្រ ៧៥ នាក់ ក្នុងមួយគីឡូម៉ែត្រទ្វេគុណ និងអត្រាកំណើនប្រចាំឆ្នាំ ១,៥៤ ភាគរយ។ កុមារដែលស្ថិតនៅចន្លោះក្រុមអាយុពី (០-១៤) ឆ្នាំ មានចំនួន ៣៣,៧ ភាគរយ ក្រុមអាយុក្នុងសកម្មភាពសេដ្ឋកិច្ចពី(១៥-៦៤) ឆ្នាំ មានចំនួន ៦២ ភាគរយ និងក្រុមអាយុប្រជាជនវ័យចំណាស់ពី (៦៥+) ឆ្នាំ មានចំនួន ៤,៣ ភាគរយ។

ម៉ាក្រូសេដ្ឋកិច្ចកម្ពុជា មានកំណើន ៧,១% នៅឆ្នាំ២០១១ និង ៧,៣ ភាគរយ នៅឆ្នាំ២០១២ ហើយត្រូវបានព្យាករណ៍ថានឹងសម្រេចបានក្នុងរង្វង់ ៧% នៅឆ្នាំ២០១៣ នេះ ដែលបានមកពីការបន្តនៃកំណើនព្រមគ្នានៃវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។

យោងតាមលទ្ធផលចុងក្រោយ នៃជំរឿនសហគ្រាសឆ្នាំ២០១១ កម្ពុជាមានសហគ្រាសចំនួន ៥០៥.១៤៣ អ្នកចូលរួមក្នុងការងារសរុប ១.៦៧៦.២៦៣ នាក់ ដោយមានអ្នកចូលរួមការងារភេទប្រុសចំនួន ៦៥០.១៧៩ នាក់ ស្មើនឹង ៣៨,៨ ភាគរយ និងអ្នកចូលរួមការងារភេទស្រី មានចំនួន ១.០២៦.០៨៤ នាក់ស្មើនឹង ៦១,២ ភាគរយ ។ ចំនួនសហគ្រាស ដែលមានអ្នកធ្វើការពី០១ ទៅ ០២ នាក់ មានចំនួនប្រហែល ៨០ ភាគរយ នៃចំនួនសហគ្រាសសរុប។ ចំនួនសហគ្រាសមានអ្នកធ្វើការ ០៥ នាក់ ឬ ច្រើនជាងមានចំនួន ៤០ ពាន់សហគ្រាស ស្មើនឹង ៧,៨ ភាគរយ មានអ្នកចូលរួមការងារចំនួន ៨៧៩.០០០ នាក់ ហើយចំនួនសហគ្រាសដែលមានអ្នកធ្វើការ ១០ នាក់ ឬ ច្រើនជាងមានចំនួន ១៣ ពាន់សហគ្រាសស្មើនឹង ២,៦ ភាគរយ មានអ្នកចូលរួមការងារចំនួន ៧១៦.០០០ នាក់ ចំណែកឯសហគ្រាសដែលមានអ្នកធ្វើការ ១០០ នាក់ ឬ ច្រើនជាងមានចំនួន ៧៨៧ សហគ្រាស

ស្មើនឹង ០,២ ភាគរយ ហើយចំនួនសហគ្រាសដែលមានអ្នកធ្វើការ ១.០០០ នាក់ ឬ ច្រើនជាងមាន ចំនួន ១១៩ សហគ្រាស។

ប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជារួមមាន របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិត នៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងបណ្តាញ សុវត្ថិភាពសង្គមសម្រាប់ជនក្រីក្រ និង ជនងាយរងគ្រោះ ដែលបណ្តាញសុវត្ថិភាពសង្គមនេះ មានការ ចូលរួមពីបណ្តាក្រសួង ដៃគូអភិវឌ្ឍន៍ អង្គការ និងស្ថាប័នពាក់ព័ន្ធនានា លើការផ្តល់នូវការគាំពារសង្គម សម្រាប់ប្រជាជនទូទៅ ឲ្យទទួលបាននូវអាហារូបត្ថម្ភ ការថែទាំសុខភាព ការអប់រំបច្ចេកទេស និង វិជ្ជាជីវៈ ការការពារ និង ការជួយអន្តរាគមន៍ពីសង្គមនៅពេលដែលទទួលរងហានិភ័យផ្សេងៗ។

***ជំពូកទី៤.*** ការអនុវត្តរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារ (ជំហានទី១) បានលើកឡើងអំពី ដំណើរការរបស់បេឡាជាតិរបបសន្តិសុខសង្គមជារួម និង គោលនយោបាយនៃការអនុវត្តរបបធានា រ៉ាប់រងហានិភ័យការងារ ពីនិយមន័យគ្រោះថ្នាក់ការងារ (*គ្រោះថ្នាក់នៅពេលធ្វើការ ឬក្នុងពេលធ្វើការ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺដែលបណ្តាលមកពីវិជ្ជាជីវៈ)* និង បែបបទ នីតិវិធីនៃការចុះបញ្ជិកា និងបង់ភាគទាន និងតាវកាលិក (អត្ថប្រយោជន៍) ដែលជនរងគ្រោះថ្នាក់ការងារជាសមាជិកនៃ ប.ស.ស ត្រូវទទួលបាន។ មួយវិញទៀត វាក៏បានលើកឡើងពីលទ្ធផលការងារសម្រេចបានលើការអនុវត្ត ជំហានទី១ របបធានារ៉ាប់រងហានិភ័យការងារផងដែរ ដែលចាប់តាំងពីការអនុវត្តដំបូងនាខែវិច្ឆិកា ឆ្នាំ២០០៨ រហូតមកដល់ដំណាច់ឆ្នាំ២០១២ បេឡាជាតិរបបសន្តិសុខសង្គម បានពង្រីកវិសាលភាព របបធានារ៉ាប់រងហានិភ័យការងារបានចំនួន ២០/២៤ រាជធានី-ខេត្ត ចុះកិច្ចសន្យាប្រើប្រាស់សេវា សុខាភិបាលជាមួយមន្ទីរពេទ្យ មណ្ឌលសុខភាព និងមន្ទីរព្យាបាលឯកជនចំនួន៥១ និងបានចុះបញ្ជិកា សហគ្រាស គ្រឹះស្ថាន ចំនួន ៤.៥៨៣ សហគ្រាស មានកម្មករនិយោជិតសរុបចំនួន ៧៦៨.១៣៤ នាក់ និង បានផ្តល់ការធានារ៉ាប់រងគ្រោះថ្នាក់ការងារដល់សមាជិកចំនួនប្រមាណ ៣៧.០០០ នាក់។

***ជំពូកទី៥.*** បានលើកឡើងអំពីផែនការយុទ្ធសាស្ត្ររយៈពេលបីឆ្នាំ របស់បេឡាជាតិរបបសន្តិ សុខសង្គម ដោយបានអត្ថាធិប្បាយលម្អិតអំពីសកម្មភាពទាំងឡាយ ដែលមាននៅក្នុងគោលដៅ និង ទិសដៅនីមួយៗ សម្រាប់អនុវត្តពីឆ្នាំ២០១៣-២០១៥។ ក្នុងគោលដៅទី១ ពាក់ព័ន្ធនឹងការពង្រីក និង ពង្រឹងការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ បានកំណត់ទិសដៅធំៗចំនួន៤ ដែលនឹងឈាន ទៅរកការធានានូវប្រសិទ្ធភាព និងការគ្របដណ្តប់នៅទូទាំងប្រទេស។ គោលដៅទី២ ស្តីពីការបង្កើត របបធានារ៉ាប់រងសុខភាព មានសកម្មភាពជាគន្លឹះចំនួន៤ ដែលផ្តោតលើការសិក្សារៀបចំលិខិតបទដ្ឋាន ការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ វិធីសាស្ត្រទូទាត់ និង គ្រប់គ្រងសេវាសុខាភិបាល និងយុទ្ធនាការ ផ្សព្វផ្សាយបញ្ជ្រាបផ្នែកនេះចូលដល់ស្រទាប់មហាជន ជាពិសេសអ្នកប្រើប្រាស់សេវា ឲ្យមានការ យល់ដឹង ដោយសារការងារនេះត្រូវបានចាត់ទុកថា ជារបត់ថ្មីនៃវិស័យសន្តិសុខសង្គមកម្ពុជា ដែល ទាមទារឲ្យមានការបណ្តុះនូវជំនឿទុកចិត្តពីគ្រប់មជ្ឈដ្ឋាន។ គោលដៅទី៣ គឺការបង្កើតឲ្យមានរបប ប្រាក់សោធន ដែលជាគោលការណ៍ត្រូវបានចាត់ទុកថាជាការគាំពាររយៈពេលវែង ពោលគឺការគាំពារ រហូតដល់ដំណាក់កាលនៃជីវិតចុងក្រោយរបស់កម្មករនិយោជិត។

# ចក្ខុវិស័យ បេសកកម្ម និងគោលដៅ

## ចក្ខុវិស័យ

ធានាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## បេសកកម្ម

ផ្តល់សេវាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេលជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀត ដូចជាជំងឺ និងមាតុភាពជាដើម។

## គោលដៅ

ដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យ និងបេសកកម្មខាងលើ បេឡាជាតិរបបសន្តិសុខសង្គមបានកំណត់គោលដៅធំៗចំនួន០៣ សម្រាប់អនុវត្តពីឆ្នាំ២០១៣-២០១៥ ដើម្បីផ្តល់ការធានាសន្តិសុខសង្គមដល់កម្មករនិយោជិតនៅក្នុងវិស័យឯកជន៖

**គោលដៅទី១៖** ពង្រីក និង ពង្រឹងការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

**គោលដៅទី២៖** ដំណើរការរបបធានារ៉ាប់រងសុខភាព

**គោលដៅទី៣៖** ដំណើរការរបបប្រាក់សោធន

# មាតិកា


**អារម្ភកថា** .......... i
**សេចក្ដីសង្ខេប** .......... iii
**ចក្ខុវិស័យ បេសកកម្ម និងគោលដៅ** .......... vii

**ជំពូកទី I. សេចក្ដីផ្ដើម** .......... **១**
១. ប្រវត្តិ និងនិយមន័យសន្តិសុខសង្គម .......... ១
២. ប្រវត្តិសន្តិសុខសង្គម និងការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមនៅកម្ពុជា .......... ២
៣. រចនាសម្ព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម .......... ៣

**ជំពូកទី II. ច្បាប់ និងឯកសារគតិយុត្ត** .......... **៤**
១. បទដ្ឋានជាតិ និងអន្តរជាតិ .......... ៤
២. ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល .......... ៨
៣. ផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ឆ្នាំ២០០៩-២០១៣. .......... ១១

**ជំពូកទី III. កត្តាកំណត់ និងស្ថានភាពផ្សេងៗ** .......... **១៣**
១. កត្តាប្រជាសាស្ត្រ .......... ១៣
២. កត្តាម៉ាក្រូសេដ្ឋកិច្ច .......... ១៤
៣. ស្ថានភាពសហគ្រាស គ្រឹះស្ថាន និងអ្នកចូលរួមការងារ .......... ១៥
៤. ស្ថានភាពវិស័យសន្តិសុខសង្គមនៅកម្ពុជា .......... ១៧

**ជំពូកទី IV. ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ (ជំហានទី១)** .......... **២១**
១. គ្រោះថ្នាក់ការងារ .......... ២១
២. តាវកាលិកគ្រោះថ្នាក់ការងារ .......... ២២
៣. បែបបទ និងនីតិវិធីនៃការចុះបញ្ជិកា និងបង់ភាគទាន .......... ២៣
៤. លទ្ធផលការងារសម្រេចបាន លើការអនុវត្តរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារ ឆ្នាំ២០១២ .......... ២៥

**ជំពូកទី V. ផែនការយុទ្ធសាស្ត្របេឡាជាតិរបបសន្តិសុខសង្គម** .......... **២៧**
គោលដៅទី១៖ ពង្រីក និង ពង្រឹងការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ .......... ២៨
គោលដៅទី២៖ ដំណើរការរបបធានារ៉ាប់រងសុខភាព .......... ៣០
គោលដៅទី៣៖ ដំណើរការរបបប្រាក់សោធន .......... ៣៣

**តារាងម៉ាទ្រិច** .......... ៣៥
**ឧបសម្ព័ន្ធ** .......... ៤៤
**ឯកសារយោង** .......... ៥០

# ជំពូកទី ១
# សេចក្តីផ្តើម

## ១. ប្រវត្តិ និងនិយមន័យសន្តិសុខសង្គម

ថ្វីបើទស្សនាទានស្តីពីសន្តិសុខសង្គមកើតមានជាយូរមកហើយក្តី ពោលគឺ *គំនិតដំបូងស្តីពីសន្តិសុខសង្គមនេះកើតមានតាំងពីអំឡុងទសវត្សរ៍៨០ នៃសតវត្សទី១៩ នៅប្រទេសអាល្លឺម៉ង់* ប៉ុន្តែពាក្យថា "***សន្តិសុខសង្គម***" ត្រូវបានគេប្រើដំបូងបំផុតនៅសហរដ្ឋអាមេរិក នៅក្នុងច្បាប់សន្តិសុខសង្គម (Social Security Act) ដែលបានអនុម័តនាថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៣៥ ក្រោមក្របខ័ណ្ឌនៃគោលនយោបាយកំណែទម្រង់សេដ្ឋកិច្ច និងសង្គមកិច្ចរបស់លោកប្រធានាធិបតី **ហ្វ្រង់គ្លីនរ៉ូសឺវែល**។ ក្រោយមកពាក្យនេះ ក៏ត្រូវបានសហប្រជាជាតិយកមកប្រើនៅក្នុងសេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្សនៅឆ្នាំ១៩៤៨ ដែលចែងថា " *មនុស្សគ្រប់រូបក្នុងឋានៈខ្លួនជាសមាជិកសង្គម ត្រូវមានសិទ្ធិខាងសន្តិសុខសង្គម*"។ បន្ទាប់ពីនោះមក ពាក្យសន្តិសុខសង្គមត្រូវបានគេប្រើប្រាស់ជាទូទៅនៅក្នុងបណ្តាប្រទេសនានា ជាពិសេសប្រទេសដែលមានការរីកចម្រើនជឿនលឿនខាងឧស្សាហកម្ម សម្រាប់សម្គាល់នូវសំណុំវិធានការសាធារណៈ ក្នុងការដោះស្រាយបញ្ហាទុក្ខលំបាករបស់ប្រជាពលរដ្ឋ នៅពេលដែលជួបប្រទះហានិភ័យសង្គមជាយថាហេតុផ្សេងៗ។

និយមន័យនៃសន្តិសុខសង្គម មានលក្ខណៈផ្សេងៗពីគ្នារវាងប្រទេសនានានៅក្នុងសាកលលោក ប៉ុន្តែក្នុងនោះមានបង្កប់នូវចំណុចរួមមួយ ដែលនោះគឺជាវិធានការជួយសម្រាលបន្ទុកក្នុងគ្រាដែលជនណាម្នាក់នៅក្នុងសង្គមបានបាត់បង់ ឬថយចុះនូវប្រាក់ចំណូល ពុំអាចមានលទ្ធភាពទ្រទ្រង់ជីវភាពក្នុងគ្រួសារបាន។

ក្នុងគោលដៅផ្តល់នូវបទដ្ឋានសម្រាប់ការអនុវត្តរបស់រដ្ឋជាសមាជិក អង្គការអន្តរជាតិខាងការងារ (ILO) តាមរយៈសន្និសីទសាកលរបស់ខ្លួនបានអនុម័តនូវអនុសញ្ញា និងអនុសាសន៍មួយចំនួនទាក់ទងដល់បទដ្ឋានសន្តិសុខសង្គម ដែលក្នុងនោះមានអនុសញ្ញាលេខ ១០២ ស្តីពីបទដ្ឋានអប្បបរមានៃសន្តិសុខសង្គម។ អនុសញ្ញានេះបានកំណត់វិសាលគម និងតាវកាលិកអប្បបរមាក្នុងចំណោមតាវកាលិកទាំងអស់ចំនួន០៩ គឺ *ការថែទាំ និងព្យាបាល ជំងឺ និកម្មភាព ជរាភាព គ្រោះថ្នាក់ការងារ បន្ទុកគ្រួសារ មាតុភាព ទុព្វលភាព និងតាវកាលិកឧត្តរជីវី* ដែលរដ្ឋជាសមាជិកនានា គប្បីធានាឲ្យមាននៅក្នុងគោលនយោបាយសន្តិសុខសង្គមរបស់ខ្លួន។ អនុលោមតាមន័យខាងលើ យើងអាចកំណត់បាននូវគោលបំណងបីធំៗនៃសន្តិសុខសង្គមគឺ៖

-ទី១ ការធានាចំពោះតម្រូវការចាំបាច់ក្នុងការថែទាំសុខភាព

-ទី២ ការធានាចំពោះតម្រូវការចាំបាច់ នៅពេលបាត់បង់ប្រាក់ចំណូលដោយសារហានិភ័យនានា

-ទី៣ ការធានាចំពោះតម្រូវការចាំបាច់នៅពេលបន្ទុកគ្រួសារកើនឡើង។

*សរុបសេចក្តីមកសន្តិសុខសង្គម គឺជាវិធានការគតិយុត្តចាំបាច់នានាដែលរដ្ឋ ឬរដ្ឋាភិបាលត្រូវចាត់ ដើម្បីការពារចំពោះពលរដ្ឋរបស់ខ្លួនណា ដែលមិនមានលទ្ធភាពរកបានប្រាក់ចំណូល ឬដែលកំពុងប្រឈមនឹងការទទួលខុសត្រូវខាងហិរញ្ញវត្ថុ ទោះជាដោយបណ្តោះអាសន្ន ឬដោយអចិន្ត្រៃយ៍ក្តី ដោយសារហានិភ័យសង្គម ដើម្បីឲ្យពួកគេមានលទ្ធភាពដោះស្រាយជីវភាពរស់នៅជាចាំបាច់ តាមរយៈការផ្តល់នូវធនធានខាងហិរញ្ញវត្ថុ ឬវត្ថុប្រើប្រាស់ចាំបាច់ ឬក៏ការផ្តល់សេវាកម្មផ្សេងៗជាដើម។*

## ២. ប្រវត្តិសន្តិសុខសង្គម និងការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) នៅកម្ពុជា

ក្រោយទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ កម្ពុជាបានចេញព្រះរាជក្រមលេខ៣ នស ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៥៥ ពាក់ព័ន្ធនឹងសិទ្ធិរបស់កម្មករនិយោជិត ក្នុងការទទួលបាននូវប្រាក់ឧបត្ថម្ភសម្រាប់ប្រពន្ធ និងកូន ដែលនេះអាចចាត់ទុកជាការចាប់ផ្តើមឡើង នៃប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា។ ជាការគួរឲ្យសោកស្តាយ ប្រព័ន្ធសន្តិសុខសង្គមកម្ពុជា ត្រូវបានបំផ្លិចបំផ្លាញចោលទៅវិញក្រោមរបបកម្ពុជាប្រជាធិបតេយ្យនៅកំឡុងឆ្នាំ១៩៧៥-១៩៧៩។ ចាប់ពីឆ្នាំ១៩៧៩ មក កម្មករនិយោជិតទាំងអស់ទទួលបានការគាំពារផ្នែកសោធននិវត្តន៍ ទុព្វលភាព មរណភាព និងគ្រោះថ្នាក់ការងារ។ នៅឆ្នាំ១៩៨៩ ដោយសារមានកំណែទម្រង់ពីសេដ្ឋកិច្ចផែនការ មកសេដ្ឋកិច្ចទីផ្សារ ប្រព័ន្ធសន្តិសុខសង្គមសម្រាប់កម្មករនិយោជិតផ្នែកឯកជនត្រូវបានកែសម្រួល ស្របតាមស្ថានភាពសេដ្ឋកិច្ចជាក់ស្តែងតាមរយៈច្បាប់ការងារឆ្នាំ១៩៩២ ដែលបានតម្រូវឲ្យនិយោជកជាអ្នកទទួលបន្ទុកលើគ្រោះថ្នាក់ការងារដែលកើតឡើងជាយថាហេតុចំពោះកម្មករនិយោជិតរបស់ខ្លួន។ នៅឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើត។ រីឯច្បាប់ការងារឆ្នាំ១៩៩២ ត្រូវបានផ្លាស់ជំនួសដោយច្បាប់ស្តីពីការងារនៅឆ្នាំ១៩៩៧។ នៅឆ្នាំ២០០២ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវបានប្រកាសឲ្យប្រើ។

ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ មានគោលបំណងបង្កើតឲ្យមានរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមមានផ្នែកប្រាក់សោធន ផ្នែកហានិភ័យការងារ និងផ្នែកផ្សេងៗទៀត ផ្អែកតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចជាតិ។ ដោយយោងទៅលើស្ថានភាពអភិវឌ្ឍន៍នៃសេដ្ឋកិច្ចជាតិ និងដើម្បីឆ្លើយតបទៅនឹងការរីកចំរើននៃវិស័យការងារ អតីតនាយកដ្ឋានសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលពេលនោះមានភារកិច្ចចម្បងពីរ គឺ ១. ការអនុវត្តច្បាប់ស្តីពីការងារពាក់ព័ន្ធនឹងបញ្ហាគ្រោះថ្នាក់ការងារ និង ២. ការរៀបចំច្បាប់ស្តីពីរបបសន្តិសុខសង្គម បានខិតខំប្រឹងប្រែងយ៉ាងសកម្មសិក្សាស្រាវជ្រាវ និងចងក្រងនូវលិខិតូបករណ៍គតិយុត្តជាច្រើន ដើម្បីឲ្យមានការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។

កិច្ចខិតខំប្រឹងប្រែងនេះ បានសម្រេចលទ្ធផលជាផ្លែផ្កាដោយបេឡាជាតិរបបសន្តិសុខសង្គម ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល មានបេសកកម្មបម្រើសេវាសាធារណៈមានលក្ខណៈសង្គម ហៅកាត់ថា (ប.ស.ស) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៧។ ប.ស.ស គឺជានីតិបុគ្គលសាធារណៈ ដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពត្រីភាគី គឺភាគីតំណាងរាជរដ្ឋាភិបាល ភាគីតំណាងនិយោជក និងភាគីតំណាងកម្មករនិយោជិត។

ក្នុងឆ្នាំ២០០៧ នេះដែរ ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម ត្រូវបានបង្កើតឡើង ហើយជាបន្តបន្ទាប់រហូតមកប្រកាស និងសេចក្តីសម្រេចជាច្រើនទាក់ទងនឹង ដំណើរការបេឡាជាតិរបបសន្តិសុខសង្គម ក៏ដូចជារបបធានារ៉ាប់រងហានិភ័យការងារ ត្រូវបានដាក់ឲ្យក្រុមប្រឹក្សាភិបាលប្រជុំពិភាក្សា និងស្នើសុំសេចក្តីសម្រេច ពីក្រសួងអាណាព្យាបាល និងក្រសួងពាក់ព័ន្ធ។ រហូតមកដល់ខែវិច្ឆិកា ឆ្នាំ២០០៨ បេឡាជាតិរបបសន្តិសុខសង្គម បានចាប់ផ្តើមដំណើរការជំហានទី១ របស់ខ្លួន គឺរបបធានារ៉ាប់រងហានិភ័យការងារដោយជោគជ័យ។

## ៣. រចនាសម្ព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម



# ជំពូកទី ២
# ច្បាប់ និងឯកសារគតិយុត្ត

## ១. បទដ្ឋានជាតិ និងអន្តរជាតិ

### ១.១. បទដ្ឋានជាតិ

***រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣*** គឺជាច្បាប់កំពូលរបស់ជាតិ និងជាបទប្បញ្ញត្តិសម្រាប់ការគាំពារសង្គម ចំពោះប្រជាពលរដ្ឋទូទៅនៅក្នុងប្រទេស ដោយមិនមានការរើសអើងនូវគ្រប់ទម្រង់ទាំងអស់ ដែលរួមបញ្ចូលនូវសិទ្ធិទទួលបានរបបសន្តិសុខសង្គម និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត។ ច្បាប់នេះក៏បានបង្កើតនូវបទប្បញ្ញត្តិពិសេស សម្រាប់ផ្នែកសន្តិសុខសង្គមនៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធចំពោះកម្មករនិយោជិតផងដែរ។

ជំពូកទី៣ អំពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ មាត្រា៣៦ វាក្យខ័ណ្ឌទី៤ បានចែងថា *"ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់"* ។

ជំពូកទី៦ អំពីអប់រំ វប្បធម៌ និងសង្គមកិច្ច មាត្រា៧៥ បានចែងថា *"រដ្ឋចាត់ចែងឲ្យមានរបបសន្តិសុខសង្គមដល់កម្មករ និងនិយោជិត"* ។

***ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧*** គ្រប់គ្រងរាល់ទំនាក់ទំនងវិជ្ជាជីវៈ ដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិត ដើម្បីធានាឲ្យមានលក្ខខណ្ឌការងារល្អប្រសើររក្សាបានភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ ពង្រឹងសុវត្ថិភាព និងសុខភាពការងារនៅនឹងកន្លែងធ្វើការ។ បន្ទាប់ពីរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការងារ ជាមូលដ្ឋានគ្រឹះនៃការបង្កើតច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលវាបានកំណត់អំពីនិយមន័យគ្រោះថ្នាក់ការងារ ការទទួលខុសត្រូវរបស់និយោជកចំពោះគ្រោះថ្នាក់ការងារ ដែលកើតឡើងលើកម្មករនិយោជិតរបស់ខ្លួន នូវការធានារ៉ាប់រងលើការពិនិត្យព្យាបាល ការផ្តល់ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍សង្គមមួយចំនួនទៀត ដូចមានចែងនៅក្នុង *ជំពូកទី៩ អំពីគ្រោះថ្នាក់ការងារ មាត្រា (២៤៨-២៥៧)*។ មួយវិញទៀត ច្បាប់នេះក៏បានកំណត់ថា ការធានារ៉ាប់រងគ្រោះថ្នាក់ការងារ ត្រូវស្ថិតនៅក្រោមរបបទូទៅមួយខាងការធានារ៉ាប់រងជាកាតព្វកិច្ច ដែលរបបនេះត្រូវប្រព្រឹត្តទៅក្រោមការធានារ៉ាប់រងរបស់បេឡាជាតិរបបសន្តិសុខសង្គម។

***ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារឆ្នាំ២០០២*** មានគោលបំណង បង្កើតឲ្យមានរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន៖

*១- ផ្នែកប្រាក់សោធន ដែលត្រូវទទួលបន្ទុកផ្តល់តាវកាលិកជរាភាព ទុព្វលភាព និងមរណភាព។*

*២- ផ្នែកហានិភ័យការងារ ដែលត្រូវទទួលបន្ទុកផ្តល់តាវកាលិកគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ។*

*ចំពោះផ្នែកផ្សេងៗទៀតនឹងត្រូវកំណត់ដោយអនុក្រឹត្យជាបន្តបន្ទាប់ ដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចជាតិ។*

***អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម*** បង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាសាធារណៈមានលក្ខណៈសង្គម មានឈ្មោះថា "បេឡាជាតិរបបសន្តិសុខសង្គម" សរសេរជាអក្សរកាត់ "ប.ស.ស" ដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង អាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បេឡាជាតិរបបសន្តិសុខសង្គមមានភារកិច្ចៈ

- *គ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។*
- *ធានាផ្តល់ឲ្យបានសមស្របនូវតាវកាលិកទាំងឡាយ សម្រាប់សមាជិកនៃ ប.ស.ស ក្នុងគោលដៅជួយសម្រួលការលំបាកនានានៅពេល ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ មាតុភាពជាដើម។*
- *ប្រមូលភាគទានពីសមាជិក ប.ស.ស និងនិយោជក។*
- *សម្របសម្រួល និងរៀបចំឲ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ច សម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន។*
- *សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីអប់រំផ្សព្វផ្សាយអំពីរបៀបបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ និងចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខ និងអនាម័យការងារ។*
- *សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីសិក្សាស្រាវជ្រាវ និងអង្កេតហានិភ័យការងារ។*
- *ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម។*

ក្រៅពីបទដ្ឋានខាងលើ ក៏នៅមានបទដ្ឋានគតិយុត្តមួយចំនួនទៀតរួមមាន *ប្រកាសអន្តរក្រសួង* ប្រកាស និងសេចក្តីសម្រេចជាច្រើនទាក់ទងនឹងដំណើរការនៃបេឡាជាតិរបបសន្តិសុខសង្គម អនុលោមតាមច្បាប់ស្តីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## ១.២. បទដ្ឋានអន្តរជាតិ

***សេចក្តីប្រកាសជាសាកលអំពីសិទ្ធិមនុស្ស*** គឺជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ដែលមនុស្សគ្រប់រូបមានសិទ្ធិក្នុងការចូលរួមសកម្មភាព ទទួលការការពារ និងទទួលអត្ថប្រយោជន៍ពីសង្គមស្មើគ្នាៗ ដោយមិនមានការរើសអើងនូវគ្រប់ទម្រង់ទាំងអស់។

*- មាត្រា ២២ "មនុស្សគ្រប់រូបដែលជាសមាជិកសង្គម មានសិទ្ធិលើផ្នែកសន្តិសុខសង្គម... ស្របតាមស្ថានភាពធនធាននៃប្រទេសនីមួយៗ"។*

- *មាត្រា ២៥ "មនុស្សគ្រប់រូបមានសិទ្ធិទទួលបានកំរិតនៃការរស់នៅសមរម្យ ដើម្បីទ្រទ្រង់សុខភាព និងសុខុមាលភាពសម្រាប់ខ្លួនឯងផ្ទាល់ និងគ្រួសារ ដែលរួមមានអាហារ សម្លៀកបំពាក់ ទីជម្រក ការថែទាំសុខភាព ព្រមទាំងសេវាសង្គមនានា និងសិទ្ធិទទួលបានសន្តិសុខនៅពេលដែលគ្មានការងារធ្វើ មានជម្ងឺ ពិការភាព ការបែកបាក់គ្នា ចូលនិវត្តន៍ ឬក៏ការគ្មានសមត្ថភាពក្នុងការរកទទួលទានចិញ្ចឹមជីវិត"* ។

***សេចក្តីប្រកាសទីក្រុង* Philadelphia *ឆ្នាំ១៩៤៤*** ផ្តោតជាចម្បងទៅលើទិសដៅ និងគោលបំណងរបស់អង្គការអន្តរជាតិខាងការងារ ILO ដោយវាបានទទួលស្គាល់នូវកាតព្វកិច្ចដ៏ធំធេងរបស់អង្គការនេះ ចំពោះប្រជាជាតិទាំងអស់ សម្រាប់កម្មវិធីរបស់ពិភពលោកដែលត្រូវសម្រេចឲ្យបាននូវ៖

- *ការពង្រីកវិធានការផ្នែកសន្តិសុខសង្គម ដើម្បីផ្តល់នូវមូលដ្ឋានគ្រឹះនៃប្រាក់ចំណូល ចំពោះតម្រូវការនូវការការពារ និងការថែទាំសុខភាពដ៏ទូលំទូលាយមួយ។*
- *ការការពារអាយុជីវិត និងសុខភាពកម្មករនៅគ្រប់វិជ្ជាជីវៈទាំងអស់។*
- *ការផ្តល់ការការពារសុខុមាលភាពកុមារ និងមាតុភាព ។*

***សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN)*** មានគោលដៅជំរុញឲ្យមានការអភិវឌ្ឍរួមគ្នាលើគ្រប់វិស័យរវាងបណ្តាប្រទេសជាសមាជិក ដើម្បីសម្រេចឲ្យបាននូវសហគមន៍អាស៊ានតែមួយ អត្តសញ្ញាណតែមួយ និងចក្ខុវិស័យតែមួយ។ ទាក់ទងនឹងវិស័យសន្តិសុខសង្គម សមាគមនេះបានចេញនូវសេចក្តីប្រកាស ក៏ដូចជាសេចក្តីថ្លែងការណ៍រួម និងផែនការការងារមួយចំនួនរួមមាន៖

- ផែនការសហគមន៍អាស៊ានឆ្នាំ២០១៥ ដែលផ្តោតសំខាន់ទៅលើសរសរស្តម្ភបីគឺ សហគមន៍នយោបាយ សន្តិសុខ សហគមន៍សេដ្ឋកិច្ច និងសហគមន៍សង្គមវប្បធម៌អាស៊ាន ដែលការគាំពារសង្គមត្រូវបានលើកឡើងជាអាទិភាព និងបានបញ្ចូលទៅក្នុងសរសរស្តម្ភទី៣ សហគមន៍សង្គមវប្បធម៌អាស៊ាន ក្នុងការរៀបចំប្រព័ន្ធសំណាញ់សុវត្ថិភាពសង្គម និងការការពារពីផលប៉ះពាល់អវិជ្ជមាននៃការធ្វើសមាហរណកម្ម និងសកលភាវូបនីយកម្ម រួមមានតាមរយៈការលើកកំពស់ការផ្លាស់ប្តូរបទពិសោធន៍នៅក្នុងប្រព័ន្ធសន្តិសុខសង្គម និងអភិវឌ្ឍស្តង់ដារសន្តិសុខសង្គមនៅក្នុងប្រទេសជាសមាជិក។

- សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលបានធ្វើការប្តេជ្ញាចិត្តបន្ថែមទៀត ទៅលើសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសទីក្រុងវីយែន និងកម្មវិធីនៃសកម្មភាព និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដទៃទៀតដែលប្រទេសសមាជិកអាស៊ានជារដ្ឋភាគី ដោយនៅក្នុងគោលការណ៍រួមទី៣០.១ *"មនុស្សគ្រប់រូបត្រូវមានសិទ្ធិផ្នែកសន្តិសុខសង្គម រួមទាំងការធានារ៉ាប់រងសង្គមដែលអាចទទួលបាន ដើម្បីជួយដល់ពួកគេក្នុងការធានានូវមធ្យោបាយសម្រាប់ការរស់នៅដោយសេចក្តីថ្លៃថ្នូរ និងសមរម្យ"*។

- សេចក្តីថ្លែងការណ៍រួមកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានបូក៣ លើកទី៧ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ ក្រុងភ្នំពេញ ប្រទេសកម្ពុជា រវាងរដ្ឋមន្ត្រីការងារអាស៊ាន និងសមភាគីមកពីសាធារណៈរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន និងសាធារណៈរដ្ឋកូរ៉េ សម្រាប់កិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរទស្សនៈ ដែលបានផ្តោតជាសំខាន់លើបញ្ហាដែលទាក់ទងទៅនឹងការខិតខំប្រឹងប្រែងធ្វើឲ្យប្រសើរឡើងនូវការគាំពារសង្គម និងការអភិវឌ្ឍជំនាញ។

ក្រៅពីមូលដ្ឋានខាងលើ ក៏នៅមានមូលដ្ឋានមួយចំនួនទៀតទាក់ទងនឹងផ្នែកសន្តិសុខសង្គម ដែលប្រទេសជាសមាជិកអាស៊ាន បានព្រមព្រៀងគ្នា រួមមានផែនការសកម្មភាពអាស៊ានស្តីពីសំណាញ់សុវត្ថិភាពសង្គម សេចក្តីប្រកាសកោះបាលីស្តីពីការធ្វើឲ្យប្រសើរឡើងនូវតួនាទី និងការចូលរួម នៃជនពិការនៅក្នុងសហគមន៍អាស៊ាន និងជាពិសេសនៅរាល់កិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ាន ដែលតែងតែបានលើកឡើងពីការអភិវឌ្ឍគុណភាពនៃកំលាំងពលកម្ម និងការផ្តល់ការធានាសន្តិសុខសង្គមដល់កម្មករនិយោជិត។

**សមាគមសន្តិសុខសង្គមអាស៊ាន (ASSA)** ជាអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវវេទិកាសម្រាប់ស្ថាប័នជាសមាជិក នៅក្នុងការផ្លាស់ប្តូរទស្សនៈ និងបទពិសោធន៍លើបញ្ហាសន្តិសុខសង្គម។ សមាជិកនៅក្នុងសមាគមនេះ រួមមានស្ថាប័នសន្តិសុខសង្គមទាំងឡាយនៅក្នុងបណ្តាប្រទេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ដែលក្នុងនោះបេឡាជាតិរបបសន្តិសុខសង្គម នៃព្រះរាជាណាចក្រកម្ពុជាក៏ជាសមាជិកមួយផងដែរ។ គោលបំណងចម្បងរបស់សមាគមនេះគឺដើម្បី៖

- លើកកម្ពស់ការអភិវឌ្ឍនៃវិស័យសន្តិសុខសង្គមនៅក្នុងតំបន់ស្របតាមគោលបំណង ច្បាប់ និងបទប្បញ្ញត្តិនៃបណ្តាប្រទេសជាសមាជិក
- លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងតំបន់នៅគ្រប់ផ្នែកទាំងអស់នៃសកម្មភាពសន្តិសុខសង្គម
- ផ្លាស់ប្តូរបទពិសោធន៍ និងព័ត៌មានស្តីពីសន្តិសុខសង្គម
- ធ្វើការនៅក្នុងកិច្ចសហប្រតិបត្តិការ ជាមួយស្ថាប័នសន្តិសុខសង្គមផ្សេងទៀតនៅក្នុងតំបន់នៅអាស៊ីប៉ូពាំ និងជាមួយអង្គការសន្តិសុខសង្គមដទៃទៀតនៅទូទាំងពិភពលោក
- ធ្វើកិច្ចសហប្រតិបត្តិការក្នុងការការពារ ការលើកកម្ពស់ និងការអភិវឌ្ឍរបបសន្តិសុខសង្គមតាមរយៈការបណ្តុះបណ្តាល សិក្ខាសាលា ការពិគ្រោះយោបល់ និងការពិភាក្សា។

***អនុសញ្ញាលេខ ១០២ របស់អង្គការពលកម្មអន្តរជាតិ*** បានកំណត់អំពីគ្រោងការ នៃសារៈសំខាន់រួមលើគោលការណ៍គ្រឹះសន្តិសុខសង្គម ដែលប្រព័ន្ធសន្តិសុខសង្គមទាំងឡាយ គួរតែត្រូវបានលើកកំពស់ឲ្យមានការអភិវឌ្ឍដ៏ទូលំទូលាយបំផុត។ អនុសញ្ញាលេខ១០២ ជាអនុសញ្ញាមូលដ្ឋានគ្រឹះផ្នែកសន្តិសុខសង្គមដែលមានសារៈសំខាន់បំផុត សម្រាប់ប្រទេសជាសមាជិករបស់អង្គការ ILO ទាំងអស់ ដែលតំណាងឲ្យការទទួលស្គាល់ជាអន្តរជាតិ និងត្រូវបានទទួលស្គាល់ជានិមិត្តរូបមួយ ដោយវាដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញបន្ថែមនូវសិទ្ធិផ្នែកសន្តិសុខសង្គម ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ វាគឺជាអនុសញ្ញាអន្តរជាតិតែមួយគត់ ដែលបានកំណត់ពីតាវកាលិកទាំងប្រាំបួននៃសន្តិសុខសង្គម និងកំណត់ស្តង់ដារអតិបរមាសម្រាប់ផ្នែកនីមួយៗ ដែលរួមមាន៖ *១.ការថែទាំវេជ្ជសាស្ត្រ ២.ជំងឺ ៣.និកម្មភាព ៤.ជរាភាព ៥.គ្រោះថ្នាក់ការងារ ៦.គ្រួសារ ៧.មាតុភាព ៨.ទុព្វលភាព និង ៩.ឧត្តរជីវី។*

ក្រៅពីបទដ្ឋានខាងលើ ក៏នៅមានបទដ្ឋានអន្តរជាតិមួយចំនួនទៀត ដែលទាក់ទងទៅនឹងផ្នែកសន្តិសុខសង្គមដែលត្រូវបានអភិវឌ្ឍ និងរៀបចំឡើងតាមរយៈការពិភាក្សា និងទទួលស្គាល់ជាសកលដែលសន្តិសុខសង្គមជាសិទ្ធិគ្រឹះនៅក្នុងសង្គមដែលមនុស្សគ្រប់រូបត្រូវទទួលបាន ដូចមាននៅក្នុងបទដ្ឋានគតិយុត្តមួយចំនួនដែលបានទទួលស្គាល់ជាអន្តរជាតិរួមមាន៖

*១- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌*
*២- អនុសញ្ញាស្តីពីសិទ្ធិរបស់កុមារ*
*៣- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការប្រកាន់ពូជសាសន៍*
*៤- អនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ*
*៥- អនុសញ្ញាលេខ១២១ ស្តីពីតាវកាលិកគ្រោះថ្នាក់ការងារ*
*៦- អនុសញ្ញាលេខ១២៨ ស្តីពីតាវកាលិកទុព្វលភាព ជរាភាព និងឧត្តរជីវី*
*៧- អនុសញ្ញាលេខ១៣០ ស្តីពីតាវកាលិកព្យាបាល និងជំងឺ។*

## ២. ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

ផ្តើមចេញពីនយោបាយ " ឈ្នះ - ឈ្នះ " របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសជាតិដែលកន្លងមកធ្លាប់ទទួលរងនូវភាពខ្ទេចខ្ទាំដោយសារសង្គ្រាមស៊ីវិល និងវិបត្តិនយោបាយជាបន្តបន្ទាប់ បានទទួលនូវសុខសន្តិភាព និងឯកភាពទឹកដីដ៏ពេញលេញ ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ដោយសារស្ថិរភាពនយោបាយ និងសន្តិភាពនេះហើយ ដែលនាំឲ្យកម្ពុជាអនុវត្តនូវកិច្ចការកែទម្រង់លើគ្រប់វិស័យសំដៅកសាងធនធានមនុស្ស អភិវឌ្ឍសមត្ថភាពស្ថាប័ន ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច និងបង្កើតបរិយាកាសល្អ ដល់ការទាក់ទាញការវិនិយោគទាំងក្នុង និងក្រៅប្រទេស សំដៅធានាបាននូវកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ។

នៅក្នុងវិស័យសន្តិសុខសង្គម រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងឆ្ពោះទៅរកការពង្រីកការគាំពារសង្គមដ៏ទូលំទូលាយមួយ ដូចមាននៅក្នុងផែនការយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនខាងក្រោម៖

### ២.១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងទី២

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងទី២ ជារបៀបវារៈគោលនយោបាយសង្គមសេដ្ឋកិច្ច នៃកម្មវិធីនយោបាយសម្រាប់នីតិកាលទី៣ និងទី៤ នៃរដ្ឋសភារបស់រាជរដ្ឋាភិបាលកម្ពុជា **ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** សំដៅដល់ការលើកស្ទួយវិស័យកសិកម្ម, ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ការអភិវឌ្ឍវិស័យឯកជន និងការងារ និងការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស តាមរយៈការអនុវត្តសួលអភិបាលកិច្ចល្អ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ, កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ រួមទាំងបរិស្ថានគ្របដណ្តប់នៃសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម, សមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក, ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ និងបរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ។ នៅក្នុងយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលកម្ពុជា មានគោលបំណងធ្វើឲ្យប្រសើរឡើងនូវការជួយអន្តរាគមន៍ផ្នែកសង្គម តាមរយៈការធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចល្អ, ការអភិវឌ្ឍការងារ, ការផ្តល់កម្មវិធីសំណាញ់សុវត្ថិភាពសង្គមសម្រាប់ប្រជាពលរដ្ឋទូទៅ, សម្រាប់មន្ត្រីរាជការស៊ីវិល និងសម្រាប់កម្មករនិយោជិត *"មុំទី៣ ការអភិវឌ្ឍផ្នែកឯកជន និងការងារ ចំនុចទី៤ ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម"* ដែលបានបង្ហាញឲ្យ

ឃើញពីឆន្ទៈដ៏ច្បាស់លាស់របស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ លើកកំពស់ស្ថិរភាពសង្គម និងភាពសុខុដុមរមនារបស់ប្រជាពលរដ្ឋ។

*រូបភាពទី១៖ គំនូសបំព្រួញយុទ្ធសាស្ត្រចតុកោណ*




*ប្រភព៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២*

## ២.២. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ជាផែនទីចង្អុលផ្លូវសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដែលផែនការនេះ ត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រដែលមានលក្ខណៈច្បាស់លាស់ ដោយបានកំណត់នូវក្រសួងស្ថាប័ន ដែលជាអ្នកទទួលខុសត្រូវអនុវត្តគោលនយោបាយជាអាទិភាពទាំងឡាយក្នុងមុំនីមួយៗ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងបានកំណត់ពីសកម្មភាពជាក់លាក់ និងតម្លៃប៉ាន់ស្មាន ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយ។ មួយវិញទៀតវាក៏ត្រូវបានរៀបចំឡើង ដោយមានធាតុចូលពីក្រសួង ស្ថាប័ននីមួយៗរបស់រាជរដ្ឋាភិបាល និងដោយមានការពិគ្រោះយោបល់ជាមួយតួអង្គដែលមានចំណែកពាក់ព័ន្ធផងដែរ។ នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍជាតិ បានបញ្ជាក់យ៉ាងច្បាស់នៅត្រង់ជំពូកទី៤ ចំណុចទី*៥.៤. ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ចរៀបចំដំណើរការការងារ និងគ្រប់គ្រងប្រព័ន្ធសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានតួនាទីអភិវឌ្ឍ និងរៀបចំគ្រប់គ្រងរបបសន្តិសុខសង្គម សម្រាប់ផ្នែកមន្ត្រីរាជការស៊ីវិល។* ដូចនេះនៅពេលដែលប្រព័ន្ធ

សន្តិសុខសង្គមទាំងពីរនេះ ត្រូវបានអនុវត្តពេញលេញនោះ ប្រព័ន្ធនេះនឹងផ្តល់មកនូវអត្ថប្រយោជន៍ជាច្រើនដល់កម្មករនិយោជិត និងមន្ត្រីដែលចូលនិវត្តន៍ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ការសម្រាក មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកក្នុងបន្ទុក។

## ២.៣. យុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (២០១១-២០១៥)

យុទ្ធសាស្រ្តនេះ ត្រូវបានសម្របសម្រួល និងរៀបចំដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ) ដោយមានការចូលរួមពីផ្នែកដែលពាក់ព័ន្ធទាំងឡាយ រួមមានតំណាងរដ្ឋាភិបាលនៅកំរិតថ្នាក់ជាតិ និងក្រោមជាតិ តំណាងសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា។ យុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ត្រូវបានរៀបចំឡើង និងអនុវត្តនូវសកម្មភាពជាអាទិភាពដែលបានលើកឡើងនៅក្នុងយុទ្ធសាស្រ្តចតុកោណ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ ២០០៩-២០១៣ និងបំពេញបន្ថែមនូវគោលនយោបាយ ផែនការ និងយុទ្ធសាស្រ្តទាំងឡាយរបស់ក្រសួងពាក់ព័ន្ធ ដែលទាក់ទងដោយផ្ទាល់ ឬដោយប្រយោលចំពោះការគាំពារសង្គម។ យុទ្ធសាស្រ្តនេះមានលក្ខណៈទូលាយ និងបានរួមបញ្ចូលនូវប្រព័ន្ធការពារសង្គមដែលជាអត្ថប្រយោជន៍សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ និងបានកំណត់នូវគោលនយោបាយសំខាន់ៗ ដើម្បីឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ ដោយវាបានលើកឡើងអំពីអាទិភាព នៃការការពារសង្គមរបស់រាជរដ្ឋាភិបាល ពីស្ថានភាពក្រីក្រ ភាពងាយរងគ្រោះ គោលនយោបាយគាំពារសង្គមនានា និងយុទ្ធសាស្រ្តគាំពារសង្គមរបស់កម្ពុជា *"ជំពូកទី២ ការគាំពារសង្គមគឺជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា"*។

*រូបភាពទី២៖ ដំណើរការជាលំដាប់ឆ្ពោះទៅកាន់ការគាំពារសង្គមដ៏ស៊ីជម្រៅ*




*ប្រភព៖ យុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (យ.ជ.គ.ស)*

### ២.៤. យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ (២០១១-២០២០)

យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ហៅកាត់ថា "យ.អ.វ.ហ ២០១១-២០២០" គឺជាឯកសារយុទ្ធសាស្ត្របច្ចុប្បន្នកម្ម ដើម្បីបន្តអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុមួយរឹងមាំ និងផ្អែកលើគោលការណ៍ទីផ្សារ ដែលបម្រើឲ្យការកៀរគរ និងបែងចែកធនធានប្រកបដោយប្រសិទ្ធភាព សំដៅរួមចំណែកគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ឯកសារយុទ្ធសាស្ត្រនេះ បានសម្របសម្រួលយុទ្ធសាស្ត្រ និងវដ្តនៃការរៀបចំផែនការសកម្មភាពអនុវិស័យនានា ស្របតាមទស្សនៈវិស័យរួមរយៈពេលវែង សម្រាប់វិស័យហិរញ្ញវត្ថុទាំងមូល។ មួយវិញទៀត វាក៏ផ្តោតផងដែរទៅលើតម្រូវការធ្វើសមាហរណកម្មហិរញ្ញវត្ថុក្នុងតំបន់អាស៊ាន ក្នុងនាមកម្ពុជាជាសមាជិកមួយនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន។ ផែនការយុទ្ធសាស្ត្រនេះរួមមាន០៦ ជំពូក បានលើកឡើងពីស្ថានភាពទូទៅនៃវិស័យហិរញ្ញវត្ថុ, វិស័យធនាគារ, វិស័យហិរញ្ញវត្ថុមិនមែនធនាគារ, អភិបាលកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ, ការកសាងសមត្ថភាព និងផែនការយុទ្ធសាស្ត្រ។

នៅជំពូកទី៣ ស្តីពីវិស័យហិរញ្ញវត្ថុមិនមែនធនាគារ បានលើកឡើងពីវិស័យធានារ៉ាប់រងសោធន និងទីផ្សារទុន។ ផ្នែកសោធន រដ្ឋាភិបាលបានបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស), បេឡាជាតិអតីតយុទ្ធជន (ប.ជ.អ), និង មូលនិធិជនពិការ (ម.ជ.ព) ផ្នែកទាំងអស់នេះស្ថិតនៅក្រោមការគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានអនុវត្តរបបសន្តិសុខសង្គមសម្រាប់វិស័យសាធារណៈ ហើយក្រសួងនេះក៏បាននឹងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ប្រជាពលរដ្ឋទូទៅនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ របបសោធនសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោម ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ អនុវត្តដោយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដែលនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបច្ចុប្បន្នបាននឹងកំពុងអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ។ ដោយឡែកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំពុងរៀបចំច្បាប់ស្តីពីការធានារ៉ាប់រង ដែលនឹងបង្កើតឲ្យមានសោធនស្ម័គ្រចិត្តពីផ្នែកឯកជន។

## ៣. ផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ឆ្នាំ២០០៩-២០១៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅក្នុងអាណត្តិទី៤ នេះបានខិតខំប្រឹងប្រែងយ៉ាងសកម្មអនុវត្តនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលដោយបានដាក់ចេញនូវផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ឆ្នាំ២០០៩-២០១៣ របស់ខ្លួននៅក្នុងការបង្កើតការងារ, ការធានាលក្ខខណ្ឌការងារល្អប្រសើរ, ការជំរុញការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម, ការអភិវឌ្ឍសមត្ថភាពជំនាញបច្ចេកទេស និងវិជ្ជាជីវៈជូនប្រជាពលរដ្ឋ

ការពង្រឹង និងពង្រីកការបញ្ជ្រាបយេនឌ័រក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការពង្រឹងស្ថាប័ន, ភាពជាដៃគូ, ប្រសិទ្ធភាពការងារ និងគណនេយ្យភាព។

តាមរយៈផែនការសកម្មភាពនេះក្រសួង សម្រេចបានលទ្ធផលការងារមួយចំនួន លើការធានាបានលក្ខខណ្ឌការងារល្អប្រសើរ រក្សាបានភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ ពង្រឹងសុវត្ថិភាព និងសុខភាពការងារនៅនឹងកន្លែងធ្វើការ ការពារទប់ស្កាត់ពលកម្មកុមារ ពង្រឹងគោលនយោបាយរកការងារឲ្យធ្វើទាំងក្នុង និងក្រៅប្រទេស ដល់ប្រជាជនកម្ពុជារាប់ម៉ឺននាក់ និងការបណ្តុះបណ្តាលវិជ្ជាជីវៈជូនប្រជាពលរដ្ឋ។

ទន្ទឹមនឹងការអនុវត្តច្បាប់ស្តីពីការងារ ការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ មានសារៈសំខាន់ណាស់ក្នុងការជំរុញការអនុវត្តច្បាប់ស្តីពីការងារ ឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀតនៅក្នុងការពង្រឹងសុវត្ថិភាព និងសុខុមាលភាពរបស់កម្មករនិយោជិត ដែលក្រសួងបានកំណត់ជាអាទិភាពទី៣ នៅក្នុងផែនការសកម្មភាពរយៈពេល០៥ ឆ្នាំរបស់ខ្លួន សម្រាប់ជំរុញការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលរួមមានផ្នែកធានារ៉ាប់រងហានិភ័យការងារ, ការធានារ៉ាប់រងសុខភាព និងផ្នែកប្រាក់សោធន ចំពោះកម្មករនិយោជិតក្នុងវិស័យឯកជន។

# ជំពូកទី ៣
# កត្តាកំណត់ និងស្ថានភាពផ្សេងៗ

## ១. កត្តាប្រជាសាស្ត្រ

យោងតាមលទ្ធផលចុងក្រោយ ជំរឿនទូទៅស្ថិតិប្រជាសាស្ត្រឆ្នាំ២០០៨ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ បានបង្ហាញឲ្យឃើញថា ព្រះរាជាណាចក្រកម្ពុជាមានប្រជារាស្ត្រចំនួន ១៣.៣៩៥.៦៨២ នាក់ ប្រុសមានចំនួន ៦.៥១៦.០៥៤ នាក់ (៤៨,៦៤ ភាគរយ) ស្រីចំនួន ៦.៨៧៩.៦២៨ នាក់ (៥១,៣៦ ភាគរយ) ក្នុងនោះប្រជារាស្ត្ររស់នៅទីក្រុងចំនួន ២.៦១៤.០២៧ នាក់ និងនៅជនបទចំនួន ១០.៧៨១.៦៥៥ នាក់។ អាយុមធ្យមរបស់បុរសមាន ៦០,៥ ឆ្នាំ និងស្ត្រីមាន ៦៤,៣ ឆ្នាំ។ ដង់ស៊ីតេប្រជារាស្ត្រ ៧៥ នាក់ ក្នុងមួយគីឡូម៉ែត្រទ្វេគុណ និងអត្រាកំណើនប្រចាំឆ្នាំ ១,៥៤ ភាគរយ។ អត្រាមរណភាពរបស់ទារកមានចំនួន ៦០ នាក់ក្នុង ១.០០០ ទារក និងអត្រាមរណភាពមាតានៅពេលសំរាលកូនមានចំនួន ៤៦១ នាក់ ក្នុង១០០.០០០ នាក់ នៅពេលផ្តល់កំណើត។ យោងតាមការប៉ាន់ស្មាននៅឆ្នាំ១៩៩៨ ប្រជាជនពិភពលោកទាំងអស់មានចំនួន ៦,៧ ពាន់លាននាក់ ក្នុងនោះប្រមាណ ៨,៦ ភាគរយ រស់នៅតំបន់អាស៊ីអាគ្នេយ៍ ដែលប្រជារាស្ត្រកម្ពុជាមានចំនួន ២,៣ ភាគរយ។ យោងតាមជំរឿនសហគ្រាស នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការផងដែរ ប្រជារាស្ត្រព្យាករណ៍ឆ្នាំ២០១១ មានចំនួនរហូតដល់ ១៤.៥២១.២៧៥ នាក់។

កុមារដែលស្ថិតនៅចន្លោះក្រុមអាយុពី (០-១៤) ឆ្នាំ មានចំនួន ៣៣,៧ ភាគរយ ក្រុមអាយុក្នុងសកម្មភាពសេដ្ឋកិច្ចពី(១៥-៦៤) ឆ្នាំ មានចំនួន ៦២ ភាគរយ និងក្រុមអាយុប្រជាជនវ័យចំណាស់ពី (៦៥+) ឆ្នាំ មានចំនួន ៤,៣ ភាគរយ។ ប្រជារាស្ត្រកម្ពុជាដែលមានអាយុវ័យក្មេងមានចំនួនច្រើនហាក់បានវិវដ្តមកដល់វ័យកណ្តាល និងដំណាក់កាលចុងក្រោយនឹងមកដល់កម្រិតអាយុវ័យចំណាស់។ មួយវិញទៀតអត្រាអាយុក្នុងបន្ទុក នៃប្រជារាស្ត្រកម្ពុជា បានបង្ហាញនូវនិន្នាការធ្លាក់ចុះក្នុងរយៈពេលពីឆ្នាំ១៩៩៨ ដែលមាន ៨៦,១៥ ភាគរយ ដល់ឆ្នាំ២០០៨ មានតែ ៦១,១៩ ភាគរយ គឺធ្លាក់ចុះ ២៤,៩៦ ភាគរយ។

អ្នកចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចសរុបមាន ៤៨,៨៤ ភាគរយ ជាបុរស និងស្ត្រី ៥១,១៦ ភាគរយ នៅប្រទេសកម្ពុជា។ អត្រាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច នៅថ្នាក់ជាតិសម្រាប់មនុស្ស ៧ ឆ្នាំឡើង បានកើនឡើងក្នុងទសវត្សរ៍ឆ្នាំ១៩៩៨-២០០៨ ចាប់ពី ៥៥,៥ ភាគរយ ទៅ ៦១,៧ ភាគរយ ដែលអត្រានេះនៅជនបទមានកំរិតខ្ពស់ជាងនៅទីប្រជុំជន គិតទាំងបុរស និងស្ត្រី។ អត្រាភាពគ្មានការងារធ្វើនៅប្រទេសកម្ពុជាបានបង្ហាញនូវការធ្លាក់ចុះចាប់ពី ៥,៣ ភាគរយ មកនៅ ១,៧ ភាគរយ ចាប់ពីឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ២០០៨។ តាមការវិភាគទៅលើភាពមានការងារធ្វើបានបង្ហាញផងដែរថា ទាំងអ្នកធ្វើការឲ្យគ្រួសារដោយគ្មានប្រាក់កំរៃ និងអ្នកធ្វើការងារដោយទុនផ្ទាល់ខ្លួន គឺមានប្រហែល៨៣ ភាគរយ នៃមនុស្សដែលមានការងារធ្វើទាំងអស់នៅទូទាំងប្រទេស ដែលវាបានចង្អុល

បង្ហាញឲ្យឃើញថា ភាគច្រើននៃអ្នកមានការងារធ្វើនៅកម្ពុជា គឺស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬវិស័យសេដ្ឋកិច្ចមិនរៀបរយ។ មួយវិញទៀតភាគរយ នៃប្រជារាស្ត្រមានការងារធ្វើបែងចែកតាមវិស័យមាន ៧២,៣ ភាគរយ ធ្វើការក្នុងវិស័យទី១ បន្ទាប់មកមាន ៨,៥ ភាគរយធ្វើការក្នុងវិស័យទី២ និង ១៩,២ ភាគរយ ធ្វើការក្នុងវិស័យទី៣។

នៅប្រទេសកម្ពុជាមានមនុស្សពិការចំនួន ១៩២.៥៣៨ នាក់ ដែលក្នុងនោះ ៥៦,៣ ភាគរយជាបុរស និង ៤៣,៧ ភាគរយជាស្ត្រី ដែលមនុស្សពិការមាន ១,៤៤ ភាគរយ នៃប្រជារាស្ត្រទាំងអស់។ ក្នុងចំណោមមនុស្សពិការនៅក្នុងប្រទេសទាំងមូលមាន ៣២ ភាគរយ ជាមនុស្សពិការពីកំណើត បន្ទាប់ពីនេះច្រើនទៀតគឺពិការក្រោយកំណើតដែលរួមមានរងគ្រោះដោយសារសង្គ្រាម គ្រាប់មីន និងគ្រោះថ្នាក់ផ្សេងៗទៀត។ អត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចនៃមនុស្សពិការមាន ១,២៨ ភាគរយ នៅក្នុងក្រុមអាយុធ្វើការងារ ១៥-៦៤ ឆ្នាំ។

ទំហំគ្រួសារគិតជាមធ្យមក្នុងមួយគ្រួសារបានថយចុះពី ៥,២ នាក់ ក្នុងឆ្នាំ១៩៩៨ មកនៅត្រឹម ៤,៧ នាក់ ក្នុងឆ្នាំ២០០៨ នៅកម្រិតថ្នាក់ជាតិ។ ភាគរយស្ត្រីជាមេគ្រួសារ មានចំនួន ២៥,៦ ភាគរយ។ និន្នាការនៃការថយចុះទំហំគ្រួសារនេះ គឺដោយសារតែការកើនឡើងចំនួនគ្រួសារនៅក្នុងប្រទេស ដែលមានការផ្លាស់ប្តូរពីប្រព័ន្ធគ្រួសាររស់នៅរួមគ្នា ទៅជាគ្រួសារមានឪពុកម្តាយ និងកូន។

## ២. កត្តាម៉ាក្រូសេដ្ឋកិច្ច

ការបោះឆ្នោតសកលឆ្នាំ១៩៩៣ បាននាំមកនូវការអនុវត្តគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សេដ្ឋកិច្ចទីផ្សារ ការគោរពសិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ទន្ទឹមគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំឡើងនូវកម្មវិធីជាតិសម្រាប់នីតិសម្បទា និងអភិវឌ្ឍកម្ពុជានាឆ្នាំ ១៩៩៤ ផែនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ៥ ឆ្នាំលើកទី១ (១៩៩៦-២០០០) សម្រាប់កំណត់ចក្ខុវិស័យ នៃការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ ដោយផ្តោតជាសំខាន់លើស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងការកាត់បន្ថយភាពក្រីក្រ។ តាមរយៈនេះ កម្ពុជាសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងវឌ្ឍនៈភាពសេដ្ឋកិច្ចគួរឲ្យកត់សំគាល់ ក្នុងនោះកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំមានកម្រិត ៨,៤ ភាគរយ ក្នុងរវាងឆ្នាំ ១៩៩៤-២០០៦។

ក្នុងដំណាក់កាលពីឆ្នាំ២០០៤ ដល់ ២០០៧ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច មានអត្រាកំណើនមធ្យមប្រចាំឆ្នាំ សម្រេចបានលើស ១០ ភាគរយ កម្ពុជាបានស្ថិតនៅក្នុងចំណោមប្រទេស ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងពិភពលោក។ វិបត្តិសេដ្ឋកិច្ចពិភពលោកឆ្នាំ២០០៨ ការធ្លាក់ចុះនៃបរិស្ថានសេដ្ឋកិច្ចខាងក្រៅប្រទេសនៅឆ្នាំ២០០៩ បានជះឥទ្ធិពលមកលើសេដ្ឋកិច្ចកម្ពុជា ដែលធ្វើឲ្យអត្រាកំណើននៃផលិតផលក្នុងស្រុក GDP បានធ្លាក់ចុះក្នុងកំរិតទាបមួយដែលពុំធ្លាប់មានពីមុនមក។ ទោះបីដូច្នេះក្តី វិស័យជាច្រើនបានវិលត្រឡប់មករកសភាពដើមភ្លាមៗនៅឆ្នាំបន្ទាប់ ដោយសារការកើនឡើងនៃអំណាចទិញនៅតំបន់ជនបទ ការនាំចេញមានការកើនឡើងសារជាថ្មី ជាពិសេសរាជរដ្ឋាភិបាលកម្ពុជាបានបង្កើនចំណាយសាធារណៈ សម្រាប់ជំរុញតម្រូវការក្នុងស្រុក ដែលបានធ្វើឲ្យកំណើន

សេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១១ កន្លងទៅនេះ កើនឡើងបានចំនួន ៧,១ ភាគរយ បន្ទាប់ពីកើន ៦ ភាគរយ នៅឆ្នាំ២០១០។

*ក្រាហ្វិកទី១៖ សូចនាករម៉ាក្រូសេដ្ឋកិច្ច (GDP Growth Rate)*




*ប្រភព៖ សូចនាករម៉ាក្រូសេដ្ឋកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២២-២-២០១៣)*

សេដ្ឋកិច្ចកម្ពុជាបាននឹងកំពុងបង្ហាញនូវភាពមាំមួន ឆ្ពោះទៅរកគោលដៅគោលនយោបាយកំណើនប្រចាំឆ្នាំ ៧,០% តាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល។ កំណើនសម្រេចបាន ៧,៣% នៅឆ្នាំ២០១២ ហើយត្រូវបានព្យាករណ៍ថានឹងសម្រេចបានក្នុងរង្វង់ ៧,០% នៅឆ្នាំ ២០១៣ នេះ។ តម្លៃ ផ.ស.ស. (គិតតាមថ្លៃបច្ចុប្បន្ន) មានចំនួន ៥៦.៦១៧ ពាន់លានរៀល ឬប្រមាណ ១៤.០៣៨ លានដុល្លារអាមេរិក។ កំណើនសម្រាប់ឆ្នាំ ២០១២ នេះបានសម្រេចដោយកំណើនវិស័យកសិកម្មបានកើនឡើង ៤,៣% ដែលនៅក្នុងនោះវិស័យដំណាំបានកើនឡើង ៤,៩% និងវិស័យនេសាទបានកើនឡើង ៦,៧%។ ទន្ទឹមនឹងនេះដែរវិស័យឧស្សាហកម្ម សម្រាប់ឆ្នាំ ២០១២ បានកើនឡើង ៩,២% ដែលនៅក្នុងនោះវិស័យកាត់ដេរបានកើនឡើង ៦,៩% និងវិស័យសេវាកម្មបានកើនឡើង ៨,១% ដែលនៅក្នុងនោះវិស័យសណ្ឋាគារ និងភោជនីយដ្ឋានបានកើនឡើង ១២,៥% ។

## ៣. ស្ថានភាពសហគ្រាស គ្រឹះស្ថាន និងអ្នកចូលរួមការងារ

យោងតាមលទ្ធផលចុងក្រោយ ជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការឆ្នាំ២០១១ ព្រះរាជាណាចក្រកម្ពុជាមាន *៥០៥.១៤៣* សហគ្រាស អ្នកចូលរួមក្នុងការងារសរុបចំនួន *១.៦៧៦.២៦៣* នាក់ ក្នុងនោះអ្នកចូលរួមការងារភេទប្រុសចំនួន ៦៥០.១៧៩ នាក់ ស្មើនឹង ៣៨,៨ ភាគរយ និងអ្នកចូលរួមការងារភេទស្រី មានចំនួន ១.០២៦.០៨៤ នាក់ស្មើនឹង ៦១,២ ភាគរយ ដូចនេះអ្នកចូលរួមការងារជាស្ត្រីមានចំនួនច្រើនជាងបុរស។

បើប្រៀបធៀបទៅនឹងលទ្ធផល នៃការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេស ឆ្នាំ២០០៩ ចំនួនអ្នកចូលរួមការងារសរុបកើនឡើង ៩,៥ ភាគរយ ហើយអត្រាកំណើនប្រចាំឆ្នាំព្យាករណ៍មាន ៤,៥៤ ភាគរយ ចំណែកអត្រាកំណើនប្រជាជនព្យាករណ៍ប្រចាំឆ្នាំមាន ១,៥៤ ភាគរយ ដូចនេះអត្រាកំណើនអ្នកចូលរួមក្នុងការងារមានកំរិតខ្ពស់ជាងកំណើនប្រជាជន។ កំណើននេះបង្ហាញថាអ្នកចូលរួមការងារនៅក្នុងវិស័យទី១ បានផ្លាស់ប្តូរទៅរកវិស័យទី២ និងទី៣ ដែលចលនាផ្លាស់ប្តូរនេះ គឺជាលក្ខណៈពិសេសរួមមួយនៅក្នុងដំណើរការនៃការអភិវឌ្ឍជាតិផងដែរ។ យោងតាមលទ្ធផល នៃជំរឿននេះក៏បានបង្ហាញផងដែរ នូវស្ថានភាពសំខាន់ៗមួយចំនួនទាក់ទងនឹងស្ថានភាពសហគ្រាស គ្រឹះស្ថាន ស្ថានភាពអ្នកចូលរួម និងពិសេសទាក់ទងនឹងស្ថានភាពសេដ្ឋកិច្ចកម្ពុជា។

### ៣.១. ចំនួនសហគ្រាស និងចំនួនអ្នកចូលរួម

ចំនួនសហគ្រាស ដែលមានអ្នកធ្វើការពី០១ ទៅ ០២ នាក់ មានចំនួនប្រហែល ៨០ ភាគរយ នៃចំនួនសហគ្រាសសរុប។ ចំនួនសហគ្រាស ដែលមានអ្នកធ្វើការ ០១ នាក់ មានចំនួន ២២២ ពាន់សហគ្រាសស្មើនឹង ៤៤ ភាគរយ ហើយសហគ្រាសមានអ្នកធ្វើការ ០២ នាក់ មានចំនួន ១៧៦ ពាន់នាក់ស្មើនឹង ៣៤,៩ ភាគរយ។

ចំនួនសហគ្រាសមានអ្នកធ្វើការ ០៥ នាក់ ឬ ច្រើនជាងមានចំនួន ៤០ ពាន់សហគ្រាស ស្មើនឹង ៧,៨ ភាគរយ មានអ្នកចូលរួមការងារចំនួន ៨៧៩.០០០ នាក់ ហើយចំនួនសហគ្រាស ដែលមានអ្នកធ្វើការ ១០ នាក់ ឬ ច្រើនជាងមានចំនួន ១៣ ពាន់សហគ្រាសស្មើនឹង ២,៦ ភាគរយ មានអ្នកចូលរួមការងារចំនួន ៧១៦.០០០ នាក់ ចំណែកឯសហគ្រាសដែលមានអ្នកធ្វើការ ១០០ នាក់ ឬ ច្រើនជាងមានចំនួន ៧៨៧ សហគ្រាស ស្មើនឹង ០,២ ភាគរយ មានអ្នកចូលរួមការងារចំនួន ៤៥៤.០០០ នាក់ ហើយចំនួនសហគ្រាសដែលមានអ្នកធ្វើការ ១.០០០ នាក់ ឬ ច្រើនជាងមានចំនួន ១១៩ សហគ្រាស មានអ្នកចូលរួមការងារចំនួន ២៥៧.០០០ នាក់។ ដូចនេះអាចសន្និដ្ឋានបានថា សហគ្រាសខ្នាតធំមានចំណែកតូចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មួយវិញទៀតគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលដែលបាននឹងកំពុងលើកកំពស់ និងគាំទ្រដល់សហគ្រាសខ្នាតតូចបានជោគជ័យ។ *(ព័ត៌មានលំអិតដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី១.១ និង១.២)*

### ៣.២. ចំនួនសហគ្រាសបែងចែកតាមចំណាត់ថ្នាក់វិស័យស្តង់ដារអន្តរជាតិ

បើមើលពីចំនួនសហគ្រាស បែងចែកតាមផ្នែកនៃចំណាត់ថ្នាក់វិស័យស្តង់ដារអន្តរជាតិអាជីវកម្មលក់ដុំ លក់រាយ និងការជួសជុលយានយន្ត ទោចក្រយានយន្ត ដែលជាផ្នែកធំជាងគេបំផុតនៃចំណាត់ថ្នាក់វិស័យស្តង់ដារអន្តរជាតិ មានចំនួន២៨៩ ពាន់សហគ្រាស ស្មើនឹង ៥៧,២ ភាគរយ។ បន្ទាប់មកទៀតគឺផ្នែកផលិតកម្មមាន ៧៥ ពាន់សហគ្រាស ស្មើនឹង ១៤,៩ ភាគរយ ផ្នែកលំនៅដ្ឋាន និងសកម្មភាពសេវាម្ហូបអាហារមាន ៧០ ពាន់សហគ្រាស ស្មើនឹង ១៣,៨ ភាគរយ និងសកម្មភាពសេវាកម្មផ្សេងៗទៀតមាន ៣៣ ពាន់សហគ្រាស ស្មើនឹង ៦,៤ ភាគរយ។ នៅក្នុងផ្នែកកម្មន្តសាលជាពិសេសសហគ្រាសកិនស្រូវ ផលិតផលកែច្នៃធញ្ញជាតិ និងវាយនភ័ណ្ឌមានសមាមាត្រមួយយ៉ាងធំ។ *(ព័ត៌មានលំអិតដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី១.៣)*

### ៣.៣. ចំនួនសហគ្រាសតាមបណ្តារាជធានី-ខេត្ត

បើមើលពីចំនួនសហគ្រាសតាមបណ្តារាជធានី-ខេត្ត រាជធានីភ្នំពេញគឺជាតំបន់ដែលមានសហគ្រាសច្រើនជាងគេបំផុតដែលមានចំនួន ៩៦ ពាន់សហគ្រាស ស្មើនឹង ១៩ ភាគរយ។ បន្ទាប់មកគឺខេត្តកំពង់ចាមមានចំនួន ៥៦ ពាន់សហគ្រាសស្មើនឹង ១១,១ ភាគរយ ខេត្តកណ្តាលមានចំនួន ៤១ ពាន់សហគ្រាស ស្មើនឹង ៨ ភាគរយ ខេត្តបាត់ដំបងមានចំនួន ៣៤ ពាន់សហគ្រាសស្មើនឹង ៦,៨ ភាគរយ ខេត្តសៀមរាបមានចំនួន ៣២ ពាន់សហគ្រាសស្មើនឹង ៦,៤ ភាគរយ និងខេត្តតាកែវមានចំនួន ៣២ ពាន់សហគ្រាសស្មើនឹង ៦,៣ ភាគរយ។ រាជធានីភ្នំពេញមានសហគ្រាសច្រើនដោយសារជាកន្លែងនៃមជ្ឈមណ្ឌលពាណិជ្ជកម្ម និងដោយសារការកាត់បញ្ចូល ២០ ឃុំ ពីខេត្តកណ្តាលផងដែរ។ ហើយបើគិតពីចំនួនអ្នកធ្វើការគឺមានច្រើនជាងគេរហូតដល់ ៥៥៩ ពាន់នាក់ស្មើនឹង ៣៣,៤ ភាគរយ បន្ទាប់មកទៀតគឺខេត្តកណ្តាលមាន ១៥១ ពាន់នាក់ស្មើនឹង ៩ ភាគរយ ខេត្តកំពង់ចាមមាន ១៤៣ ពាន់នាក់ស្មើនឹង ៨,៥ ភាគរយ ខេត្តសៀមរាបមាន ៩៤ ពាន់នាក់ស្មើនឹង ៥,៦ ភាគរយ និងខេត្តបាត់ដំបងមាន ៨៥ ពាន់នាក់ស្មើនឹង ៥,១ ភាគរយ។*(ព័ត៌មានលំអិតដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី១.៤)*

## ៤. ស្ថានភាពវិស័យសន្តិសុខសង្គមនៅកម្ពុជា

ស្ថានភាពនៃវិស័យសន្តិសុខសង្គមនៅកម្ពុជា មានការរីកចំរើនគួរឲ្យកត់សំគាល់នាប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រមួយចំនួន សម្រាប់ការគាំពារសង្គមដ៏ទូលំទូលាយមួយ និងលើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឲ្យកាន់តែល្អប្រសើរ ដើម្បីឈានឆ្ពោះទៅកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ស្ថិរភាពសង្គម ដែលរួមមានៈ *យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងទី២* ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣* និង *យុទ្ធសាស្ត្រជាតិគាំពារសង្គម សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (២០១១-២០១៥)*។ ក្រៅពីផែនការយុទ្ធសាស្ត្រខាងលើក៏នៅមានផែនការយុទ្ធសាស្ត្រ បទដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀតដែលមានស្រាប់ និងត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ដែលស្របតាមស្ថានភាពរីកចំរើននៃសេដ្ឋកិច្ចជាតិ មានជាអាទិ៍ៈ *អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)* អនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ *អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស)* និង *អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ)*។

ស្របតាមគោលនយោបាយជាយុទ្ធសាស្ត្រខាងលើ ក្នុងការរួមចំណែកលើកស្ទួយប្រព័ន្ធសុវត្ថិភាពសង្គម ដែលរួមមានសំណាញ់សុវត្ថិភាពសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ការធានាសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងការធានាសន្តិសុខសង្គមដល់កម្មករនិយោជិតនៅក្នុងវិស័យឯកជន ស្ថាប័នពាក់ព័ន្ធនានាសម្រេចបានការងារមួយចំនួនគួរឲ្យកត់សំគាល់។

*រូបភាពទី៣៖ វិសាលភាពនៃយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ*




*ប្រភព៖ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ*

## ៤.១. របបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

ការធានារ៉ាប់រងសន្តិសុខសង្គមនៅក្នុងវិស័យការងារឯកជន អនុវត្តដោយគ្រឹះស្ថានបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ ដែលរួមមានផ្នែកប្រាក់សោធន ផ្នែកហានិភ័យការងារ និងផ្នែកផ្សេងៗទៀត ស្របតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចជាតិ។ បេឡាជាតិរបបសន្តិសុខសង្គម បានអនុវត្តនូវជំហានទី១ របបធានារ៉ាប់រងហានិភ័យការងារនាខែវិច្ឆិកា ឆ្នាំ២០០៨ រហូតមកដល់ដំណាច់ឆ្នាំ២០១២ បានពង្រីកវិសាលភាពចំនួន២០/២៤ រាជធានី-ខេត្ត បានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានចំនួន ៤.៥៨៣ សហគ្រាស មានកម្មករនិយោជិតសរុបចំនួន ៧៦៨.១៣៤ នាក់ និងបានផ្តល់ការធានារ៉ាប់រងគ្រោះថ្នាក់ការងារដល់សមាជិកចំនួនជាង ៣៧.០០០ នាក់។ បេឡាជាតិរបបសន្តិសុខសង្គម ក៏មានទិសដៅអនុវត្តនូវជំហានទី២ លើរបបធានារ៉ាប់រងសុខភាពនៅឆ្នាំ២០១៣ និងជំហានទី៣ របបប្រាក់សោធននៅឆ្នាំ២០១៥ ខាងមុខនេះ។

## ៤.២. របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងជនពិការ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានតួនាទីអភិវឌ្ឍ និងរៀបចំគ្រប់គ្រងរបបសន្តិសុខសង្គម សម្រាប់ផ្នែកមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន។ សម្រាប់ផ្នែកមន្ត្រីរាជការស៊ីវិល ទទួលបន្ទុកដោយគ្រឹះស្ថានបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) អនុលោមតាមព្រះរាជក្រឹត្យ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលព្រះរាជក្រឹត្យនេះមានគោលដៅកំណត់ពីរបបសន្តិសុខសង្គម ស្ថាប័នអនុវត្ត និងមូលនិធិសម្រាប់ទ្រទ្រង់របបសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។ របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល គ្របដណ្តប់លើតាវកាលិក ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក។ យោងតាមរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០១១ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រហូតមកដល់ឆ្នាំ២០១១ មាននិវត្តជនចំនួន ៣៦.៤៧៦ នាក់ ប្រពន្ធចំនួន ២៨.៣៧៩ នាក់ និងកូនចំនួន ៩.០៣៩ នាក់ និងជនបាត់បង់សម្បទាវិជ្ជាជីវៈចំនួន ៣.៨៥៧ នាក់ ប្រពន្ធចំនួន ២.១៥៥ នាក់ និងកូន ២២៥ នាក់ ដែលកំពុងទទួលរបបសោធននិវត្តន៍។

ចំពោះផ្នែកអតីតយុទ្ធជន ទទួលបន្ទុកដោយអង្គភាពបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ) លើការផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ដែលរហូតមកដល់ឆ្នាំ២០១១ មានអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារដែលទទួលរបបសន្តិសុខសង្គមពីរដ្ឋមានចំនួន ៨៨.៤៦៧ គ្រួសារ និងអ្នកនៅក្នុងបន្ទុក ២១៧.៦៦៨ នាក់។

ក្រសួងនេះក៏ទទួលបន្ទុកផងដែរ លើការគ្រប់គ្រងមូលនិធិជនពិការ អនុលោមតាមអនុក្រឹត្យលេខ ១១៨ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ ដែលមូលនិធិនេះជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ហៅកាត់ថា (ម.ជ.ព) ដើម្បីរួមចំណែកលើកស្ទួយវិស័យពិការភាពឲ្យកាន់តែល្អប្រសើរឡើង។

## ៤.៣. សំណាញ់សុវត្ថិភាពសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ

សំណាញ់សុវត្ថិភាពសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ គឺជាសំណាញ់សុវត្ថិភាពសង្គមមួយ ដែលមានការចូលរួមពីបណ្តាក្រសួង ដៃគូអភិវឌ្ឍន៍ អង្គការ និងស្ថាប័នពាក់ព័ន្ធនានា លើការផ្តល់នូវការគាំពារសង្គមសម្រាប់ប្រជាជនទូទៅ ឲ្យទទួលបាននូវអាហារូបត្ថម្ភ ការថែទាំសុខភាព ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ការការពារ និងការជួយអន្តរាគមន៍ពីសង្គមនៅពេលដែលទទួលរងហានិភ័យផ្សេងៗ ដើម្បីឈានឆ្ពោះទៅកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ស្ថិរភាពសង្គម។

សម្រាប់ផ្នែកថែទាំសុខភាព ក្រសួងសុខាភិបាលមានតួនាទី ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធសុខាភិបាល ជាពិសេសសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ឲ្យទទួលបាននូវសេវាសុខាភិបាលដ៏សមរម្យ ប្រកបដោយគុណភាព អាចទទួលយកបាន និងស្មើភាព។ យោងតាមរបាយការណ៍

សមិទ្ធិផលសុខាភិបាលឆ្នាំ២០១១ របស់ក្រសួងសុខាភិបាល ប្រជាពលរដ្ឋក្រីក្រដែលកំពុងត្រូវបានគាំពារដោយយន្តការហិរញ្ញប្បទានសុខាភិបាលមួយចំនួន មានជាអាទិ៍៖ ការលើកលែងការបង់ថ្លៃសេវាមូលនិធិសមធម៌ និងប័ណ្ណសុខភាពបន្តពូជ ដែលយន្តការទាំងអស់នេះហិរញ្ញប្បទានដោយថវិកាជាតិ និងថវិកាដៃគូ។ រីឯប្រជាពលរដ្ឋមួយចំនួនទៀត កំពុងត្រូវបានការពារដោយគម្រោងធានារ៉ាប់រងសុខភាពសហគមន៍ ដែលហិរញ្ញប្បទានដោយប្រាក់បង់វិភាគទានទុកជាមុនពីសមាជិក ធានារ៉ាប់រងឈរលើគោលការណ៍ស្ម័គ្រចិត្ត។ ករណីប្រើប្រាស់សេវាដោយប្រជាជនក្រីក្រក្រោមយន្តការហិរញ្ញប្បទានគាំពារប្រជាជនក្រីក្រដូចបានរៀបរាប់ខាងលើនៅក្នុងឆ្នាំ២០១១ មានចំនួនសរុប ២.១៦៤.១៣០ ករណី។ ចំពោះមូលនិធិសមធម៌ករណីប្រើប្រាស់សេវារបស់ប្រជាជនក្រីក្រ គាំពារដោយមូលនិធិសមធម៌មានចំនួនសរុប ៨៧២.៥៥៦ ករណី និងចំណាយដោយប្រើប្រាស់ថវិកាដៃគូរួមជាមួយថវិកាបដិភាគរបស់រាជរដ្ឋាភិបាលនៅឆ្នាំ២០១១ មានទឹកប្រាក់សរុប ៦.៤៦២.៧០០ ដុល្លារ។

ក្រៅពីយន្តការខាងលើដែលគ្រប់គ្រងផ្ទាល់ដោយរដ្ឋ រាជរដ្ឋាភិបាលកម្ពុជាក៏បានបើកចំហរឲ្យមានការចូលរួមអភិវឌ្ឍន៍វិស័យសន្តិសុខសង្គម និងបង្កបរិយាកាសល្អដល់ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន ដើម្បីផ្តល់សេវាសន្តិសុខសង្គមដល់ប្រជាពលរដ្ឋ។ ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលបានចូលរួមចំណែកយ៉ាងសំខាន់ នៅក្នុងការអភិវឌ្ឍន៍វិស័យសន្តិសុខសង្គមនៅកម្ពុជា ជាក់ស្តែងតាមរយៈជំនួយពី AFD និង GIZ អង្គការ GRET បានបង្កើតគម្រោងសុខភាពគ្រួសារយើង (SKY) និងគម្រោងធានារ៉ាប់រងសុខភាព (HIP)។ SKY គឺជាគម្រោងធានារ៉ាប់រងសុខភាពដោយស្ម័គ្រចិត្តសម្រាប់គ្រួសារនៅតាមតំបន់ជនបទ នៅក្នុងផ្នែកក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ ដែលចាប់តាំងពីពេលដំណើរការនាឆ្នាំ២០០៨ រហូតមកដល់ឆ្នាំ២០១១ គម្រោង SKY មានសមាជិកចំនួន ៧០.០៧៨ នាក់ ដែលគម្រោងនេះជាផ្នែកមួយនៃគម្រោងធានារ៉ាប់រងសុខភាពតាមសហគមន៍ (CBHI) និងដៃគូជាមួយមូលនិធិសមធម៌ (HEF) ដូចមាននៅក្នុងផែនការមេសម្រាប់ការគាំពារសង្គមរបស់ក្រសួងសុខាភិបាល។ គម្រោងធានារ៉ាប់រងសុខភាព HIP ចាប់ផ្តើមដំណើរការនាឆ្នាំ២០០៩ មានដៃគូជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង GMAC ផ្តល់ជំនួយដោយ AFD អនុវត្តសាកល្បងលើគម្រោងធានារ៉ាប់រងសុខភាពជាកាតព្វកិច្ច របស់បេឡាជាតិរបបសន្តិសុខសង្គម ដែលគ្រោងនឹងចាប់ផ្តើមអនុវត្តនាឆ្នាំ២០១៣។ គម្រោងនេះធ្វើការធានារ៉ាប់រងសុខភាពកម្មកររោងចក្រកាត់ដេរដោយការចូលរួមបង់ភាគទាន ៥០ ភាគរយ ពីនិយោជក ដែលរហូតមកដល់ខែតុលា ឆ្នាំ២០១១ គម្រោងនេះមានកម្មករចូលរួមចំនួន ៥.៩៣៩ នាក់ មកពីរោងចក្រចំនួន ១១ ។

# ជំពូកទី ៤
# បេឡាជាតិរបបសន្តិសុខសង្គម
# ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ (គ្រោះថ្នាក់ការងារ)
# ជំហានទី១

បេឡាជាតិរបបសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាសាធារណៈមានលក្ខណៈសង្គម ហៅកាត់ថា (ប.ស.ស) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ អនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលច្បាប់នេះមានគោលបំណងបង្កើតឲ្យមានរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានផ្នែកប្រាក់សោធន ផ្នែកហានិភ័យការងារ និងផ្នែកផ្សេងៗទៀតស្របតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចជាតិ។ បេឡាជាតិរបបសន្តិសុខសង្គម គឺជានីតិបុគ្គលសាធារណៈ ដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប.ស.ស មានក្រុមប្រឹក្សាភិបាលចូលរួមដោយត្រីភាគី ដែលមកពីខាងរដ្ឋាភិបាល តំណាងនិយោជក និងតំណាងកម្មករនិយោជិត។

## ១. គ្រោះថ្នាក់ការងារ

បេឡាជាតិរបបសន្តិសុខសង្គម ចាប់ផ្តើមអនុវត្តជំហានទី១ របបធានារ៉ាប់រងគ្រោះថ្នាក់ការងារនាខែវិច្ឆិកា ឆ្នាំ២០០៨។ របបធានារ៉ាប់រងគ្រោះថ្នាក់ការងារ ជាការធានារ៉ាប់រងជាកាតព្វកិច្ចគ្របដណ្តប់លើកម្មករនិយោជិតទាំងអស់ ដែលកំណត់ដោយច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ របបធានារ៉ាប់រងគ្រោះថ្នាក់ការងារគ្របដណ្តប់លើគ្រោះថ្នាក់៖

***គ្រោះថ្នាក់នៅពេលធ្វើការ ឬក្នុងពេលធ្វើការ*** ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិត ដោយធ្វើការ ឬក្នុងពេលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសពីកម្មករនិយោជិត ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលធ្វើការឲ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈ មានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វី នៅទីកន្លែងណាក៏ដោយ។

***គ្រោះថ្នាក់ពេលធ្វើដំណើរ*** ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិត ក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឲ្យទៅ។

***ជំងឺដែលបណ្តាលមកពីវិជ្ជាជីវៈ*** ត្រូវចាត់ទុកជាហានិភ័យការងារ ចំពោះជំងឺដែលបណ្តាលមកពីវិជ្ជាជីវៈ ដែលទាក់ទងនឹងការងារប្រើកំលាំងកាយ ប៉ះពាល់ដោយជាតិពុល និងការងារដែលអនុវត្តនៅក្នុងលក្ខខណ្ឌ ឬតំបន់មានលក្ខណៈមិនប្រក្រតី ដែលនាំឲ្យអ្នកធ្វើការកើតជំងឺផ្សេងៗ។

## ២. តាវកាលិកគ្រោះថ្នាក់ការងារ

កម្មករនិយោជិតទាំងអស់នៃសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម មានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ នៅពេលដែលសាមីជនទទួលរងនូវហានិភ័យការងារ។ តាវកាលិកគ្រោះថ្នាក់ការងាររួមមាន៖

***ការផ្តល់សេវាសង្គ្រោះបន្ទាន់*** ក្នុងករណីដែលគ្រោះថ្នាក់កើតនៅនឹងកន្លែងធ្វើការ និយោជកត្រូវផ្តល់ការសង្គ្រោះបន្ទាន់ នៅកន្លែងដែលជិតបំផុត និងបន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ ការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនខាងលើ ត្រូវស្ថិតនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។

***ការផ្តល់សេវាថែទាំ និងព្យាបាល*** ការព្យាបាលចំពោះកម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារត្រូវតែប្រព្រឹត្តទៅ នៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

***ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃ*** ប្រាក់បំណាច់ប្រចាំថ្ងៃ សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នស្មើនឹង ៧០ ភាគរយ នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ។ ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំនៅមន្ទីរពេទ្យត្រូវស្មើនឹង ៥០ ភាគរយនៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ។ ប្រាក់បំណាច់ប្រចាំថ្ងៃ ដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការកើតឧបទ្ទវហេតុបណ្តាលឲ្យទទួលរងនូវហានិភ័យការងារ។

***តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍*** កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង ២០ ភាគរយ មានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ ដែលប្រាក់វិភាជន៍នេះត្រូវផ្តល់ជូនអ្នករងគ្រោះតែម្តងគត់។ កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារចាប់ពី ២០ ភាគរយឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍។

***តាវកាលិកសម្រាប់អ្នកចាំថែរក្សាជនរងគ្រោះ*** កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ក្នុងកម្រិត ១០០ ភាគរយ មានសិទ្ធិទទួលបានប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាដល់ខ្លួន។ ប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាត្រូវស្មើ ៥០ ភាគរយនៃប្រាក់ធនលាភរបស់ជនរងគ្រោះ។

***ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព*** ក្នុងករណីដែលមានការទទួលរងនូវហានិភ័យការងារ រហូតបណ្តាលឲ្យបាត់បង់ជីវិត អ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព ត្រូវបានផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព ដែលមានចំនួន ៤.០០០.០០០ រៀល។ ប្រាក់វិភាជន៍នេះ ត្រូវតែផ្តល់ជូនទៅជនដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ។

***ភាវកាលិកឧត្តរជីវី*** គឺជាប្រាក់ធនលាភដែលត្រូវផ្តល់ឲ្យសិទ្ធិវន្ត នៃជនរងគ្រោះថ្នាក់ការងាររហូតដល់បាត់បង់ជីវិត។ សិទ្ធិវន្ត មានប្រពន្ធ ឬប្តី កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក ចំពោះសិទ្ធិវន្ត ជាប្រពន្ធ ឬប្តីនៃជនរងគ្រោះ ត្រូវមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ហើយសិទ្ធិនេះនឹងត្រូវបានរំលាយនៅពេលដែលសាមីជនរៀបអាពាហ៍ពិពាហ៍ជាថ្មី។ សិទ្ធិទទួលធនលាភនៃសិទ្ធិវន្ត ត្រូវបានរំលាយនៅពេលដែលសាមីជនទទួលមរណភាព។

***សេវាបុនរ្នីតិសម្បទា*** កម្មករនិយោជិតដែលរងហានិភ័យការងារ បណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានឧបករណ៍ ឬអវយវៈសិប្បនិម្មិត តាមការកំណត់របស់គ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ ជនរងគ្រោះ មានសិទ្ធិទទួលបានសេវាសម្របសម្រួលមុខងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ។

## ៣. បែបបទ និងនីតិវិធីនៃការចុះបញ្ជិកា និងបង់ភាគទាន

### ៣.១. បែបបទ និងនីតិវិធីនៃការចុះបញ្ជិកា

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានរបស់ខ្លួនក្នុងបេឡាជាតិរបបសន្តិសុខសង្គម។

និយោជក ឬម្ចាស់សហគ្រាស ត្រូវផ្ញើបញ្ជីឈ្មោះកម្មករនិយោជិតនៅក្នុងសហគ្រាសរបស់ខ្លួនមកបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម។ ការផ្ញើបញ្ជីឈ្មោះកម្មករនិយោជិត ត្រូវធ្វើក្នុងពេលដំណាលគ្នានឹងការផ្ញើទម្រង់បញ្ជិកាសហគ្រាស គ្រឹះស្ថាន។

បេឡាជាតិរបបសន្តិសុខសង្គមនឹងផ្តល់ "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន" ជូនសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិការួច និងផ្តល់លេខអត្តសញ្ញាណ និងចេញ "ប័ណ្ណធានារ៉ាប់រងហានិភ័យការងារ" ជូនកម្មករនិយោជិតម្នាក់ៗដោយឥតគិតថ្លៃ។ "ប័ណ្ណធានារ៉ាប់រងហានិភ័យការងារ" ត្រូវប្រគល់ជូនទៅកម្មករនិយោជិតតាមរយៈនិយោជក។

រៀងរាល់ខែ និយោជកដែលជានាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្ញើរបាយការណ៍អំពីចំនួនកម្មករនិយោជិតមកបេឡាជាតិរបបសន្តិសុខសង្គម ឲ្យបានមុនថ្ងៃទី១៥ នៃខែបន្ទាប់។ របាយការណ៍អំពីចំនួនកម្មករនិយោជិត ត្រូវធ្វើឡើងដូចគ្នានឹងទម្រង់ "បញ្ជិកាកម្មករនិយោជិត" ដោយត្រូវបញ្ជាក់បន្ថែមអំពីចំនួនកម្មករនិយោជិតទាំងអស់ដែលមាននៅក្នុងខែត្រូវរាយការណ៍។ របាយការណ៍

អំពីចំនួនកម្មករនិយោជិត ដែលត្រូវធ្វើជូនបេឡាជាតិរបបសន្តិសុខសង្គម អាចធ្វើតាម "ទម្រង់ក្រដាស" ឬ "ទម្រង់អេឡិចត្រូនិច" ដោយមានលិខិតបញ្ជូន ដែលចុះហត្ថលេខានាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន។

ក្នុងដំណាក់កាលចាប់ដំណើរការដំបូង នៃបេឡាជាតិរបបសន្តិសុខសង្គម ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានត្រូវអនុវត្ត ចំពោះតែសហគ្រាស គ្រឹះស្ថានណាដែលមានកម្មករនិយោជិតចំនួន ០៨ នាក់ឡើង។

### ៣.២. បែបបទ និងនីតិវិធីនៃការបង់ភាគទាន

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ មានកម្មករនិយោជិតចាប់ពី ០៨ នាក់ឡើងទៅ បានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកហានិភ័យការងារ ជូនដល់បេឡាជាតិរបបសន្តិសុខសង្គម ។

ភាគទានផ្នែកហានិភ័យការងារ គឺជាកាតព្វកិច្ចដោយឡែករបស់និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន។ កម្មករនិយោជិត មិនតម្រូវឲ្យមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះទេ។ អត្រាភាគទានផ្នែកហានិភ័យការងារជាអត្រាឯកភាព ដែលត្រូវបានកំណត់ស្មើនឹង ០,៨ ភាគរយនៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។

កាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទានដំបូង ត្រូវបានកំណត់ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែល ប.ស.ស បានចេញ "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន"។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានសម្រាប់ខែនីមួយៗយ៉ាងយូរបំផុតនៅថ្ងៃទី ១៥ នៃខែបន្ទាប់។ ការខកខានមិនបានបង់ភាគទានតាមកាលបរិច្ឆេទដែលបានកំណត់ខាងលើ ត្រូវបង់បន្ថែមនូវការប្រាក់តាមចំនួនជាក់ស្តែង និងត្រូវទទួលការពិន័យជាប្រាក់តាមអត្រាអប្បបរមា ដូចមានចែងក្នុងមាត្រា ៣៦ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានដោយផ្ទាល់ចូលទៅគណនីរបស់បេឡាជាតិរបបសន្តិសុខសង្គម ដែលស្ថិតក្នុងធនាគារដែលបានកំណត់ រួចហើយត្រូវផ្ញើ "បង្កាន់ដៃបង់ភាគទាន " ដែលចេញដោយធនាគារមក ប.ស.ស បន្ទាប់ពីថ្ងៃដែលខ្លួនបានបង់។ បន្ទាប់ពីបានទទួល "បង្កាន់ដៃបង់ភាគទាន" បេឡាជាតិរបបសន្តិសុខសង្គម នឹងចេញលិខិតបញ្ជាក់អំពី "ការទទួលប្រាក់ភាគទាន" ជូនទៅសហគ្រាស គ្រឹះស្ថានសាមីវិញ។ ក្នុងករណីដែលពិនិត្យឃើញថា ភាគទានដែលបានបង់មិនគ្រប់ចំនួន ប.ស.ស ត្រូវកំណត់ឲ្យសហគ្រាស គ្រឹះស្ថានបង់បង្គ្រប់តាមចំនួនជាក់ស្តែង។ *(ព័ត៌មានលំអិតអំពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានហានិភ័យការងារ ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី២.១)*

## ៤. លទ្ធផលការងារសម្រេចបាន លើការអនុវត្តរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារ ឆ្នាំ២០១២

### ៤.១. ការងារចុះបញ្ជិកា និងប្រមូលភាគទាន

ចាប់តាំងពីការអនុវត្តដំបូងនាខែវិច្ឆិកា ឆ្នាំ២០០៨ រហូតមកដល់ឆ្នាំ២០១២ បេឡាជាតិរបបសន្តិសុខសង្គម បានពង្រីកវិសាលភាពរបបធានារ៉ាប់រងហានិភ័យការងារបានចំនួន ២០/២៤ រាជធានី-ខេត្ត ចុះកិច្ចសន្យាប្រើប្រាស់សេវាសុខាភិបាល ជាមួយមន្ទីរពេទ្យ មណ្ឌលសុខភាព និងមន្ទីរព្យាបាលឯកជនចំនួន ៥១ និងបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានប្រមាណចំនួន ៤.៥៨៣ សហគ្រាស មានកម្មករនិយោជិតសរុបចំនួន ៧៦៨.១៣៤ នាក់ ក្នុងនោះសហគ្រាសជាប់ភាគទានចំនួន ៤.៥១៩ សហគ្រាសដែលបានបង់ភាគទានមានចំនួន ៣.៩២១ និងមានកម្មករនិយោជិតចំនួន ៧៤៥.២៧៥ នាក់។

### ៤.២. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម

ការងារអធិការកិច្ច និងកិច្ចការនីតិកម្មមានមុខងារក្នុងការធានាឲ្យមានការអនុវត្តច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទបញ្ញាផ្សេងៗជាធរមាន។ ផ្នែកនេះផ្តោតជាសំខាន់លើការងារមួយចំនួនមានជាអាទិ៍ ការអញ្ជើញសហគ្រាស គ្រឹះស្ថាន ឲ្យមកចុះបញ្ជិកា និងបង់ភាគទាន ការចុះអង្កេតគ្រោះថ្នាក់ការងារ ការពង្រឹងការអនុវត្តច្បាប់តាមរយៈការធ្វើអធិការកិច្ច ការដាក់កំហិត ការពិន័យ និងពាក្យបណ្តឹងទៅតុលាការក្នុងករណីសហគ្រាស គ្រឹះស្ថាន មិនព្រមអនុវត្តតាមច្បាប់ និងបទបញ្ញាជាធរមាន។ សម្រាប់ឆ្នាំ២០១២ បេឡាជាតិរបបសន្តិសុខសង្គម បានចាត់មន្ត្រីឲ្យចុះធ្វើអធិការកិច្ចបានចំនួនជាង ១.០០០ សហគ្រាស ចុះអង្កេតគ្រោះថ្នាក់ការងារចំនួនប្រមាណ ១៤.៧៥៤ នាក់ និងបានដាក់ពាក្យបណ្តឹង និងចូលរួមក្នុងនីតិវិធីត្រៀមទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការចំពោះសហគ្រាស គ្រឹះស្ថាន ដែលមិនព្រមអនុវត្តតាមច្បាប់ចំនួនជាង ១០ ករណី។ ក្រៅពីការងារខាងលើ បេឡាជាតិរបបសន្តិសុខសង្គម បានចាត់វិធានការចុះស្រាវជ្រាវពីសហគ្រាស គ្រឹះស្ថានថ្មីៗ ចុះសម្របសម្រួលពន្យល់ ណែនាំពីការអនុវត្តគោលនយោបាយរបបធានារ៉ាប់រងហានិភ័យការងារ ពិសេសពីនីតិវិធីនៃការចុះបញ្ជិកា និងបង់ភាគទាន បានលទ្ធផលគួរឲ្យកត់សំគាល់។

### ៤.៣. ការផ្តល់តាវកាលិកគ្រោះថ្នាក់ការងារ

ការងារផ្តល់តាវកាលិកជាគោលដៅមួយដ៏សំខាន់ នៃការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាពិសេសលើការអនុវត្តជំហានទី១ របបធានារ៉ាប់រងហានិភ័យការងារ ដោយវាបានផ្តល់នូវការធានារ៉ាប់រងដល់កម្មករនិយោជិតដែលបម្រើការងារនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន ឲ្យទទួលបាននូវការព្យាបាលដោយឥតគិតថ្លៃ និងធានាបាននូវសន្តិសុខប្រាក់ចំណូល នៅពេលដែលពួកគេទទួលរងនូវគ្រោះថ្នាក់ការងារ។

បេឡាជាតិរបបសន្តិសុខសង្គម ដើម្បីធានាដល់ការផ្តល់តាវកាលិកឲ្យមានប្រសិទ្ធភាព និងបាន ឆាប់រហ័ស បានដាក់ឲ្យដំណើរការប្រព័ន្ធទូរស័ព្ទទំនាក់ទំនងបន្ទាន់ (១២៨៦) សម្រាប់ការសង្គ្រោះបន្ទាន់នៅពេលមានគ្រោះថ្នាក់ការងារ និងបានចុះកិច្ចសន្យាជាមួយមន្ទីរពេទ្យ និងមន្ទីរព្យាបាលឯកជនបានចំនួន ៥១ ហើយបានដាក់ភ្នាក់ងារឲ្យប្រចាំការនៅតាមមន្ទីរពេទ្យនីមួយៗ ដើម្បីជួយសម្របសម្រួលការងារប្រចាំថ្ងៃដល់ជនរងគ្រោះ។ មួយវិញទៀត ក្នុងករណីមានគ្រោះថ្នាក់ធ្ងន់ធ្ងរ បេឡាជាតិរបបសន្តិសុខសង្គម បានបញ្ជូនមន្ត្រីទៅដល់កន្លែងគ្រោះថ្នាក់ផ្ទាល់ ដើម្បីជួយសម្របសម្រួល និងធ្វើអន្តរាគមន៍បានទាន់ពេលវេលា។ ចាប់តាំងពីដំណើរការរហូតមកដល់ឆ្នាំ២០១២ ប.ស.ស បានផ្តល់ការធានារ៉ាប់រងគ្រោះថ្នាក់ការងារដល់កម្មករនិយោជិតចំនួនជាង *៣៧.០០០* នាក់។

ដោយឡែកសម្រាប់ឆ្នាំ២០១២ បេឡាជាតិរបបសន្តិសុខសង្គម បានទទួលរបាយការណ៍ហានិភ័យការងារចំនួន ១៤.៧៦១ នាក់ ហើយតាមរយៈលទ្ធផលនៃការអង្កេត មានគ្រោះថ្នាក់ការងារចំនួន ១៤.២៣៣ នាក់ (ស្រី ១០.៧០៩ នាក់) ក្នុងនោះរបួសស្រាលមាន ១៣.៥៨៥ នាក់ របួសធ្ងន់ ៥៧១ នាក់ ជំងឺវិជ្ជាជីវៈ ១៨ នាក់ និងស្លាប់ ៥៩ នាក់ និងមិនមែនគ្រោះថ្នាក់ការងារចំនួន ៥២១ នាក់។ គ្រប់ករណីគ្រោះថ្នាក់ការងារទាំងអស់ខាងលើ ត្រូវបានផ្តល់តាវកាលិកដោយបេឡាជាតិរបបសន្តិសុខសង្គម។ *(ព័ត៌មានលំអិតអំពីរបាយការណ៍ហានិភ័យការងារ សូមអាននៅក្នុងតារាងឧបសម្ព័ន្ធទី២.២)*

# ជំពូកទី ៥
# ផែនការយុទ្ធសាស្ត្រ
# បេឡាជាតិរបបសន្តិសុខសង្គម

ផែនការយុទ្ធសាស្ត្ររបស់បេឡាជាតិរបបសន្តិសុខសង្គម បង្កើតឡើងដោយអនុលោមតាមបទដ្ឋានសំខាន់ៗមួយចំនួន ស្ថានភាពនៃការអភិវឌ្ឍទាំងនៅក្នុងប្រទេស និងក្នុងតំបន់ ភាពងាយស្រួល និងបញ្ហាប្រឈមនានា ដែលត្រូវដោះស្រាយ និងអនុវត្តឲ្យបានឆាប់រហ័សទាក់ទងនឹងការផ្តល់ការគាំពារសង្គម ដែលទិដ្ឋភាពទាំងនោះរួមមាន ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ផែនការសកម្មភាពរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលច្បាប់នេះមានគោលបំណងបង្កើតឲ្យមានរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានផ្នែកប្រាក់សោធន ផ្នែកហានិភ័យការងារ និងផ្នែកផ្សេងៗទៀតស្របតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចជាតិ។

ការធ្វើសមាហរណកម្មអាស៊ានឆ្នាំ២០១៥ ដើម្បីប្រែក្លាយអាស៊ានឲ្យទៅជាសហគមន៍តែមួយ វាសនាតែមួយ នៅក្នុងការកាត់បន្ថយនូវគម្លាតនៃការអភិវឌ្ឍ និងជារួមការធ្វើឲ្យមានភាពសុខដុមរមនារបស់ប្រជាជាតិទាំងមូល ដែលរួមមានការរៀបចំប្រព័ន្ធសំណាញ់សុវត្ថិភាពសង្គមផងដែរនោះ កម្ពុជាត្រូវអភិវឌ្ឍស្តង់ដារសន្តិសុខសង្គម ឲ្យបានល្អប្រសើរសម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន និងសម្រាប់ជាធាតុចូលមួយនៅក្នុងការជំរុញ ដើម្បីសម្រេចឲ្យបាននូវសហគមន៍អាស៊ានតែមួយនៅឆ្នាំ២០១៥។

បន្ថែមពីលើនេះ ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក៏បានផ្តល់នូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់ទាក់ទងនឹងវិស័យសន្តិសុខសង្គមឲ្យ *“ជំរុញការគិតគូរឲ្យបានល្អិតល្អន់អំពីប្រយោជន៍កម្មករនិយោជិតឲ្យបានប្រសើរ ដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព តាមរយៈការអនុវត្តច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាជំហានបន្តទៀត ជាពិសេសត្រូវគិតគូរដល់អ្នកធ្វើការក្រៅផ្លូវការ ដែលមិនអាចទទួលបាននូវសោធននិវត្តន៍ អត្ថប្រយោជន៍ពេលឈឺថ្កាត់ និងការការពារលើហានិភ័យនៃការងារ ដូចជាគ្រោះថ្នាក់ និងខូចសុខភាពជាដើម”* ។

អនុលោមតាមទិដ្ឋភាពជារួមខាងលើ បេឡាជាតិរបបសន្តិសុខសង្គម បាននឹងកំពុងរៀបចំពង្រីកពង្រឹង និងអភិវឌ្ឍការងាររបស់ខ្លួនបន្ថែមទៀត ដោយបានរៀបចំនូវផែនការយុទ្ធសាស្ត្ររយៈពេលវែងនេះឡើង ដែលមានចក្ខុវិស័យ និងបេសកកម្មយ៉ាងច្បាស់លាស់ក្នុងការធានាផ្នែកសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារជាជំហានៗ ក្នុងគោលដៅជួយសម្រាលការលំបាក

នានានៅពេលជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬ ពេលជួបប្រទះយថាភាពផ្សេងៗ ទៀតដូចជាជំងឺ និងមាតុភាពជាដើម នៅក្នុងការរួមចំណែកដល់គោលនយោបាយកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាល ធានាឲ្យមានស្ថិរភាព និងភាពសុខដុមរមនានៅក្នុងសង្គម ដោយបានកំណត់ គោលដៅធំៗចំនួន ០៣ សម្រាប់អនុវត្តរយៈពេល ០៣ ឆ្នាំ (២០១៣-២០១៥)។

- *គោលដៅទី១ ៖ ពង្រីក និង ពង្រឹងការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ*
- *គោលដៅទី២៖ ដំណើរការរបបធានារ៉ាប់រងសុខភាព*
- *គោលដៅទី៣៖ ដំណើរការរបបប្រាក់សោធន*

## ១. គោលដៅទី១. ពង្រីក និង ពង្រឹងការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

រហូតមកដល់ឆ្នាំ២០១២ របបធានារ៉ាប់រងហានិភ័យការងារ ត្រូវបានដាក់ឲ្យដំណើរការអស់ រយៈពេលជាង ៤ ឆ្នាំ មកហើយ។ ឆ្លងកាត់រយៈពេលនេះ បេឡាជាតិរបបសន្តិសុខសង្គម បានមើល ឃើញ ក៏ដូចជាទទួលបាននូវបទពិសោធន៍ជាច្រើន ទាំងចំណុចខ្លាំង និងចំណុចខ្សោយដែលជាបញ្ហា ប្រឈម ដែលបញ្ហាទាំងនោះទាក់ទងជាចម្បងជាមួយនឹងការអនុវត្តកាតព្វកិច្ចរបស់និយោជក មាន ជាអាទិ៍ ការមិនចង់ចុះបញ្ជិកាជាមួយ ប.ស.ស, ការមិនព្រមបង់ភាគទាន, ការលាក់ចំនួនកម្មករ និយោជិត, ការប្តូរឈ្មោះសហគ្រាស ឬ ប្តូរម្ចាស់ជាញឹកញាប់, ភាពយឺតយ៉ាវក្នុងការជូនដំណឹងអំពី គ្រោះថ្នាក់ការងារជាដើម។ ការយល់ដឹងរបស់កម្មករនិយោជិតនៅមានកម្រិត ក្នុងនោះរួមមានការ ទាមទារតាវកាលិកចំពោះគ្រោះថ្នាក់មិនមែនការងារ, ការមិនមានសំបុត្រអាពាហ៍ពិពាហ៍, ការក្លែងបន្លំ សំបុត្រអាពាហ៍ពិពាហ៍ (ធ្វើសំបុត្រអាពាហ៍ពិពាហ៍ក្រោយពេលមរណភាព), កម្មករមួយចំនួនពុំមាន អត្តសញ្ញាណច្បាស់លាស់(ខ្ចីឈ្មោះអ្នកដទៃ, ប្រើឯកសារមិនប្រក្រតី ។ល។)។ រីឯការផ្តល់សេវាវេជ្ជ សាស្ត្ររបស់មន្ទីរពេទ្យ និងមន្ទីរព្យាបាលមួយចំនួនមានភាពជំអក់មិនសូវយកចិត្តទុកដាក់, មានការ ពន្លើសតម្លៃសេវា ឬការបង្កើតសេវាបន្ថែម, គុណភាពសេវានៅមានកំរិត, ហើយជាពិសេសគឺការ ប្រើពាក្យសម្តី ឬអាកប្បកិរិយាមិនសមរម្យរបស់គ្រូពេទ្យមកលើជនរងគ្រោះ។ ក្រៅពីកត្តាខាងក្រៅ ក៏នៅមានកត្តាខាងក្នុងរបស់ ប.ស.ស ផ្ទាល់ទាក់ទងគុណភាពនៃការផ្តល់សេវាជូនជនរងគ្រោះ, ការ យឺតយូរក្នុងការផ្តល់តាវកាលិកជាយថាហេតុ, សមត្ថភាពមន្ត្រីមួយចំនួននៅមានកំរិត, ប្រព័ន្ធគ្រប់គ្រង ទិន្នន័យមិនទាន់មានភាពរលូន។ល។ និង។ល។។ បញ្ហាទាំងអស់នេះវាមានទំនាក់ទំនងគ្នាទៅវិញ ទៅមក និងមានផលប៉ះពាល់ដល់ការអនុវត្តគោលនយោបាយធានារ៉ាប់រងហានិភ័យការងារ ពោលគឺ ការផ្តល់តាវកាលិកដល់ជនរងគ្រោះ។ ក្នុងគោលបំណងដោះស្រាយបញ្ហាប្រឈមទាំងនេះ បេឡា ជាតិរបបសន្តិសុខសង្គម បានដាក់ចេញនូវសកម្មភាពជាអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រ ដែល ពាក់ព័ន្ធនឹងការធ្វើឲ្យកាន់តែប្រសើរនូវរបបធានារ៉ាប់រងហានិភ័យការងារ។

ភាពច្បាស់លាស់, ការសម្របសម្រួល និងដោះស្រាយបានឆាប់រហ័ស ទាន់ពេលវេលា នឹង ត្រូវបានពង្រឹង ជាពិសេសការបណ្តុះបណ្តាលធនធានមនុស្ស, ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា, និង ការរៀបចំបែបបទ និងនីតិវិធីឲ្យបានកាន់តែល្អប្រសើរ ដើម្បីធានាដល់ការអនុវត្តរបបធានារ៉ាប់រង

ហានិភ័យការងារ ឲ្យមានប្រសិទ្ធភាព និងប្រកបដោយគុណភាព ស្របតាមការកើនឡើងនៃចំនួនសមាជិក ទំហំការងារ ឆ្លើយតបបានទៅនឹងស្ថានភាពនៃការរីកចំរើនសេដ្ឋកិច្ច សង្គម ទាំងនៅក្នុងប្រទេស និងក្នុងតំបន់។ ដោយពិនិត្យឃើញនូវបញ្ហាទាំងនេះ ទើបបេឡាជាតិរបបសន្តិសុខសង្គមកំណត់យកទិសដៅចំនួនបួនដូចខាងក្រោម៖

*១.១.* ពង្រីកវិសាលភាពរបបធានារ៉ាប់រងហានិភ័យការងារគ្របដណ្តប់ទូទាំងប្រទេស ដើម្បីឲ្យកម្មករនិយោជិត ដែលកំពុងបំរើការងារតាមបណ្តារាជធានី-ខេត្តទាំងអស់នៅទូទាំងប្រទេសទទួលបានការធានារ៉ាប់រងហានិភ័យការងារ ដូចដែលមានចែងនៅក្នុងច្បាប់។ នៅក្នុងការពង្រីកវិសាលភាពនេះ ប.ស.ស នឹងរៀបចំប្រជុំផ្សព្វផ្សាយពង្រីកវិសាលភាពតាមបណ្តាខេត្ត ដែលមិនទាន់បានអនុវត្តទៅដល់ និងចុះកិច្ចសន្យាជាមួយមូលដ្ឋានសុខាភិបាល ដើម្បីផ្តល់សេវាសុខាភិបាលដល់កម្មករនិយោជិតដែលជាសមាជិកនៃ ប.ស.ស ទទួលរងនូវគ្រោះថ្នាក់ការងារ។ មួយវិញទៀតត្រូវរៀបចំជ្រើសរើសមន្ត្រី និងបុគ្គលិកឲ្យបំពេញការងារ ដំឡើងប្រព័ន្ធគ្រប់គ្រង និងតភ្ជាប់បណ្តាញព័ត៌មានវិទ្យា និងបង្កើតការិយាល័យសាខា ប.ស.ស តាមបណ្តារាជធានី-ខេត្ត ឲ្យបានគ្របដណ្តប់នៅទូទាំងប្រទេស។

*១.២.* ពង្រឹង និងអភិវឌ្ឍរបបធានារ៉ាប់រងហានិភ័យការងារ ឲ្យបានកាន់តែល្អប្រសើរបន្ថែមទៀតតាមរយៈ៖

- ធ្វើការផ្សព្វផ្សាយឲ្យបានកាន់តែទូលំទូលាយបន្ថែមទៀត ទៅដល់ផ្នែកដែលពាក់ព័ន្ធជាពិសេសនិយោជក និងកម្មករនិយោជិត ឲ្យយល់ពីការអនុវត្តគោលនយោបាយធានារ៉ាប់រងហានិភ័យការងារ។
- ពង្រឹងការអនុវត្តច្បាប់ តាមរយៈការធ្វើអធិការកិច្ចតាមបណ្តាសហគ្រាស គ្រឹះស្ថាន ការចុះអង្កេតគ្រោះថ្នាក់ការងារ និងការចាត់វិធានការរដ្ឋបាលចំពោះសហគ្រាស គ្រឹះស្ថានដែលមិនព្រមអនុវត្តតាមច្បាប់។
- អភិវឌ្ឍនូវគោលនយោបាយធានារ៉ាប់រងហានិភ័យការងារ ដោយធ្វើការពិនិត្យលើចំណុចដែលមានចែងក្នុងលិខិតបទដ្ឋាន ប៉ុន្តែមិនទាន់បានអនុវត្តនៅឡើយ ដូចជាការកំណត់នីតិវិធី និងបែបបទនៃការទារបំណុលពីនិយោជក និងកម្មករនិយោជិត, ការរៀបចំគោលការណ៍ស្តីពីវិជ្ជាជីវៈសេរីការងារម្តងម្កាល ឬតាមរដូវ, ការរៀបចំគោលការណ៍ស្តីពីការគ្រប់គ្រងការិយភារីចំពោះរបបធានារ៉ាប់រងហានិភ័យការងារ, ការបណ្តុះបណ្តាលធនធានមនុស្ស, ការសិក្សាចងក្រងប្រភេទជំងឺវិជ្ជាជីវៈ, ការវិភាគការអនុវត្តរបបសន្តិសុខសង្គម, ការបង្កើតគណៈកម្មការវិនិយោគ និងការកែសម្រួលសមាសភាពតួនាទី ភារកិច្ចគណៈកម្មការវេជ្ជសាស្ត្រ។
- អភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀតស្របតាមស្តង់ដារអន្តរជាតិ, ការកើនឡើងនៃចំនួនសមាជិក និងទំហំការងារ លើប្រព័ន្ធនៃការគ្រប់គ្រងបញ្ជិកា ភាគទាន និងតាវកាលិក ប្រព័ន្ធគ្រប់គ្រងជាមួយអ្នកផ្តល់សេវាសុខាភិបាល និងធនាគារដៃគូ និងការបំពាក់ឧបករណ៍ ដំឡើងប្រព័ន្ធ បង្កើនសមត្ថភាព រៀបចំនីតិវិធី និងកែលំអហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាទាំងនៅថ្នាក់កណ្តាល និងតាមការិយាល័យសាខា ប.ស.ស រាជធានី-ខេត្ត។

*១.៣.* ចាត់វិធានការបង្ការគ្រោះថ្នាក់ការងារ ដើម្បីជៀសវាង ឬកាត់បន្ថយនូវករណីគ្រោះថ្នាក់ការងារចំពោះកម្មករនិយោជិត ដែលគ្រោះថ្នាក់ការងារនេះនាំឲ្យខាតបង់ដល់ការងារ ពេលវេលា ថវិកា និងជាយថាហេតុបណ្តាលឲ្យបាត់បង់ដល់អាយុជីវិតទៀតផង។ នៅលើការងារនេះ ប.ស.ស បានរៀបចំផែនការការងារ ការសិក្សាចងក្រងស្ថិតិគ្រោះថ្នាក់ការងារ និងសហការជាមួយដៃគូពាក់ព័ន្ធជាពិសេសក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) និងគណៈកម្មការសិក្សាស្រាវជ្រាវ ទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិតតាមបណ្តាសហគ្រាស គ្រឹះស្ថាន (ស.ទ.ប.ក) ក្នុងការរៀបចំវិធានការបង្ការ ទប់ស្កាត់ និងសង្គ្រោះបន្ទាន់ករណីគ្រោះថ្នាក់ការងារ, ការធ្វើសិក្ខាសាលា និងកិច្ចប្រជុំពិគ្រោះយោបល់, ការផ្សព្វផ្សាយ និងពន្យល់ណែនាំ, ការចាត់វិធានការផ្នែកសន្តិសុខការងារ និងអនាម័យ និងការចុះពិនិត្យផ្ទាល់ និងជួយសម្របសម្រួលករណីគ្រោះថ្នាក់ការងារឲ្យជនរងគ្រោះទទួលបានការសង្គ្រោះបន្ទាន់។

*១.៤.* ផ្តល់សេវាបុនរីតិសម្បទា ដល់កម្មករនិយោជិតដែលជាសមាជិកនៃ ប.ស.ស ទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ឲ្យទទួលបាននូវការស្តារកាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ ដើម្បីធានាលទ្ធភាពក្នុងការចូលរួមដ៏ពេញលេញ និងដោយស្មើភាពនៃជនរងគ្រោះក្នុងសកម្មភាពនានារបស់សង្គម តាមរយៈការរៀបចំយន្តការការងារ លើការបណ្តុះបណ្តាលធនធានមនុស្ស ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការសហការជាមួយដៃគូពាក់ព័ន្ធដើម្បីកំណត់ និងវាយតម្លៃការផ្តល់សេវា ការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងចុះកិច្ចសន្យាជាមួយអង្គភាពផ្តល់សេវាបុនរីតិសម្បទា នៅតាមបណ្តារាជធានី-ខេត្ត។

## ២. គោលដៅទី២. ដំណើរការរបបធានារ៉ាប់រងសុខភាព

បន្ទាប់ពីបានអនុវត្តដោយជោគជ័យនូវជំហានទី១ របបធានារ៉ាប់រងហានិភ័យការងារ និងដោយយោងទៅលើស្ថានភាពរីកចំរើននៃសេដ្ឋកិច្ចជាតិ ដែលក្នុងនោះមានការកើនឡើងជាច្រើននូវការវិនិយោគក្នុងប្រទេស និងកម្មករនិយោជិតដែលបម្រើការងារនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន ហើយដែលការរីកចំរើននេះទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់អំពីបញ្ហាលក្ខខណ្ឌការងារ ជាពិសេសបញ្ហាសុខភាពរបស់កម្មករនិយោជិត ជាក់ស្តែងនាប៉ុន្មានឆ្នាំចុងក្រោយនេះមានបាតុភាពករណីដួលសន្លប់កម្មករនិយោជិតនៅក្នុងសហគ្រាស គ្រឹះស្ថាន តាមបណ្តារាជធានី-ខេត្តមួយចំនួន ដែលនៅឆ្នាំ២០១២ កន្លងទៅមានករណីកម្មករដួលសន្លប់ចំនួន ១១,៧ ភាគរយ នៃចំនួនគ្រោះថ្នាក់ការងារសរុប ដែលករណីនេះមួយចំនួនធំត្រូវបានរកឃើញថាមានការពាក់ព័ន្ធទៅនឹងបញ្ហាសុខភាព និងរបបអាហាររបស់កម្មករនិយោជិតផ្ទាល់ ជាពិសេសឥរិយាបថនៃការរស់នៅខ្វះអនាម័យ, កំរិតវប្បធម៌ទាប, ការសន្សំសំចៃ, ការអត់ទ្រាំមិនហ៊ានទៅពិនិត្យសុខភាពដោយសារសេវាវេជ្ជសាស្ត្រមានតម្លៃខ្ពស់។ ក្រៅពីករណីសន្លប់ ក៏នៅមានករណីគ្រោះថ្នាក់កម្មករនិយោជិតជាច្រើនទៀត ដែលមិនមែនជាគ្រោះថ្នាក់ការងារ បានទៅទទួលសេវាព្យាបាលនៅតាមមន្ទីរពេទ្យដែលបានចុះកិច្ចសន្យា ក៏ដូចជាបានរាយការណ៍ និងមិនបានរាយការណ៍មកបេឡាជាតិរបបសន្តិសុខសង្គម ទាក់ទងទៅនឹងបញ្ហាសុខភាពស្ថិតនៅក្នុងស្ថានភាពមួយគួរឲ្យព្រួយបារម្ភ។ ស្ថានភាពទាំងនេះបានធ្វើឲ្យមានផលប៉ះពាល់

យ៉ាងខ្លាំងចំពោះសុខភាពកម្មករនិយោជិតដែលជាជនរងគ្រោះ ដែលត្រូវទទួលបន្ទុកចំណាយថវិកាក្នុងការព្យាបាលខ្លួន ហើយស្ថានភាពនេះវានឹងមានផលប៉ះពាល់កាន់តែខ្លាំងថែមទៀត បើសិនជាមានគ្រោះថ្នាក់ ឬ បញ្ហាសុខភាពរហូតដល់បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ឬ បាត់បង់ជីវិតនោះដល់គ្រួសាររបស់ជនរងគ្រោះ និងសង្គមទាំងមូល ដែលត្រូវទទួលបន្ទុកថែទាំជនពិការ ប្ដី/ប្រពន្ធ កូន ឬជនចាស់ជរាក្នុងបន្ទុក។

តាមរយៈបទពិសោធន៍ប្រកបដោយជោគជ័យ និងដោយយោលទៅលើស្ថានភាពចាំបាច់ដែលត្រូវដោះស្រាយចំពោះមុខខាងលើ និងដោយទទួលបានចំណារឯកភាពដ៏ខ្ពង់ខ្ពស់ពី **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងដោយអនុលោមតាមអនុក្រឹត្យលេខ១៦ អនក្រ/បក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម យើងនឹងរៀបចំដាក់ឲ្យដំណើរការជំហានទី២ គឺរបបធានារ៉ាប់រងសុខភាពឲ្យបាននៅឆ្នាំ២០១៣ នេះ ដើម្បីឲ្យកម្មករនិយោជិតទទួលបាននូវការថែទាំ និងព្យាបាលសុខភាព ការពារប្រឆាំងនឹងការប្រថុយប្រថាននៃការចំណាយលើមហន្តរាយផ្នែកសុខភាព និងការប្រឆាំងនឹងការខាតបង់ប្រាក់ចំណូល នៅពេលមានជំងឺ មាតុភាព និងយថាភាពផ្សេងៗទៀត ហើយផ្នែកនេះក៏នឹងត្រូវដាក់បញ្ចូលផងដែរ សមាជិកគ្រួសារក្នុងបន្ទុក រួមមានប្ដី/ប្រពន្ធ និងកុមារជាដើម។

ម្យ៉ាងទៀត ដោយសារប្រទេសកម្ពុជាជាសមាជិកអាស៊ាន ការបង្កើតឲ្យមានរបបធានារ៉ាប់រងសុខភាព គឺជាការត្រៀមលក្ខណៈក្នុងការធ្វើសមាហរណកម្មចូលសហគមន៍អាស៊ាននាឆ្នាំ២០១៥ ខាងមុខផងដែរ ព្រោះថាបណ្ដាប្រទេសសមាជិកអាស៊ានសុទ្ធតែមានប្រព័ន្ធធានារ៉ាប់រងសុខភាពរួចហើយ។

ដើម្បីសម្រេចឲ្យបាននូវការផ្ដល់របបធានារ៉ាប់រងសុខភាពនេះ ប.ស.ស បានកំណត់ទិសដៅចំនួន០៤ សម្រាប់អនុវត្តរួមមាន៖ ការសិក្សាស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានគតិយុត្ត ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា ការរៀបចំវិធីសាស្ត្រទូទាត់ថ្លៃសេវាសុខាភិបាល និងការផ្សព្វផ្សាយសាធារណៈ និងអនុវត្ត។

*២.១.* សិក្សាស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីរៀបចំដាក់ឲ្យដំណើរការរបបធានារ៉ាប់រងសុខភាព ដែលនៅជំហានដំបូងទាមទារឲ្យមានការសិក្សាស្រាវជ្រាវ ឲ្យបានល្អិតល្អន់ពីលទ្ធភាពនៃកិច្ចដំណើរការរបស់របបទាំងមូល និងត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ជាមូលដ្ឋានអនុវត្ត។ ការត្រៀមរៀបចំអនុវត្តជំហានទី២ កន្លងមក ប.ស.ស បានបង្កើតក្រុមការងាររៀបចំដាក់ឲ្យដំណើរការរបបធានារ៉ាប់រងសុខភាព តាមរយៈក្រុមការងារនេះការត្រៀមរៀបចំអនុវត្តការងារសម្រេចបានលទ្ធផលគួរឲ្យកត់សំគាល់ ជាបន្តបន្ទាប់មកសម្រាប់ឆ្នាំ២០១៣ នេះ ប.ស.ស បានរៀបចំការងារនេះឲ្យទៅជាផែនការយុទ្ធសាស្ត្រ ដែលមានគោលដៅ និងទិសដៅច្បាស់លាស់ ហើយបន្តអនុវត្តការងារដែលនៅសេសសល់ និងបញ្ចូលបន្ថែមនូវការងារមួយចំនួនទៀតដែលនៅខ្វះចន្លោះដែលមានសកម្មភាព ពេលវេលា និងសូចនាករសម្រាប់វាស់វែងដ៏ជាក់លាក់។

ឆ្លើយតបទៅនឹងទិសដៅខាងលើ សកម្មភាពមួយចំនួនត្រូវបានអនុវត្តដោយបន្តរៀបចំប្រជុំក្រុមការងារជាប្រចាំដើម្បីពិភាក្សា និងត្រួតពិនិត្យមើលការងារដែលសម្រេចបាន ភាពខ្វះចន្លោះ និង

បញ្ហាប្រឈម ដើម្បីស្វែងរកដំណោះស្រាយ និងលើកផែនការអនុវត្តបន្ត ព្រមទាំងរៀបចំឲ្យមានការបណ្តុះបណ្តាលមន្ត្រី និងបុគ្គលិកឲ្យមានសមត្ថភាពត្រូវនឹងការអនុវត្តការងារជាក់ស្តែង។ មួយវិញទៀតនឹងរៀបចំឲ្យមានការអង្កេត និងសិក្សាស្រាវជ្រាវ ឲ្យបានច្បាស់លាស់ទាក់ទងនឹងស្ថានភាពរបស់អ្នកផ្តល់សេវា សហគ្រាស គ្រឹះស្ថាន និងស្ថានភាពសុខភាពរបស់កម្មករនិយោជិត ដើម្បីឲ្យការអនុវត្តមានប្រសិទ្ធភាព និងចំគោលដៅ និងធ្វើសិក្ខាសាលា កិច្ចប្រជុំពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធ ប្រមូលផ្តុំគំនិតយោបល់ និងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ជាមូលដ្ឋានអនុវត្តន៍។

*២.២.* រៀបចំប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការអនុវត្តរបបធានារ៉ាប់រងសុខភាព ដែលប្រព័ន្ធព័ត៌មានវិទ្យានេះ ជាខួរក្បាលរបស់បេឡាជាតិរបបសន្តិសុខសង្គម សម្រាប់ការអនុវត្តរបបសន្តិសុខសង្គម និងការគ្រប់គ្រងរបស់អង្គភាពទាំងមូល។ ការអនុវត្តរបបធានារ៉ាប់រងសុខភាព មានការលំបាកច្រើនដងជាងការអនុវត្តរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារ ដូចនេះតម្រូវឲ្យមានការរៀបចំនូវប្រព័ន្ធព័ត៌មានវិទ្យាឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីធានាដល់កិច្ចដំណើរការប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។ ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់របបធានារ៉ាប់រងសុខភាពនេះរួមមាន៖

- បង្កើតប្រព័ន្ធនៃការចុះបញ្ជិកា ការបង់ភាគទាន និងប្រព័ន្ធនៃការផ្តល់តាវកាលិក។
- សហការជាមួយក្រសួងមហាផ្ទៃ ដើម្បីកំណត់គោលដៅអត្តសញ្ញាណកម្មករនិយោជិតនៅក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ID Smart Card) និងបំពាក់ប្រព័ន្ធនៃការទទួលបណ្តឹងតវ៉ាពីសមាជិក (Complaint System) សម្រាប់កត់ត្រានូវសំណូមពរ និងបញ្ហាប្រឈមនានា ដើម្បីធ្វើការដោះស្រាយ និងកែសម្រួលឲ្យកាន់តែល្អប្រសើរឡើង។
- សិក្សាលទ្ធភាពផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងរួមរវាងរបបធានារ៉ាប់រងហានិភ័យការងារ និងរបបធានារ៉ាប់រងសុខភាព ដំឡើង និងរៀបចំបន្ទប់ទិន្នន័យតភ្ជាប់រវាងប្រព័ន្ធគ្រប់គ្រងរបបធានារ៉ាប់រងសុខភាពជាមួយនឹងប្រព័ន្ធគ្រប់គ្រងគណនេយ្យ បង្កើនល្បឿន ការបញ្ជូនទិន្នន័យរវាងស្នាក់ការកណ្តាល និងការិយាល័យសាខា និងរៀបចំនីតិវិធី និងបំពាក់ឧបករណ៍ត្រួតពិនិត្យប្រព័ន្ធ។

*២.៣.* រៀបចំវិធីសាស្ត្រទូទាត់ថ្លៃសេវាសុខាភិបាល ដើម្បីធានានូវនិរន្តរភាពនៃការអនុវត្តគម្រោងរបបធានារ៉ាប់រងសុខភាព ដែលវាទាក់ទងជាពិសេសជាមួយអ្នកផ្តល់ និងអ្នកទៅទទួលសេវាសុខាភិបាល ហើយបញ្ហានេះជាចំនុចសំខាន់នៅក្នុងការអនុវត្តរបបធានារ៉ាប់រងសុខភាពរបស់អង្គភាពសន្តិសុខសង្គមទាំងឡាយ ព្រោះវាទាក់ទងទៅនឹងស្ថិរភាព និងនិរន្តរភាពរបស់គម្រោងទាំងមូល។ ដូចនេះវាទាមទារឲ្យមានការរៀបចំវិធីសាស្ត្រឲ្យបានត្រឹមត្រូវ នូវយន្តការទូទាត់ថ្លៃសេវាសុខាភិបាលដែលមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ។ មួយវិញទៀត ដើម្បីធានាដល់ការផ្តល់សេវាបានល្អ និងកាត់បន្ថយបាននូវការប្រើ ឬផ្តល់សេវាមិនចំគោលដៅ ត្រូវរៀបចំប្រព័ន្ធនៃការទូទាត់ថ្លៃសេវាសុខាភិបាលឲ្យបានច្បាស់លាស់ បំពាក់ប្រព័ន្ធត្រួតពិនិត្យសុពលភាពនៃសមាជិកនៅតាមមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចសន្យា និងដាក់ភ្នាក់ងារ ប.ស.ស ប្រចាំការនៅតាមមូលដ្ឋានសុខាភិបាលទាំងនោះ សម្រាប់ជួយសម្របសម្រួលការងារប្រចាំថ្ងៃ។

*២.៤.* ផ្សព្វផ្សាយសាធារណៈ និងអនុវត្ត ដើម្បីឲ្យភាគីពាក់ព័ន្ធទាំងអស់បានដឹង និងយល់ពីនីតិវិធី និងបែបបទនៃការអនុវត្តរបបធានារ៉ាប់រងសុខភាពតាមរយៈ ការធ្វើសេចក្តីជូនដំណឹង ធ្វើសិក្ខាសាលា ប្រជុំផ្សព្វផ្សាយ ផលិតស្ប៉ត និងខិត្តប័ណ្ណផ្សព្វផ្សាយស្តីពីការអនុវត្តរបបធានារ៉ាប់រងសុខភាព ដើម្បីផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ។

បន្ទាប់ពីការរៀបចំនូវនីតិវិធី និងបែបបទការងារ បានគ្រប់ជ្រុងជ្រោយ បេឡាជាតិរបបសន្តិសុខសង្គម នឹងអនុវត្តនូវការចុះបញ្ជិកា និងប្រមូលភាគទានសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត និងផ្តល់តាវកាលិករបបធានារ៉ាប់រងសុខភាពដល់សមាជិក។

## ៣. គោលដៅទី៣. ដំណើរការរបបប្រាក់សោធន

របបប្រាក់សោធន លើវិស័យសាធារណៈសម្រាប់មន្ត្រីរាជការស៊ីវិល អនុវត្តដោយបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ចំពោះរបបសោធនសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារអនុវត្តដោយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ របបនេះគ្របដណ្តប់លើតាវកាលិក សោធនជរាភាព វិភាជន៍ជរាភាព សោធនទុព្វលភាព សោធនចំពោះអ្នកនៅក្នុងបន្ទុក និងវិភាជន៍ចំពោះអ្នកនៅក្នុងបន្ទុក ដែលរបបនេះជារឿងថ្មីដូចរបបធានារ៉ាប់រងសុខភាពផងដែរ សម្រាប់ប្រទេសកម្ពុជាយើង។ ដូច្នេះ នៅពេលដែលរបបនេះដំណើរការកម្មករនិយោជិត ដែលធ្វើការក្នុងវិស័យឯកជននឹងត្រូវទទួលបានរបបប្រាក់សោធន ដូចមន្ត្រីរាជការផងដែរ។

ការបង្កើតឲ្យមានរបបប្រាក់សោធនសម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន បង្ហាញឲ្យឃើញនូវការខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជាចំពោះអនាគតនៃកម្លាំងពលកម្មសកម្មនាពេលបច្ចុប្បន្ន និង ម្យ៉ាងទៀតក៏ជាការរួមចំណែកលើកកម្ពស់ផលិតភាពពលកម្មផងដែរ ព្រោះថាតាមរយៈយន្តការនេះ កម្លាំងពលកម្មសកម្មបច្ចុប្បន្ន មានភាពកក់ក្តៅក្នុងចិត្តចំពោះអនាគតរបស់ខ្លួនទោះកំពុងធ្វើការក្នុងវិស័យឯកជនក្តី។ លើសពីនេះថែមទៀតគោលនយោបាយនេះ រួមចំណែកលើកស្ទួយចំពោះការលើកទឹកចិត្តដល់កម្លាំងពលកម្មទាំងក្នុងផ្នែកឯកជន និងសាធារណៈ ពោលគឺការលុបបំបាត់នូវផ្នត់គំនិតដែលយល់ថា ធ្វើការជាកម្មករនិយោជិតផ្នែកឯកជនមិនមានប្រាក់សោធនហើយមានតែមន្ត្រីរាជការក្នុងមុខងារសាធារណៈទេដែលមានរបបប្រាក់សោធន។ គោលនយោបាយប្រាក់សោធន ធានាទាំងស្រុងនូវសិទ្ធិកម្មករនិយោជិតក្នុងវ័យជរាភាពរបស់ពួកគេ ព្រោះថាគេអាចមានលទ្ធភាពរស់នៅដោយខ្លួនឯងបាន ដោយមិនអាស្រ័យទាំងស្រុងលើការចិញ្ចឹមពីកូនចៅនោះឡើយ។

នៅក្នុងការរៀបចំដាក់ឲ្យដំណើររបបប្រាក់សោធននេះ បេឡាជាតិរបបសន្តិសុខសង្គម មានទិសដៅ៖

*៣.១.* សិក្សាលទ្ធភាពដាក់ឲ្យដំណើរការរបបប្រាក់សោធន តាមរយៈការរៀបចំយន្តការរបបប្រាក់សោធន ដោយបង្កើតក្រុមការងារសិក្សាស្រាវជ្រាវរៀបចំដាក់ឲ្យដំណើរការរបបប្រាក់សោធន

ដើម្បីឲ្យមានអង្គភាពទទួលខុសត្រូវ និងធានាបាននូវលទ្ធផលការងារតាមការគ្រោងទុក។ ការសិក្សាលទ្ធភាពនេះផងដែរក៏នឹងត្រូវធ្វើសិក្ខាសាលា និងកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយដៃគូពាក់ព័ន្ធទាំងអស់ ប្រមូលផ្តុំនូវគំនិតយោបល់ និងបទពិសោធន៍ការងារ សម្រាប់ជាមូលដ្ឋាននៃការរៀបចំ និងធ្វើការវិភាគវាយតម្លៃលើការអនុវត្តគម្រោងទាំងមូល ដើម្បីធានាបាននូវស្ថិរភាពនៃហិរញ្ញវត្ថុប្រាក់សោធន។

*៣.២.* រៀបចំលិខិតបទដ្ឋានគតិយុត្ត និងបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់ជាមូលដ្ឋានអនុវត្ត និងលើកកំពស់សមត្ថភាពមន្ត្រី បុគ្គលិកឲ្យមានចំណេះដឹង និងសមត្ថភាពពិតប្រាកដក្នុងការផ្តល់សេវារបបប្រាក់សោធនបានល្អប្រសើរ ជូនដល់សមាជិក។ ការរៀបចំលិខិតបទដ្ឋានគតិយុត្តនេះទាក់ទងទៅនឹងការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការចុះបញ្ជិកា ការបង់ភាគទាន ការផ្តល់តាវកាលិក និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀតសម្រាប់ជាមូលដ្ឋាន នៃការអនុវត្តគម្រោង ហើយដើម្បីឲ្យការរៀបចំសេចក្តីព្រាងប្រកាសនេះមានខ្លឹមសារគ្រប់ជ្រុងជ្រោយ ទទួលបានប្រសិទ្ធភាពក្នុងការអនុវត្ត វាត្រូវមានការចូលរួមពីផ្នែកពាក់ព័ន្ធទាំងអស់ តាមរយៈការធ្វើសិក្ខាសាលា ឬ កិច្ចប្រជុំពិគ្រោះយោបល់ជាមួយគ្នា ដើម្បីប្រមូលផ្តុំនូវគំនិតយោបល់ ដាក់បញ្ចូលទៅក្នុងលិខិតបទដ្ឋានគតិយុត្តទាំងនោះ ដែលការចូលរួមនេះមានសារៈសំខាន់ណាស់ ហើយវាត្រូវតែមាននូវគ្រប់ដំណាក់កាលទាំងអស់ នៃការរៀបចំអនុវត្តគម្រោងនីមួយៗ។

*៣.៣.* រៀបចំប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការអនុវត្តរបបប្រាក់សោធន ដែលប្រព័ន្ធព័ត៌មានវិទ្យានេះមានភាពចាំបាច់បំផុតសម្រាប់ការគ្រប់គ្រងរបបធានារ៉ាប់រងនីមួយៗ របស់បេឡាជាតិរបបសន្តិសុខសង្គម រួមទាំងរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារ របបធានារ៉ាប់រងសុខភាព និងរបបប្រាក់សោធននេះ ជាពិសេសលើប្រព័ន្ធនៃការចុះបញ្ជិកា ការបង់ភាគទាន ការផ្តល់តាវកាលិកជូនជនរងគ្រោះ និងប្រព័ន្ធគណនេយ្យនៅតាមធនាគារដៃគូ។ មួយវិញទៀត ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យានេះក៏ត្រូវឲ្យមានការចូលរួម និងសហការពីសំណាក់អ្នកជំនាញការជាតិ ឬ អន្តរជាតិក្នុងការប្រមូលទិន្នន័យសម្រាប់ការវិភាគ និងវាយតម្លៃឲ្យបានស៊ីជម្រៅ ដើម្បីឈានដល់ការកសាងមូលដ្ឋានទិន្នន័យមួយដ៏មានប្រសិទ្ធភាពបំផុត សម្រាប់ការផ្តល់របបប្រាក់សោធន។

*៣.៤.* ផ្សព្វផ្សាយសាធារណៈ និងអនុវត្ត តាមរយៈធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ ដើម្បីឲ្យផ្នែកពាក់ព័ន្ធទាំងអស់ ជាពិសេសម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត យល់ដឹងពីការអនុវត្តគោលនយោបាយរបបប្រាក់សោធន និងអនុវត្តនូវការប្រមូលភាគទានសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត សម្រាប់ត្រៀមផ្តល់តាវកាលិកដល់សមាជិកដែលមានសិទ្ធិទទួលនូវប្រាក់សោធននាពេលអនាគត។

# តារាងម៉ាទ្រិចផែនការយុទ្ធសាស្ត្រ
# បេឡាជាតិរបបសន្តិសុខសង្គម
# ឆ្នាំ ២០១៣-២០១៥

| ទិសដៅ | សកម្មភាព | សូចនាករ | ឆ្នាំអនុវត្ត | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|
| | | | ២០១៣ | ២០១៤ | ២០១៥ | |
| **គោលដៅទី១៖ ពង្រីក និងពង្រឹងការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ** | | | | | | |
| ពង្រីកវិសាលភាពរបបធានារ៉ាប់រងហានិភ័យការងារគ្របដណ្តប់ទូទាំងប្រទេស | ប្រជុំផ្សព្វផ្សាយ ពង្រីកវិសាលភាពការអនុវត្តគោលនយោបាយរបបធានារ៉ាប់រងហានិភ័យការងារតាមបណ្តាខេត្តដែលនៅសេសសល់ | ចំនួនកិច្ចប្រជុំផ្សព្វផ្សាយនៅតាមបណ្តាខេត្ត | ប្រជុំចំនួន ៤ លើកនៅខេត្តរតនគិរី មណ្ឌលគិរី ព្រះវិហារ និងឧត្តរមានជ័យ | | | ប.ស.ស |
| | បង្កើតការិយាល័យសាខា ប.ស.ស តាមបណ្តារាជធានី-ខេត្ត | ចំនួនការិយាល័យសាខា ប.ស.ស នៅតាមបណ្តារាជធានី-ខេត្ត, ក្រុង និងខណ្ឌ | ចំនួនការិយាល័យ ១០ ខេត្ត | ចំនួនការិយាល័យ១០ខេត្ត និងខណ្ឌ ០៤ | ចំនួនការិយាល័យ០៣ ខេត្ត | ប.ស.ស |
| | ចុះកិច្ចសន្យាជាមួយមូលដ្ឋានសុខាភិបាលនៅតាមបណ្តារាជធានី-ខេត្ត | ចំនួនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចសន្យា | ៦០ | ៧០ | ៨០ | ប.ស.ស |
| | ដំឡើងប្រព័ន្ធគ្រប់គ្រង និងតភ្ជាប់បណ្តាញព័ត៌មានវិទ្យា នៅតាមការិយាល័យសាខា ប.ស.ស រាជធានី-ខេត្ត | ប្រសិទ្ធភាពក្នុងការគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាតាមបណ្តារាជធានី-ខេត្ត | ៧០% | ៩០% | ៩៩% | ប.ស.ស |
| | ជ្រើសរើស និងចាត់តាំងមន្ត្រី និងបុគ្គលិកឲ្យបំពេញការងារនៅតាមការិយាល័យសាខា ប.ស.ស រាជធានី-ខេត្ត | ចំនួនមន្ត្រី និងបុគ្គលិកនៅតាមការិយាល័យសាខា ប.ស.ស រាជធានី-ខេត្ត | ៩៤ នាក់ | ១៥០ នាក់ | ២០០ នាក់ | ប.ស.ស |

| | | | | | | |
|---|---|---|---|---|---|---|
| | ផ្សព្វផ្សាយការអនុវត្តគោលនយោបាយរបបធានារ៉ាប់រងហានិភ័យការងារ | ចំនួនសិក្ខាសាលា និងកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលការងារប្រចាំឆ្នាំ និងពង្រឹងការអនុវត្តបន្ថែម | ប្រជុំបូកសរុប ១ លើក ប្រជុំពង្រឹងការអនុវត្តបន្ថែម ៩ លើក | ប្រជុំបូកសរុប ១ លើក ប្រជុំពង្រឹងការអនុវត្តបន្ថែម ១២ លើក | ប្រជុំបូកសរុប ១ លើក ប្រជុំពង្រឹងការអនុវត្តបន្ថែម ១២ លើក | ប.ស.ស |
| | ធ្វើអធិការកិច្ចតាមបណ្តាសហគ្រាស គ្រឹះស្ថាន | អគ្រាសហគ្រាស គ្រឹះស្ថានចុះបញ្ជិកាកម្មករនិយោជិត និងបង់ភាគទាន | ៨៧% | ៨៩ % | ៩១ % | ប.ស.ស |
| | អង្កេតគ្រោះថ្នាក់ការងារ | ចំនួនកម្មករនិយោជិតរងគ្រោះថ្នាក់ការងារទទួលបានតាវកាលិកតាមច្បាប់ | ១៤.០០០ នាក់ | ១៣.៥០០ នាក់ | ១៣.០០០ នាក់ | ប.ស.ស |
| ពង្រឹង និងអភិវឌ្ឍរបបធានារ៉ាប់រងហានិភ័យការងារ | ចាត់វិធានការរដ្ឋបាលចំពោះសហគ្រាស គ្រឹះស្ថានដែលមិនព្រមអនុវត្តតាមច្បាប់ | អគ្រាសហគ្រាស គ្រឹះស្ថាន អនុវត្តតាមច្បាប់បានល្អប្រសើរ | ៨៧% | ៨៩ % | ៩១ % | ប.ស.ស |
| | កំណត់នីតិវិធី និងបែបបទនៃការទារបំណុលពីនិយោជក និងកម្មករនិយោជិត | ដំណើរការនៃការរៀបចំប្រកាសស្តីពីនីតិវិធី និងបែបបទ នៃការទារបំណុលរបស់ ប.ស.ស | ៥០ % | ១០០ % | | ប.ស.ស |
| | រៀបចំគោលការណ៍ស្តីពីវិជ្ជាជីវៈសេរីការងារម្តងម្កាល ឬតាមរដូវ | ដំណើរការនៃការរៀបចំប្រកាសស្តីពីការធានារ៉ាប់រងហានិភ័យការងារចំពោះអ្នកប្រកបវិជ្ជាជីវៈសេរីការងារម្តងម្កាល ឬតាមរដូវ | ៥០ % | ១០០ % | | ប.ស.ស |
| | រៀបចំគោលការណ៍ស្តីពីការគ្រប់គ្រងការិយភារីចំពោះរបបធានារ៉ាប់រងហានិភ័យការងារ | ដំណើរការនៃការរៀបចំប្រកាសស្តីពីការគ្រប់គ្រងការិយភារី | ៥០ % | ១០០ % | | ប.ស.ស |
| | បណ្តុះបណ្តាលធនធានមនុស្ស | អគ្រាមន្ត្រី និងបុគ្គលិក មានសមត្ថភាព និងគុណភាពក្នុងការផ្តល់សេវាជូនសមាជិក | ៩២ % | ៩៤ % | ៩៦ % | ប.ស.ស |

| | | | | | | |
|---|---|---|---|---|---|---|
| ពង្រឹង និងអភិវឌ្ឍ របបធានារ៉ាប់រងហានិភ័យការងារ | សិក្សាចងក្រងប្រភេទជំងឺវិជ្ជាជីវៈ | ដំណើរការនៃការរៀបចំប្រកាសអន្តរក្រសួងស្តីពីការកំណត់ប្រភេទជំងឺវិជ្ជាជីវៈ | ៧០ % | ១០០ % | | ប.ស.ស |
| | វិភាគការអនុវត្តរបបសន្តិសុខសង្គម | ប្រសិទ្ធភាពនៃការអនុវត្តរបបសន្តិសុខសង្គម | ៩០ % | ៩២ % | ៩៤ % | ប.ស.ស |
| | បង្កើតគណៈកម្មការវិនិយោគ | ដំណើរការ នៃការរៀបចំបង្កើតគណៈកម្មការវិនិយោគ | ១០០ % | | | ប.ស.ស |
| | កែសម្រួលសមាសភាព តួនាទីភារកិច្ចគណៈកម្មការវេជ្ជសាស្ត្រ | ប្រសិទ្ធភាព នៃការបំពេញភារកិច្ច និងតួនាទី ធានាបានទាំងសម្រាប់របបធានារ៉ាប់រងហានិភ័យការងារ និងសុខភាពកាន់តែប្រសើរ | ៩០ % | ៩៥% | ៩៩% | ប.ស.ស |
| | ធ្វើឲ្យកាន់តែប្រសើរប្រព័ន្ធគ្រប់គ្រងបញ្ជិកា និងភាគទានកម្មករនិយោជិត និងសហគ្រាសគ្រឹះស្ថាន | ប្រសិទ្ធភាព នៃការគ្រប់គ្រងប្រព័ន្ធបញ្ជិកា និងភាគទានកម្មករនិយោជិត និងសហគ្រាស គ្រឹះស្ថាន | ៩០ % | ៩៥ % | ៩៩% | ប.ស.ស |
| | ធ្វើឲ្យកាន់តែប្រសើរប្រព័ន្ធគ្រប់គ្រងតាវកាលិក | ប្រសិទ្ធភាព នៃការផ្តល់តាវកាលិកជូនជនរងគ្រោះ | ៩០ % | ៩៤ % | ៩៧ % | ប.ស.ស |
| | ដំឡើងប្រព័ន្ធ SMS សម្រាប់កម្មករនិយោជិត | ដំណើរការនៃការរៀបចំដំឡើងប្រព័ន្ធ SMS | ៥០ % | ១០០ % | | ប.ស.ស |
| | រៀបចំប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់សេវាសុខាភិបាល | ប្រសិទ្ធភាព នៃការទូទាត់ និងការប្រើប្រាស់សេវាសុខាភិបាល | ៨០ % | ៨៥ % | ៩០ % | ប.ស.ស |
| | បំពាក់ឧបករណ៍សន្តិសុខទិន្នន័យបន្ថែមនៅស្នាក់ការកណ្តាល | សុវត្ថិភាពនៃការការពារពីការជ្រៀតជ្រែក និងការរំខានពីខាងក្រៅ | ៩០ % | ៩៥ % | ១០០ % | ប.ស.ស |
| | បង្កើនសមត្ថភាពឧបករណ៍ផ្ទុកទិន្នន័យ | ប្រសិទ្ធភាពនៃការផ្ទុកទិន្នន័យ និងប្រព័ន្ធដំណើរការបានល្អ | ៧០ % | ៩០ % | ៩៩ % | ប.ស.ស |
| | រៀបចំ និងកែលំអហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា | ប្រសិទ្ធភាព នៃការបញ្ជូនទិន្នន័យ | ៩០ % | ៩៣ % | ៩៥% | ប.ស.ស |

| | | | | | | |
|---|---|---|---|---|---|---|
| | សិក្សាអំពីលទ្ធភាពភ្ជាប់បណ្តាញព័ត៌មានវិទ្យាជាមួយនឹងធនាគារដៃគូ | ដំណើរការនៃការភ្ជាប់បណ្តាញព័ត៌មានវិទ្យាជាមួយនឹងធនាគារដៃគូ | ៥០ % | ៧០ % | ១០០ % | ប.ស.ស |
| | រៀបចំនីតិវិធី និងគោលនយោបាយអនុវត្តសម្រាប់ការប្រើប្រាស់ឧបករណ៍ និងប្រព័ន្ធព័ត៌មានវិទ្យា | ប្រសិទ្ធភាពនៃការប្រើប្រាស់ឧបករណ៍ និងប្រព័ន្ធព័ត៌មានវិទ្យា | ៨០ % | ៩០ % | ៩៧ % | ប.ស.ស |
| | រៀបចំផែនការស្តីពីការថែទាំ និងជួសជុលឧបករណ៍ព័ត៌មានវិទ្យា | ដំណើរការនៃការរៀបចំផែនការ | ១០០ % | | | ប.ស.ស |
| ចាត់វិធានការបង្ការគ្រោះថ្នាក់ការងារ | សិក្សាចងក្រងស្ថិតិគ្រោះថ្នាក់ការងារ | ដំណើរការ នៃការសិក្សាចងក្រងស្ថិតិគ្រោះថ្នាក់ការងារ | ៧០ % | ១០០ % | | ប.ស.ស |
| | បង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត | ដំណើរការនៃការរៀបចំបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត | ១០០% | | | ប.ស.ស និង ក្រសួង ក.ប |
| | ប្រជុំពិគ្រោះយោបល់ ជាមួយដៃគូពាក់ព័ន្ធ រៀបចំវិធានការបង្ការ ទប់ស្កាត់ និងសង្គ្រោះបន្ទាន់ករណីគ្រោះថ្នាក់ការងារ | ចំនួនប្រជុំពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធ | ១០ លើក | ១០ លើក | ១០ លើក | ប.ស.ស និង គណៈកម្មការ ស.ទ.ប.ក |
| | ផ្សព្វផ្សាយ និងពន្យល់ណែនាំពីវិធានការបង្ការ ទប់ស្កាត់ និងសង្គ្រោះបន្ទាន់ករណីគ្រោះថ្នាក់ការងារ ទៅដល់និយោជក កម្មករនិយោជិត និងដៃគូពាក់ព័ន្ធនានា | ចំនួនប្រជុំផ្សព្វផ្សាយ និងពន្យល់ណែនាំ | ១២ លើក | ១២ លើក | ១២ លើក | ប.ស.ស និង គណៈកម្មការ ស.ទ.ប.ក |
| | សហការជាមួយដៃគូពាក់ព័ន្ធ ចាត់វិធានការផ្នែកសន្តិសុខការងារ អនាម័យ និងសង្គ្រោះបន្ទាន់ករណីគ្រោះថ្នាក់ការងារ | អត្រាកាត់បន្ថយបាននូវករណីគ្រោះថ្នាក់ការងារ | ១,៧៥ % | ១,៥៨ % | ១,៤៤% | ប.ស.ស និង គណៈកម្មការ ស.ទ.ប.ក |
| | ចុះពិនិត្យផ្ទាល់ និងជួយសម្របសម្រួលករណីគ្រោះថ្នាក់ការងារឲ្យជនរងគ្រោះទទួលបានការសង្គ្រោះបន្ទាន់ | ប្រសិទ្ធភាពនៃការទទួលបានការសង្គ្រោះបន្ទាន់ | ៩២% | ៩៤ % | ៩៦ % | ប.ស.ស និង គណៈកម្មការ ស.ទ.ប.ក |

| | | | | | | |
|---|---|---|---|---|---|---|
| ផ្តល់សេវាបុននីតិសម្បទា | បង្កើតយន្តការរៀបចំការផ្តល់សេវាបុននីតិសម្បទា | ដំណើរការនៃការរៀបចំយន្តការសេវាបុននីតិសម្បទា | ៧០ % | ១០០% | | ប.ស.ស |
| | បណ្តុះបណ្តាលធនធានមនុស្សផ្នែកបុននីតិសម្បទា | ចំនួនមន្ត្រីទទួលបានការបណ្តុះបណ្តាលផ្នែកបុនីតិសម្បទា | ៥ នាក់ | ៧ នាក់ | ១០ នាក់ | ប.ស.ស |
| | រៀបចំលិខិតបទដ្ឋានគតិយុត្តបុននីតិសម្បទា | ដំណើរការរៀបចំលិខិតបទដ្ឋានគតិយុត្ត | ៧០ % | ១០០% | | ប.ស.ស |
| | សិក្សាស្រាវជ្រាវ និង សហការជាមួយដៃគូពាក់ព័ន្ធ | ដំណើរការនៃការសិក្សាស្រាវជ្រាវ | ៧០ % | ១០០% | | ប.ស.ស |
| | កំណត់ និងវាយតម្លៃអំពីស្ថានភាពបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ ដើម្បីផ្តល់សេវាបុននីតិសម្បទា | ប្រសិទ្ធភាព នៃការផ្តល់សេវាបុននីតិសម្បទា ជូនជនរងគ្រោះ | ៧០ % | ៩០% | ៩៥ % | ប.ស.ស |
| | បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យការផ្តល់សេវាបុននីតិសម្បទា | ដំណើរការ នៃការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ៧០ % | ១០០% | | ប.ស.ស |
| | ចុះកិច្ចសន្យាជាមួយអង្គភាពផ្តល់សេវាបុននីតិសម្បទា | ចំនួនអង្គភាពផ្តល់សេវាបុននីតិសម្បទា | ២ | ១៣ | ១៥ | ប.ស.ស |
| **គោលដៅទី២៖ ដំណើរការរបបធានារ៉ាប់រងសុខភាព** | | | | | | |
| សិក្សាស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានគតិយុត្ត | ប្រជុំក្រុមការងារ រៀបចំអនុវត្តរបបធានារ៉ាប់រងសុខភាព | ប្រសិទ្ធភាពនៃការរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីសម្រាប់អនុវត្ត | ៩៧% | | | ប.ស.ស |
| | បណ្តុះបណ្តាលធនធានមនុស្ស | ចំនួនមន្ត្រី និងបុគ្គលិកមានសមត្ថភាព | ៣៥ នាក់ | ១៥០ នាក់ | ២០០ នាក់ | ប.ស.ស |
| | ធ្វើការអង្កេត និងសិក្សាស្រាវជ្រាវ | ដំណើរការ នៃការអង្កេតនិងសិក្សាស្រាវជ្រាវ | ៩០% | ១០០% | | ប.ស.ស |
| | រៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការអនុវត្តរបបធានារ៉ាប់រងសុខភាព | ដំណើរការនៃការរៀបចំលិខិតបទដ្ឋានគតិយុត្ត | ៩០ % | ១០០% | | ប.ស.ស |

| | | | | | | |
|---|---|---|---|---|---|---|
| | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយដៃគូពាក់ព័ន្ធ ដើម្បីប្រមូលនូវគំនិតយោបល់ និងបទពិសោធន៍ | ចំនួនកិច្ចប្រជុំពិគ្រោះយោបល់ | ១៥ លើក | ១០ លើក | | ប.ស.ស |
| រៀបចំប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការអនុវត្ត របបធានារ៉ាប់រងសុខភាព | បង្កើតប្រព័ន្ធនៃការចុះបញ្ជិកា និងបង់ភាគទាន សម្រាប់របបធានារ៉ាប់រងសុខភាព | ដំណើរការ នៃការរៀបចំប្រព័ន្ធគ្រប់គ្រងការចុះបញ្ជិកា និងបង់ភាគទាន សម្រាប់របបធានារ៉ាប់រងសុខភាព | ៩០% | ១០០% | | ប.ស.ស |
| | រៀបចំប្រព័ន្ធគ្រប់គ្រងតាវកាលិក សម្រាប់របបធានារ៉ាប់រងសុខភាព | ដំណើរការ នៃការរៀបចំប្រព័ន្ធគ្រប់គ្រងតាវកាលិក សម្រាប់របបធានារ៉ាប់រងសុខភាព | ៩០% | ១០០% | | ប.ស.ស |
| | សហការជាមួយក្រសួងមហាផ្ទៃ ដើម្បីកំណត់គោលដៅអត្តសញ្ញាណកម្មករនិយោជិត | ចំនួនកម្មករនិយោជិតមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ID Smart Card) | ៦.០០០ នាក់ | ៦៣០.០០០ នាក់ | ៧៤០.០០០ នាក់ | ប.ស.ស |
| | បង្កើត និងបំពាក់ប្រព័ន្ធនៃការទទួលបណ្តឹងតវ៉ាពីសមាជិក (Complaint System) | ប្រសិទ្ធភាពនៃការដោះស្រាយបណ្តឹងតវ៉ាជូនសមាជិក | ៧០% | ៨៥% | ៩៥% | ប.ស.ស |
| | សិក្សាលទ្ធភាពផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យ(Database Oracle) | ដំណើរការនៃការសិក្សាលទ្ធភាពផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យ | ៧០% | ១០០% | | ប.ស.ស |
| | ដំឡើង និងរៀបចំបន្ទប់ទិន្នន័យឡើងវិញ (Reinstall data center) | ដំណើរការនៃការដំឡើង និងរៀបចំបន្ទប់ទិន្នន័យ | ៩០% | ១០០% | | ប.ស.ស |
| | សិក្សាអំពីលទ្ធភាពផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងរួមរវាងរបបធានារ៉ាប់រងហានិភ័យការងារ និងរបបធានារ៉ាប់រងសុខភាព | ដំណើរការនៃការសិក្សាលទ្ធភាព | ៧០% | ១០០% | | ប.ស.ស |
| | រៀបចំតភ្ជាប់រវាងប្រព័ន្ធគ្រប់គ្រងរបបធានារ៉ាប់រងសុខភាពជាមួយនឹងប្រព័ន្ធគ្រប់គ្រងគណនេយ្យ (Sage) | ប្រសិទ្ធភាពនៃការគ្រប់គ្រងគណនេយ្យរបបធានារ៉ាប់រងសុខភាព | ៩០% | ១០០% | | ប.ស.ស |

| | | | | | | |
|---|---|---|---|---|---|---|
| | បង្កើនល្បឿនការបញ្ជូនទិន្នន័យរវាងស្នាក់ការកណ្ដាល និងការិយាល័យសាខា | ប្រសិទ្ធភាពនៃការបញ្ជូនទិន្នន័យបានទាន់ពេលវេលា | ៩០% | ៩៥% | ៩៧% | ប.ស.ស |
| | រៀបចំនីតិវិធី និងបំពាក់ឧបករណ៍ត្រួតពិនិត្យប្រព័ន្ធ | ដំណើរការនៃការរៀបចំនីតិវិធី និងបំពាក់ឧបករណ៍ត្រួតពិនិត្យប្រព័ន្ធ | ៧០% | ១០០% | | ប.ស.ស |
| រៀបចំវិធីសាស្ត្រទូទាត់ថ្លៃសេវាសុខាភិបាល | រៀបចំយន្តការទូទាត់ថ្លៃសេវាសុខាភិបាល | ប្រសិទ្ធភាព នៃការទូទាត់ថ្លៃសេវាសុខាភិបាល | ៩០% | ១០០% | | ប.ស.ស |
| | រៀបចំប្រព័ន្ធ នៃការទូទាត់ថ្លៃសេវាសុខាភិបាល តាមប្រព័ន្ធព័ត៌មានវិទ្យា | ដំណើរការនៃការរៀបចំប្រព័ន្ធនៃការទូទាត់ថ្លៃសេវាសុខាភិបាល | ៧០% | ១០០% | | ប.ស.ស |
| | រៀបចំប្រកាសអន្តរក្រសួង សម្រាប់ការប្រើប្រាស់សេវាសុខាភិបាល ចំពោះរបបធានារ៉ាប់រងសុខភាព | ដំណើរការនៃការរៀបចំប្រកាសអន្តរក្រសួង | ៩០% | ១០០% | | ប.ស.ស |
| | បង្កើត និងបំពាក់ប្រព័ន្ធត្រួតពិនិត្យសុពលភាព នៃសមាជិកនៅតាមមូលដ្ឋានសុខាភិបាល | ចំនួនមូលដ្ឋានសុខាភិបាល ដែលត្រូវបំពាក់ព្រព័ន្ធ | ១០ | ៥០ | ៨០ | ប.ស.ស |
| | ដាក់ភ្នាក់ងារ ប.ស.ស ប្រចាំការនៅតាមមូលដ្ឋានសុខាភិបាល | ចំនួនភ្នាក់ងារ ប.ស.ស ប្រចាំការនៅតាមមូលដ្ឋានសុខាភិបាល | ១០ នាក់ | ៥០ នាក់ | ៨០ នាក់ | ប.ស.ស |
| ផ្សព្វផ្សាយសាធារណៈ និងអនុវត្ត | ធ្វើសេចក្ដីជូនដំណឹង ស្ដីពីការដាក់ឲ្យអនុវត្តរបបធានារ៉ាប់រងសុខភាព | ចំនួនសេចក្ដីជូនដំណឹង | ១ | ១ | ៥ | ប.ស.ស |
| | ធ្វើសិក្ខាសាលា និងប្រជុំផ្សព្វផ្សាយស្ដីពីការអនុវត្តរបបធានារ៉ាប់រងសុខភាព | ចំនួនសិក្ខាសាលា និងកិច្ចប្រជុំផ្សព្វផ្សាយ តាមបណ្ដារាជធានី-ខេត្ត | ប្រជុំផ្សព្វផ្សាយ ០១ លើក នៅរាជធានីភ្នំពេញ | សិក្ខាសាលា០១ លើក និង ប្រជុំផ្សព្វផ្សាយ ០២ លើក នៅរាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តកំពង់ស្ពឺ | ប្រជុំផ្សព្វផ្សាយ ០៥ លើក នៅ០៥ ខេត្ត-ក្រុង | ប.ស.ស |
| | ផលិតស្ប៉ត និងខិត្តប័ណ្ណផ្សព្វផ្សាយ | ចំនួនស្ប៉ត និង ខិត្តប័ណ្ណផ្សព្វផ្សាយ | ស្ប៉ត ០១ | ខិត្តប័ណ្ណផ្សព្វផ្សាយ ០១ | | ប.ស.ស |

| | | | | | | |
|---|---|---|---|---|---|---|
| | ចុះបញ្ជិកា និងប្រមូលភាគទានសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត | ចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតចុះបញ្ជីក្នុងប្រព័ន្ធ | សហគ្រាស ១១ និង កម្មករ ៦.០០០ នាក់ | សហគ្រាស ៣.៦០០ និង កម្មករ ៦៣០.០០០ នាក់ | សហគ្រាស ៤.៤០០ និង កម្មករ ៧៤០.០០០ នាក់ | ប.ស.ស |
| | ផ្តល់តាវកាលិករបបធានារ៉ាប់រងសុខភាព ដល់កម្មករនិយោជិត | ចំនួនកម្មករនិយោជិត ទទួលបានតាវកាលិករបបធានារ៉ាប់រងសុខភាព | ២.០០០ នាក់ | ៤០០.០០០ នាក់ | ៥០០.០០០ នាក់ | ប.ស.ស |
| **គោលដៅទី៣៖ ដំណើរការរបបប្រាក់សោធន** | | | | | | |
| សិក្សាលទ្ធភាពដាក់ឲ្យដំណើរការរបបប្រាក់សោធន | រៀបចំយន្តការរបបប្រាក់សោធន | ដំណើរការរៀបចំយន្តការរបបប្រាក់សោធន | | ៥០% | ១០០% | ប.ស.ស |
| | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធ | ចំនួនកិច្ចប្រជុំពិគ្រោះយោបល់ | | ៧ លើក | ១២ លើក | ប.ស.ស |
| | សហការ ជាមួយដៃគូពាក់ព័ន្ធក្នុងការវិភាគ វាយតម្លៃលើការអនុវត្ត គម្រោងរបបប្រាក់សោធន | ប្រសិទ្ធភាព នៃការកំណត់អត្រាភាគទានរបបប្រាក់សោធន | | ៥០% | ៩៩% | ប.ស.ស |
| រៀបចំលិខិតបទដ្ឋានគតិយុត្ត និងបណ្តុះបណ្តាលធនធានមនុស្ស | រៀបចំសេចក្តីព្រាងប្រកាស និងលិខិតបទដ្ឋានគតិយុត្ត | ដំណើរការរៀបចំសេចក្តីព្រាងប្រកាស និងលិខិតបទដ្ឋាន | | ៥០% | ១០០% | ប.ស.ស |
| | ធ្វើសិក្ខាសាលា និងកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយដៃគូពាក់ព័ន្ធ ប្រមូលផ្តុំនូវមតិយោបល់ ដើម្បីដាក់បញ្ចូលទៅក្នុងលិខិតបទដ្ឋានគតិយុត្ត | ប្រសិទ្ធភាពនៃការរៀបចំលិខិតបទដ្ឋានគតិយុត្ត | | ៥០% | ៩៩% | ប.ស.ស |
| | បណ្តុះបណ្តាលធនធានមនុស្ស | ចំនួនមន្ត្រី និងបុគ្គលិកមានសមត្ថភាព | | ៥ នាក់ | ១៥ នាក់ | ប.ស.ស |
| រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការអនុវត្តរបបប្រាក់សោធន | សហការជាមួយអ្នកជំនាញការជាតិ ឬអន្តរជាតិក្នុងការកសាងមូលដ្ឋានទិន្នន័យសម្រាប់របបប្រាក់សោធន | ប្រសិទ្ធភាពក្នុងការរៀបចំមូលដ្ឋានទិន្នន័យ និងប្រព័ន្ធគ្រប់គ្រងការផ្តល់ប្រាក់សោធន | | ៥០% | ១០០% | ប.ស.ស |

| | | | | | | |
|---|---|---|---|---|---|---|
| | បង្កើតប្រព័ន្ធនៃការចុះបញ្ជិកា និងបង់ភាគទាន | ដំណើរការរៀបចំប្រព័ន្ធចុះបញ្ជិកា និងការបង់ភាគទាន | | ៥0% | ១00% | ប.ស.ស |
| | សិក្សាលទ្ធភាពបញ្ជូនទិន្នន័យទៅកាន់គណនេយ្យរបស់និវត្តន៍ជននៅធនាគារដៃគូ | ដំណើរការសិក្សាលទ្ធភាពបញ្ជូនទិន្នន័យ | | ៥0% | ៩0% | ប.ស.ស |
| | ប្រមូលទិន្នន័យសម្រាប់ការវិភាគ និងវាយតម្លៃការអនុវត្តរបបប្រាក់សោធន | ប្រសិទ្ធភាពក្នុងការគណនាតាវកាលិក | | ៥0% | ៩0% | ប.ស.ស |
| ផ្សព្វផ្សាយសាធារណៈ និងអនុវត្ត | ធ្វើសេចក្តីជូនដំណឹង ស្តីពីការអនុវត្តរបបប្រាក់សោធន | ចំនួនសេចក្តីជូនដំណឹង | | | ១ | ប.ស.ស |
| | ធ្វើសិក្ខាសាលា និងប្រជុំផ្សព្វផ្សាយស្តីពីការអនុវត្តរបបប្រាក់សោធន | ចំនួនសិក្ខាសាលា និងកិច្ចប្រជុំផ្សព្វផ្សាយ តាមបណ្តារាជធានី-ខេត្ត | | | សិក្ខាសាលា០១ លើក និងប្រជុំផ្សព្វផ្សាយ ០២ លើក នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ | ប.ស.ស |
| | ផលិតស្ប៉ត និងខិត្តប័ណ្ណផ្សព្វផ្សាយ | ចំនួនស្ប៉ត និងខិត្តប័ណ្ណផ្សព្វផ្សាយ | | | ស្ប៉ត០១ និងខិត្តប័ណ្ណផ្សព្វផ្សាយ ០១ | ប.ស.ស |
| | ប្រមូលភាគទានសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត | ចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតបង់ភាគទាន | | | សហគ្រាស ៤.៤00 និងកម្មករ ៧៤0.000 នាក់ | ប.ស.ស |

# ឧបសម្ព័ន្ធទី១

## ស្ថានភាពសហគ្រាស គ្រឹះស្ថាន និងអ្នកចូលរួមការងារ (ជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ)

### ១. ចំនួនសហគ្រាសបែងចែកតាមទំហំនៃអ្នកចូលរួមការងារ និងភេទនៃអ្នកតំណាង

| ទំហំនៃ អ្នកចូលរួមការងារ (នាក់) | ភេទនៃអ្នកចូលរួមការងារ | | | | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| | (សហគ្រាស) | | | (ភាគរយ) | | |
| សរុប | ***505,134*** | ***176,128*** | ***329,006*** | ***100.0*** | ***34.9*** | ***65.1*** |
| **1** | 222,126 | 54,849 | 167,277 | 44 | 10.9 | 33.1 |
| **2** | 176,219 | 66,448 | 109,771 | 34.9 | 13.2 | 21.7 |
| **3** | 46,377 | 19,331 | 27,046 | 9.2 | 3.8 | 5.4 |
| **4** | 20,875 | 10,100 | 10,775 | 4.1 | 2 | 2.1 |
| **5** | 10,746 | 5,753 | 4,993 | 2.1 | 1.1 | 1 |
| **6** | 6,609 | 3,796 | 2,813 | 1.3 | 0.8 | 0.6 |
| **7** | 4,154 | 2,621 | 1,533 | 0.8 | 0.5 | 0.3 |
| **8** | 2,820 | 1,843 | 977 | 0.6 | 0.4 | 0.2 |
| **9** | 2,038 | 1,373 | 665 | 0.4 | 0.3 | 0.1 |
| **10-19** | 8,080 | 5,961 | 2,119 | 1.6 | 1.2 | 0.4 |
| **20-49** | 3,469 | 2,732 | 737 | 0.7 | 0.5 | 0.1 |
| **50-99** | 834 | 673 | 161 | 0.2 | 0.1 | 0 |
| **100-499** | 545 | 448 | 97 | 0.1 | 0.1 | 0 |
| **500-999** | 123 | 108 | 15 | 0 | 0 | 0 |
| **1000 និងច្រើនជាង** | 119 | 92 | 27 | 0 | 0 | 0 |
| **5 និងច្រើនជាង** | 39,537 | 25,400 | 14,137 | 7.8 | 5 | 2.8 |
| **10 និងច្រើនជាង** | 13,170 | 10,014 | 3,156 | 2.6 | 2 | 0.6 |
| **20 និងច្រើនជាង** | 5,090 | 4,053 | 1,037 | 1 | 0.8 | 0.2 |
| **50 និងច្រើនជាង** | 1,621 | 1,321 | 300 | 0.3 | 0.3 | 0.1 |
| **100 និងច្រើនជាង** | 787 | 648 | 139 | 0.2 | 0.1 | 0 |
| **500 និងច្រើនជាង** | 242 | 200 | 42 | 0 | 0 | 0 |
| **1-10** | 493,510 | 167,230 | 326,280 | 97.7 | 33.1 | 64.6 |
| **11-50** | 10,041 | 7,609 | 2,432 | 1 | 1.5 | 0.5 |
| **51-100** | 801 | 645 | 156 | 0.2 | 0.1 | 0 |
| **101 និងច្រើនជាង** | 782 | 644 | 138 | 0.2 | 0.1 | 0 |

## ២. ចំនួនអ្នកចូលរួមការងារបែងចែកតាមទំហំនៃអ្នកចូលរួមការងារ និងភេទ

| ទំហំនៃអ្នកចូលរួមការងារ | ភេទនៃអ្នកចូលរួមការងារ | | | | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| | (នាក់) | | | (ភាគរយ) | | |
| សរុប | ***1,676,263*** | ***650,179*** | ***1,026,084*** | ***100.0*** | ***38.8*** | ***61.2*** |
| **1** | 222,126 | 54,849 | 167,277 | 13.3 | 3.3 | 10 |
| **2** | 352,438 | 142,415 | 210,023 | 21 | 8.5 | 12.5 |
| **3** | 139,131 | 60,746 | 78,385 | 8.3 | 3.6 | 4.7 |
| **4** | 83,500 | 41,565 | 41,935 | 5 | 2.5 | 2.5 |
| **5** | 53,730 | 28,986 | 24,744 | 3.2 | 1.7 | 1.5 |
| **6** | 39,654 | 22,169 | 17,485 | 2.4 | 1.3 | 1 |
| **7** | 29,078 | 16,737 | 12,341 | 1.7 | 1 | 0.7 |
| **8** | 22,560 | 13,057 | 9,503 | 1.3 | 0.8 | 0.6 |
| **9** | 18,342 | 10,606 | 7,736 | 1.1 | 0.6 | 0.5 |
| **10-19** | 106,188 | 62,939 | 43,249 | 6.3 | 3.8 | 2.6 |
| **20-49** | 99,719 | 57,107 | 42,612 | 5.9 | 3.4 | 2.5 |
| **50-99** | 55,353 | 31,697 | 23,656 | 3.3 | 1.9 | 1.4 |
| **100-499** | 110,359 | 47,996 | 62,363 | 6.6 | 2.9 | 3.7 |
| **500-999** | 86,906 | 21,792 | 65,114 | 5.2 | 1.3 | 3.9 |
| **1000 និងច្រើនជាង** | 257,179 | 37,518 | 219,661 | 15.3 | 2.2 | 13.1 |
| **5 និងច្រើនជាង** | 879,068 | 350,604 | 528,464 | 52.4 | 20.9 | 31.5 |
| **10 និងច្រើនជាង** | 715,704 | 259,049 | 456,655 | 42.7 | 15.5 | 27.2 |
| **20 និងច្រើនជាង** | 609,516 | 196,110 | 413,406 | 36.4 | 11.7 | 24.7 |
| **50 និងច្រើនជាង** | 509,797 | 139,003 | 370,794 | 30.4 | 8.3 | 22.1 |
| **100 និងច្រើនជាង** | 454,444 | 107,306 | 348,138 | 2701 | 6.4 | 20.7 |
| **500 និងច្រើនជាង** | 344,085 | 59,310 | 284,775 | 20.5 | 3.5 | 17 |
| **1-10** | 976,019 | 400,348 | 575,671 | 58.2 | 23.9 | 34.3 |
| **11-50** | 192,347 | 111,984 | 80,363 | 11.5 | 6.7 | 4.8 |
| **51-100** | 53,953 | 30,764 | 23,189 | 3.2 | 1.8 | 1.4 |
| **101 និងច្រើនជាង** | 453,944 | 107,083 | 346,861 | 27.1 | 6.4 | 20.7 |

## ៣. ចំនួនសហគ្រាសបែងចែកតាមចំណាត់ថ្នាក់វិស័យស្តង់ដារអន្តរជាតិ និងភេទនៃអ្នកតំណាង

| (ផ្នែកនៃចំណាត់ថ្នាក់វិស័យ ស្តង់ដារអន្តរជាតិ Rev/4 1) | ភេទនៃអ្នកតំណាង | | |
|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី |
| **សរុប** | ***505,134*** | ***176,128*** | ***329,006*** |
| B សកម្មភាពអាជីវកម្មរ៉ែ និងថ្ម | 177 | 136 | 41 |
| C សកម្មភាពផលិតកម្ម | 75,031 | 39,998 | 35,033 |
| D ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន និងខ្យល់ត្រជាក់ | 4,578 | 3,848 | 730 |
| E ការផ្គត់ផ្គង់ទឹក ការងារគ្រប់គ្រងទឹកស្អុយកាកសំណល់ និងការកែច្នៃកាកសំណល់ | 458 | 338 | 120 |
| F សំណង់ | 185 | 146 | 39 |
| G ការលក់ដុំ និងលក់រាយ ការជួសជុលយានយន្ត និងទោចក្រយានយន្ត | 289,130 | 73,516 | 215,614 |
| H ការដឹកជញ្ជូន និងស្តុកទុក | 1,558 | 1,195 | 363 |
| I សកម្មភាពខាងការស្នាក់នៅ និងសកម្មភាពសេវាផ្នែកចំណីអាហារ | 69,569 | 14,612 | 54,957 |
| J ផ្នែកព័ត៌មានវិទ្យា និងទំនាក់ទំនងទូរគមនាគមន៍ | 4,708 | 3,804 | 904 |
| K សកម្មភាពហិរញ្ញវត្ថុ និងការធានារ៉ាប់រង | 3,582 | 1,614 | 1,968 |
| L សកម្មភាពអចលនទ្រព្យ | 121 | 77 | 44 |
| M សកម្មភាពមុខរបរវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស | 965 | 657 | 308 |
| N សកម្មភាពសេវាកម្មរដ្ឋបាល និងសេវាគាំទ្រកិច្ចការនេះ | 5,962 | 3,898 | 2,064 |
| P ការសិក្សាអប់រំ | 9,872 | 8,441 | 1,431 |
| Q សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គមកិច្ច | 4,877 | 3,841 | 1,036 |
| R សកម្មភាពសិល្បៈ គ្រឿងកំសាន្ត និងការកំសាន្ត | 1,780 | 1,104 | 676 |
| S សកម្មភាពសេវាកម្មដទៃទៀត | 32,581 | 18,903 | 13,678 |

## ៤. ចំនួនសហគ្រាសបែងចែកតាមភេទនៃអ្នកតំណាង តាមរាជធានី/ខេត្ត

| ខេត្ត | ភេទនៃអ្នកតំណាង | | | | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| | (សហគ្រាស) | | | (ភាគរយ) | | |
| **សរុប** | ***505,134*** | ***176,128*** | ***329,006*** | ***100.0*** | ***34.9*** | ***65.1*** |
| 01 បន្ទាយមានជ័យ | 21,541 | 7,555 | 13,986 | 4.3 | 1.5 | 2.8 |
| 02 បាត់ដំបង | 34,097 | 11,271 | 22,826 | 6.8 | 2.2 | 4.5 |
| 03 កំពង់ចាម | 56,263 | 21,516 | 34,747 | 11.1 | 4.3 | 6.9 |

| | | | | | | |
|---|---|---|---|---|---|---|
| 04 កំពង់ឆ្នាំង | 19,690 | 7,601 | 12,089 | 3.9 | 1.5 | 2.4 |
| 05 កំពង់ស្ពឺ | 22,541 | 10,042 | 12,499 | 4.5 | 2.0 | 2.5 |
| 06 កំពង់ធំ | 22,284 | 7,369 | 14,915 | 4.4 | 1.5 | 3.0 |
| 07 កំពត | 17,042 | 5,729 | 11,313 | 3.4 | 1.1 | 2.2 |
| 08 កណ្តាល | 40,531 | 14,838 | 25,693 | 8 | 2.9 | 5.1 |
| 09 កោះកុង | 5,051 | 1,397 | 3,654 | 1.0 | 0.3 | 0.7 |
| 10 ក្រចេះ | 11,046 | 3,585 | 7,461 | 2.2 | 0.7 | 1.5 |
| 11 មណ្ឌលគិរី | 2,222 | 788 | 1,434 | 0.4 | 0.2 | 0.3 |
| 12 ភ្នំពេញ | 95,848 | 29,785 | 66,063 | 19.0 | 5.9 | 13.1 |
| 13 ព្រះវិហារ | 5,317 | 2,571 | 2,746 | 1.1 | 0.5 | 0.5 |
| 14 ព្រៃវែង | 29,933 | 11,479 | 18,454 | 5.9 | 2.3 | 3.7 |
| 15 ពោធិ៍សាត់ | 12,075 | 4,094 | 7,981 | 2.4 | 0.8 | 1.6 |
| 16 រតនៈគិរី | 5,480 | 2,080 | 3,400 | 1.1 | 0.4 | 0.7 |
| 17 សៀមរាប | 32,120 | 10,509 | 21,611 | 6.4 | 2.1 | 4.3 |
| 18 ព្រះសីហនុ | 10,728 | 3,064 | 7,664 | 2.1 | 0.6 | 1.5 |
| 19 ស្ទឹងត្រែង | 4,665 | 1,675 | 2,990 | 0.9 | 0.3 | 0.6 |
| 20 ស្វាយរៀង | 15,245 | 7,242 | 8,003 | 3.0 | 1.4 | 1.6 |
| 21 តាកែវ | 31,997 | 8,652 | 23,345 | 6.3 | 1.7 | 4.6 |
| 22 ឧត្តរមានជ័យ | 4,912 | 1,716 | 3,196 | 1.0 | 0.3 | 0.6 |
| 23 កែប | 1,635 | 539 | 1,096 | 0.3 | 0.1 | 0.2 |
| 24 ប៉ៃលិន | 2,871 | 1,031 | 1,840 | 0.6 | 0.2 | 0.4 |

# ឧបសម្ព័ន្ធទី២

## បេឡាជាតិរបបសន្តិសុខសង្គម
## ការអនុវត្តរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារ ( ជំហានទី១ )
## ឆ្នាំ២០១២

### ១. ការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានហានិភ័យការងារ

| ប្រាក់ឈ្នួលប្រចាំខែ (គិតជារៀល) | ប្រាក់ឈ្នួលមធ្យមប្រចាំខែ (គិតជារៀល) | ភាគទានប្រចាំខែសម្រាប់កម្មករនិយោជិត ០១ នាក់ (គិតជារៀល) |
|---|---|---|
| ២០០.០០០ ចុះ | ២០០.០០០ | ១.៦០០ |
| ២០០.០០១ - ២៥០.០០០ | ២២៥.០០០ | ១.៨០០ |
| ២៥០.០០១ - ៣០០.០០០ | ២៧៥.០០០ | ២.២០០ |
| ៣០០.០០១ - ៣៥០.០០០ | ៣២៥.០០០ | ២.៦០០ |
| ៣៥០.០០១ - ៤០០.០០០ | ៣៧៥.០០០ | ៣.០០០ |
| ៤០០.០០១ - ៤៥០.០០០ | ៤២៥.០០០ | ៣.៤០០ |
| ៤៥០.០០១ - ៥០០.០០០ | ៤៧៥.០០០ | ៣.៨០០ |
| ៥០០.០០១ - ៥៥០.០០០ | ៥២៥.០០០ | ៤.២០០ |
| ៥៥០.០០១ - ៦០០.០០០ | ៥៧៥.០០០ | ៤.៦០០ |
| ៦០០.០០១ - ៦៥០.០០០ | ៦២៥.០០០ | ៥.០០០ |
| ៦៥០.០០១ - ៧០០.០០០ | ៦៧៥.០០០ | ៥.៤០០ |
| ៧០០.០០១ - ៧៥០.០០០ | ៧២៥.០០០ | ៥.៨០០ |
| ៧៥០.០០១ - ៨០០.០០០ | ៧៧៥.០០០ | ៦.២០០ |
| ៨០០.០០១ - ៨៥០.០០០ | ៨២៥.០០០ | ៦.៦០០ |
| ៨៥០.០០១ - ៩០០.០០០ | ៨៧៥.០០០ | ៧.០០០ |
| ៩០០.០០១ - ៩៥០.០០០ | ៩២៥.០០០ | ៧.៤០០ |
| ៩៥០.០០១ - ១.០០០.០០០ | ៩៧៥.០០០ | ៧.៨០០ |
| ១.០០០.០០១ ឡើង | ១០០០.០០០ | ៨.០០០ |

## ២. របាយការណ៍ហានិភ័យការងារឆ្នាំ២០១២

| បរិយាយ | ចំនួនជនរងគ្រោះ | | | | ផ្សេងៗ |
|---|---|---|---|---|---|
| | ករណី | សរុប | ស្រី | ប្រុស | |
| **របាយការណ៍** | ១២.៥២២ | ១៤.៧៦១ | ១១.០២៣ | ៣.៧៣៨ | |
| គ្រោះថ្នាក់កន្លែងធ្វើការ | ៩.២៣៨ | ១០.៩៧៣ | ៨.៥៨៧ | ២.៣៨៦ | |
| គ្រោះថ្នាក់ពេលធ្វើដំណើរ | ៣.២៦០ | ៣.៧៦៤ | ២.៤២២ | ១.៣៤២ | |
| ជម្ងឺវិជ្ជាជីវៈ | ២៤ | ២៤ | ១៤ | ១០ | |
| **លទ្ធផលអង្កេត** | ១២.៦៤១ | ១៤.៧៥៣ | ១១.១២០ | ៣.៦៣៣ | |
| **គ្រោះថ្នាក់ការងារ** | ១២.១២៥ | ១៤.២៣៣ | ១០.៧០៩ | ៣.៥២៤ | |
| ***គ្រោះថ្នាក់កន្លែងធ្វើការ*** | ៨.៩៦៣ | ១០.៥៧៣ | ៨.៣៤២ | ២.២៣១ | |
| របួសស្រាល | - | ១០.៣៥១ | ៨.២១៦ | ២.១៣៥ | |
| របួសធ្ងន់ | - | ២១២ | ១២៣ | ៨៩ | |
| ស្លាប់ | - | ១០ | ៣ | ៧ | |
| ***គ្រោះថ្នាក់ពេលធ្វើដំណើរ*** | ៣.១៤៥ | ៣.៦៤២ | ២.៣៥៧ | ១.២៨៥ | |
| របួសស្រាល | - | ៣.២៣៤ | ២.១២៨ | ១.១០៦ | |
| របួសធ្ងន់ | - | ៣៥៩ | ២១០ | ១៤៩ | |
| ស្លាប់ | - | ៤៩ | ១៩ | ៣០ | |
| ***ជម្ងឺវិជ្ជាជីវៈ*** | ១៨ | ១៨ | ១០ | ៨ | |
| ***មិនមែនជាគ្រោះថ្នាក់ការងារ*** | ៥១៦ | ៥២១ | ៤១២ | ១០៩ | |
| គ្រោះថ្នាក់កន្លែងធ្វើការ | ៤៣៦ | ៤៣៨ | ៣៧៥ | ៦៣ | |
| គ្រោះថ្នាក់ពេលធ្វើដំណើរ | ៧៧ | ៨០ | ៣៥ | ៤៥ | |
| ជម្ងឺវិជ្ជាជីវៈ | ៣ | ៣ | ២ | ១ | |

# ឯកសារយោង


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
២. ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧
៣. ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឆ្នាំ២០០២
៤. អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមឆ្នាំ២០០៧
៥. សេចក្តីប្រកាសជាសាកលអំពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨
៦. សេចក្តីប្រកាសទីក្រុង Philadelphia ឆ្នាំ១៩៤៤
៧. សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ផែនការសហគមន៍អាស៊ានឆ្នាំ២០១៥ សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន និងសេចក្តីថ្លែងការណ៍រួមកិច្ចប្រជុំរដ្ឋមន្ត្រីការងារអាស៊ានបូក៣ លើកទី៧...)
៨. សមាគមសន្តិសុខសង្គមអាស៊ាន (Asean Social Security Association)
៩. អនុសញ្ញាលេខ១០២ របស់អង្គការពលកម្មអន្តរជាតិឆ្នាំ១៩៥២
១០. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងទី២
១១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣
១២. យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (២០១១-២០១៥)
១៣. យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (២០១១-២០២០)
១៤. ផែនការសកម្មភាព អនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ឆ្នាំ២០០៩-២០១៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
១៥. ជំរឿនទូទៅប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
១៦. ជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១
១៧. សូចនាករម៉ាក្រូសេដ្ឋកិច្ច របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កាលបរិច្ឆេទថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣)
១៨. របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០១១ និងទិសដៅភារកិច្ចសម្រាប់ឆ្នាំ២០១២ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
១៩. របាយការណ៍សមិទ្ធផលសុខាភិបាល២០១១ និងទិសដៅការងារ២០១២ របស់ក្រសួងសុខាភិបាល
២០. របាយការណ៍បូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១២ និងទិសដៅអនុវត្តឆ្នាំ២០១៣ របស់បេឡាជាតិរបបសន្តិសុខសង្គម